**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព នៅក្រុងដូនកែវ ខេត្តតាកែវ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ **ភិក្ខុ. ញ៉ៀម ទាសនា** | សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា** |
| **ក. គឹម ស្រីធា** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលរៀន | ២០២០ |
| ជំនាន់ទី២៤ | | ឆ្នាំសរសេរសារណា | ២០២៤ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព នៅក្រុងដូនកែវ ខេត្តតាកែវ

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ **ភិក្ខុ. ញ៉ៀម វាសនា** | សាស្ត្រាចារ្យជំនួយ **បណ្ឌិត អ៊ុន សកក្កដា** |
| **ក. គឹម ស្រីឆា** | |


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | | ឆ្នាំចូលរៀន | ២០២០ |
| ជំនាន់ទី២៤ | | ឆ្នាំសរសេរសារណា | ២០២៤ |

# សេចក្តីថ្លែងអំណរគុណ

អាត្មាភាព **ញ៉ៀម វាសនា** និងនាងខ្ញុំ **គីម ស្រីឆា** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៤ ឆ្នាំសិក្សា២០២០-២០២៤។

ជាបឋមអាត្មាភាព និងនាងខ្ញុំ សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើត ខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចក្រូចឆ្មារហូតដល់ធំធាត់ពេញវ័យ ព្រមទាំងផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ និងការអប់រំទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ។ មិនតែប៉ុណ្ណោះ លោកទាំងពីរបានផ្តល់នូវការផ្គត់ផ្គង់ថវិកា និងសិក្ខាបករណ៍ចាប់តាំងពីកម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រធ្វើឱ្យកូនចងចាំជានិច្ចដោយមិនអាចបំភ្លេចបាន។

សូមគោរពថ្លែងអរគុណចំពោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន អប់រំទូន្មាន លះបង់ពេលវេលាព្រមទាំងកម្លាំងកាយកម្លាំងចិត្តដល់ខ្ញុំទាំងពីរក្នុងរយៈពេលបួនឆ្នាំកន្លងមកដើម្បីឱ្យ អាត្មាភាព និងនាងខ្ញុំទទួលបាន នូវចំណេះដឹង ផ្នែកនីតិសាស្ត្រ លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងច្បាប់ជាតិ ព្រមទាំងច្បាប់អន្តរជាតិថែមទៀតផង។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យជំនួយបណ្ឌិត អ៊ុន សតក្កដា** ដែលជាសាស្ត្រាចារ្យណែនាំដើម្បីធ្វើឱ្យមាននូវដំណើរការ នៃការតាក់តែង កិច្ចការស្រាវជ្រាវនេះឡើង ប្រកបដោយភាពជោគជ័យ។ ជាពិសេសទៀតនោះគាត់បានចំណាយកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិសផ្តល់ឯកសារពាក់ព័ន្ធ និងអនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើយ៉ាងណាឱ្យកិច្ចការស្រាវជ្រាវមួយនេះ បានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ។

ជាចុងក្រោយក៏សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកសូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតា ឥន្ទព្រហ្មជួយឱ្យប្រទេសជាតិយើង រួមទាំងប្រជាជនកម្ពុជាទាំងអស់ជួបតែសន្តិភាព សុវត្ថិភាព និងអភិវឌ្ឍន៍រីកចម្រើនឆ្ពោះទៅមុខជានិរន្តន៍។

## អារម្ភកថា

ដោយទទួលបានការឆ្លងកាត់នៃសិក្សារយៈពេលបួនឆ្នាំកន្លងមកនេះ អាត្មាភាព និងនាងខ្ញុំបានធ្វើការសិក្សាទៅ លើកិច្ចការស្រាវជ្រាវជាច្រើនដោយទទួលបានចំណេះដឹងដែលមានការណែនាំ និងការកែសម្រួលពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យជាច្រើន ហើយធ្វើឱ្យចំណេះដឹងមានការរីកចម្រើនជានិច្ច ទោះបីជាមិនល្អឥតខ្ចោះក៏ដោយ។ អាត្មាភាព និងនាងខ្ញុំក្នុងនាមជានិស្សិតបានសិក្សានៅក្នុង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំទី៤ ផ្នែកនីតិសាស្ត្រ** ពិតជាមានសេចក្តីសោមនស្សរីករាយណាស់ដែលទទួលបានឱកាស និងមានលទ្ធភាពក្នុងការសរសេរសារណាបញ្ចប់ការសិក្សា សម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយ ហើយការស្រាវជ្រាវមួយនេះក៏អាចស្ទង់អំពីចំណេះដឹងតាមរយៈការសិក្សាកន្លងមក និងធ្វើការស្រាវជ្រាវបន្ថែមទៀត។ ដោយទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សាបានជំរុញឱ្យអាត្មាភាព និងនាងខ្ញុំ បានពិភាក្សាជ្រើសរើសយកប្រធានបទដែលទាក់ទងនឹងនីតិនគរូបនីយកម្ម និងសំណង់ស្តីពី "**ការរៀបចំសណ្តាប់ និងសោភ័ណភាពនៅក្រុងដូនកែវ ខេត្តតាកែវ**" មកធ្វើជាប្រធានបទក្នុងការសរសេរសារណាបញ្ចប់ការសិក្សា។

អាត្មាភាព និងនាងខ្ញុំសង្ឃឹមថា សារណាដែលបានសរសេរមកនេះ និងអាចជួយសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិតជំនាន់ក្រោយដល់សាធារណជនដែលចង់ស្វែងយល់អំពីការរៀបចំសណ្តាប់ និងសោភ័ណភាពនៅក្រុងដូនកែវ ខេត្តតាកែវ។ បើទោះបីជាប្រធានបទនេះធ្វើការបកស្រាយមិនទាន់បានគ្រប់ជ្រុងជ្រោយ ឬមានការខ្វះចន្លោះយ៉ាងណាក្តី ប៉ុន្តែអាត្មាភាព និងនាងខ្ញុំសង្ឃឹមថា និងបានជាប្រយោជន៍ដល់មិត្តអ្នកអានដែលចង់ស្រាវជ្រាវបន្ត។

មុននឹងបញ្ចប់អាត្មាភាព និងនាងខ្ញុំ សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំណុចដែលមានការខ្វះខាត កំហុសឆ្គងដែលកើតឡើងដោយអចេតនាលើប្រការណាមួយរួមមាន ការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឬត្រង់អត្ថន័យខ្លឹមសារនៅក្នុងប្រធានបទនេះ និងសូមស្វាគមន៍ទទួលយកនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាកែលម្អដើម្បីធ្វើឱ្យសារណានេះកាន់តែមានភាពល្អប្រសើរឡើង។

ជាទីបញ្ចប់ សូមគោរពជូនពរមិត្តអ្នកអាន លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់សូមឱ្យទទួលបាននូវសំណាងល្អគ្រប់ពេលវេលាជោគជ័យគ្រប់ភារកិច្ចជោគជ័យលើការសិក្សា និងសមប្រកបជួបពុទ្ធពរបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការរៀបចំក្រុងដូនកែវ

**១.១. ទិដ្ឋភាពទូទៅនៃក្រុងដូនកែវ** ........ ៤

១.១.១. ទីតាំងភូមិសាស្ត្រ ........ ៤

១.១.២. ស្ថានភាពប្រជាសាស្ត្រ ........ ៥

១.១.២.១. ដង់ស៊ីតេប្រជាជន ........ ៥

១.១.២.២. ជីវភាពប្រជាជន ........ ៦

**១.២. សមត្ថកិច្ចពាក់ព័ន្ធក្នុងការរៀបចំក្រុងដូនកែវ** ........ ៦

១.២.១. សមាសភាព ........ ៦

១.២.១.១. ក្រុមប្រឹក្សាក្រុង ........ ៧

១.២.១.២. គណៈអភិបាលក្រុង ........ ៩

១.២.២. តួនាទី និងភារកិច្ច ........ ១០

១.២.២.១. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ........ ១០

១.២.២.២. តួនាទី និងភារកិច្ចរបស់គណៈអភិបាលក្រុង ........ ១៦

**១.៣. កត្តាដែលនាំឱ្យមានការរៀបចំក្រុងដូនកែវ** ........ ២២

១.៣.១. កំណើនប្រជាជន ........ ២២

១.៣.២. ភាពក្រីក្រ ........ ២៣

១.៣.៣. ការដាក់សម្ពាធបរិស្ថាន ........ ២៥

១.៣.៤. គមនាគមន៍ និងចរាចរណ៍ ........ ២៥

## ជំពូកទី២

## ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ នៅក្នុងក្រុងដូនកែវ ខេត្តតាកែវ


**២.១. ការរៀបចំសោភ័ណភាពនៅក្រុងដូនកែវ**........................................................២៧

២.១.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ........................................................២៧

២.១.២. ការរៀបចំសោភ័ណភាពនាពេលយប់........................................................២៩

**២.២. ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងដូនកែវ**........................................................២៩

២.២.១. សន្តិសុខ........................................................៣១

២.២.២. បញ្ហាចរាចរក្រុងដូនកែវ........................................................៣៤

២.២.៣. ភាពស្ងប់ស្ងៀម........................................................៣៥

**២.៣. បញ្ហាប្រឈម និងដំណោះស្រាយ**........................................................៣៦

២.៣.១. បញ្ហាប្រឈម........................................................៣៦

២.៣.១.២. ធនធានមនុស្ស........................................................៣៦

២.៣.១.៣. កង្វះគម្រោងថវិកា និងកង្វះបច្ចេកទេស........................................................៣៧

២.៣.១.៤. ការបំពុលបរិស្ថានទាំងប្រាំ........................................................៣៨

២.៣.២. ដំណោះស្រាយ........................................................៤៣

២.៣.២.១. ដំណោះស្រាយធនធានមនុស្ស........................................................៤៣

២.៣.២.២. ដំណោះស្រាយគម្រោងថវិកា និងបច្ចេកទេស........................................................៤៤

២.៣.២.៣. ដំណោះស្រាយការបំពុលទាំងប្រាំ........................................................៤៥

**២.៤. លទ្ធផលសម្រេចបាន និងទិសដៅអនាគត**........................................................៤៩

២.៤.១. ស្ថានភាពបច្ចុប្បន្ន........................................................៤៩

២.៤.២. ផ្នែកសង្គមកិច្ច........................................................៥០

២.៤.៣. ទិសដៅអនាគត ........................................................................................................ ៥៣

២.៤.៣.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច ........................................................................ ៥៤

២.៤.៣.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធ ........................................................ ៥៥

២.៤.៣.៣. យុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យទឹកស្អាត ...................................................................... ៥៨

**សេចក្តីសន្និដ្ឋាន**..........................................................................................................៦០

**អនុសាសន៍**..............................................................................................................៦១

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនទសវត្ស ព្រះរាជាណាចក្រកម្ពុជាក៏កំពុងតែធ្វើដំណើរក្នុងការខិតខំប្រឹងប្រែងនៅក្នុងការរៀបចំសណ្តាប់ធ្នាប់នឹងធ្វើការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ ដើម្បីប្រទេសជាតិមានការជឿនលឿនទៅមុខឱ្យដូចប្រទេសកំពុងអភិវឌ្ឍដទៃទៀតនៅលើសកលលោក។ នៅក្នុងការរៀបសណ្តាប់ធ្នាប់ និងចំសោភ័ណភាពនៅប្រទេសកម្ពុជាមានការអភិវឌ្ឍគ្រប់ទីកន្លែងផងដែររួមមានដូចជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនានាដែលជាតម្រូវការចាំបាច់សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ។

ស្របពេលដែលប្រទេសកម្ពុជា ជាប្រទេសកំពុងតែអភិវឌ្ឍនឹងត្រូវធ្វើការរៀបចំ និងអភិវឌ្ឍន៍ឱ្យបានស្របទៅតាមការកំណត់របស់ប្លង់គោលដែលបានរៀបចំដោយ គណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព គឺជាកត្តាមួយដ៏សំខាន់នៅក្នុងកែលម្អឱ្យមានភាពល្អប្រសើរឡើងស្របទៅតាមប្លង់គោលស្តង់ដារបច្ចេកទេស និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺដើម្បីធ្វើយ៉ាងណាឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនានាមានសោភ័ណភាព និងសណ្តាប់ធ្នាប់ប្រកបទៅដោយភាពល្អប្រសើរជឿនលឿនទៅមុខបន្ថែមទៀត។

ដោយឡែកខេត្ត ក្រុងមួយចំនួននៅក្នុងប្រទេសកម្ពុជាក៏នៅមានភាពខ្វះចន្លោះ និងមានបញ្ហាប្រឈមជាច្រើនផងដែរ។ ដោយពេលបច្ចុប្បន្ន រដ្ឋបាលខេត្តក្រុងបាននឹងកំពុងតែខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានកើតឡើង និងការកសាងហេដ្ឋារចនាសម្ព័ន្ធឱ្យបានស្របទៅតាមប្លង់គោលស្តង់ដារបច្ចេកទេស ដើម្បីឱ្យខេត្តក្រុងមានសណ្តាប់ធ្នាប់ សោភ័ណភាព របៀបរៀបរយ សន្តិសុខ សុវត្ថិភាពនៃការរស់នៅ គឺសុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ ដោយបានមើលឃើញពីកត្តាទាំងអស់នេះហើយ ទើបក្រុមយើងខ្ញុំបានសម្រេចជ្រើសរើសប្រធានបទទាក់ទងនឹងនីតិនគរូបនីយកម្ម និងសំណង់ស្តីពី "ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងដូនកែវ ខេត្តតាកែវ" ដើម្បីធ្វើការស្រាវជ្រាវបញ្ចប់ការសិក្សា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្ថិតនៅក្នុងក្រុងដូនកែវខេត្តតាកែវ គឺមានគណៈអភិបាលក្រុង និងអភិបាលរងក្រុងរួមជាមួយមន្ត្រីពាក់ព័ន្ធទាំងអស់ដែលមានតួនាទីក្នុងការអភិវឌ្ឍ និងរៀបចំក្រុងដូនកែវឱ្យបានល្អប្រសើរ។ ទោះជាយ៉ាងនេះក្តីដើម្បីឱ្យនិស្សិត មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ សាធារណជនបានស្វែងយល់ និងធ្វើការសិក្សាស្រាវជ្រាវឱ្យមានលក្ខណៈស៊ីជម្រៅ និងមានភាពច្បាស់លាស់ទាក់ទងនឹងប្រធានបទសារណាបញ្ចប់ការសិក្សាខាងលើ យើងខ្ញុំបានលើកឡើងនូវចំណោទបញ្ហាមួយចំនួនមកធ្វើការបកស្រាយដែលបញ្ហាទាំងនោះរួមមាន៖

១. តើបុព្វហេតុអ្វីខ្លះដែលនាំឱ្យមានការរៀបចំក្រុងដូនកែវ?

២. តើក្រុងដូនកែវមានការអភិវឌ្ឍអ្វីខ្លះ?

៣. តើក្រុងដូនកែវមានដំណោះស្រាយអ្វីខ្លះចំពោះការការពារបរិស្ថានឱ្យមានភាពល្អប្រសើរ?

ដូចនេះនិស្សិត មិត្តអ្នកអាន ឬអ្នកស្រាវជ្រាវ និងសាធារណជន ប្រាកដជាបានយល់ដឹងអំពី ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងដូនកែវហើយស្នាដៃស្រាវជ្រាវនេះអាចយកធ្វើជាឯកសារពិគ្រោះ និងជាឯកសារជំនួយស្មារតីសម្រាប់សិក្សាស្រាវជ្រាវបានទៀតផង។

## ៣. គោលបំណងនៃការស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវទាំងអស់ គឺតែងតែមានគោលបំណងនៅក្នុងការស្រាវជ្រាវ។ ដោយឡែកក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺចង់ឱ្យនិស្សិត មិត្តអ្នកអាន សាធារណជន បានសិក្សាយល់ដឹងពីការអភិវឌ្ឍ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងដូនកែវ ខេត្តតាកែវ។ លើសពីនេះទៀតគោលបំណងនៃការបង្កើតនូវស្នាដៃស្រាវជ្រាវមួយនេះ ក្នុងគោលបំណងបានជួយជំរុញឱ្យមានការអភិវឌ្ឍ ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៃរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌនៅក្នុងប្រទេសកម្ពុជា។ ជាពិសេសនោះ គឺចង់ឱ្យនិស្សិតជំនាន់ក្រោយបានសិក្សាស្វែងយល់អំពីការអភិវឌ្ឍ ការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយ ព្រមទាំងអាចយកជាឯកសារសម្រាប់ជំនួយស្មារតីបន្ថែមលើការស្រាវជ្រាវរបស់ខ្លួន។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវទាំងអស់ តែងតែមានដែនកំណត់របស់ខ្លួន។ ដើម្បីឆ្លើយតបទៅនឹងទិដ្ឋភាពជាក់ស្តែងប្រធានបទខាងលើនេះ ហើយទំហំនៃការស្រាវជ្រាវនឹងលើកយកមកបង្ហាញពីទិដ្ឋភាពនានា ដែលបានពាក់ព័ន្ធជាមួយការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងដូនកែវខេត្តតាកែវ។ ការអនុវត្តតាមផែនការដំណោះស្រាយរបស់អាជ្ញាធរក្រុងដូនកែវ។ ដូច្នេះអ្វីដែលបានទាក់ទងទៅនឹងប្រធានបទស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងដូនកែវ ខេត្តតាកែវ យើងនឹងត្រូវធ្វើការបកស្រាយ និងសិក្សាស្រាវជ្រាវទៅលើអ្វីដែលបានពាក់ព័ន្ធជាមួយនឹងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ អាចចាត់ទុកបានជាការចូលរួមចំណែកនៅក្នុងការអភិវឌ្ឍសង្គមកម្ពុជាផងដែរ។ ដោយបានផ្តល់នូវចំណេះដឹងចំពោះនិស្សិត មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងសាធារណជនទាំងអស់អាចជួយសម្រួលដល់ការអភិវឌ្ឍ ឬការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្រុងដូនកែវ ខេត្តតាកែវ ឬយកទៅ

អភិវឌ្ឍន៍នៅក្រុងណាមួយបន្ថែម។ ម្យ៉ាងទៀតសោត គឺដើម្បីធ្វើយ៉ាងណាឱ្យក្រុងដូនកែវមានសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អជាពិសេសចូលរួមចំណែកក្នុងការជំរុញឱ្យមានការអភិវឌ្ឍថ្មីៗបន្ថែមតទៅខាងមុខទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើការបកស្រាយទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងតួយ៉ាងដែលមានបញ្ហាប្រឈម និងដំណោះស្រាយរបស់អាជ្ញាធរក្រុងដូនកែវ ខេត្តតាកែវ។ ដោយឯកសារទទួលបានពីសាលាក្រុងដូនកែវ សៀវភៅតែងនិពន្ធនៅក្នុងបណ្ណាល័យច្បាប់ បណ្តាញផ្សព្វផ្សាយសង្គម ព្រមទាំងបានធ្វើការសិក្សាស្រាវជ្រាវជាមួយទិដ្ឋភាពទូទៅផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃខិតខំធ្វើការស្រាវជ្រាវ និងការសរសេរសារណាបញ្ចប់ការសិក្សារបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អាត្មាភាព និងនាងខ្ញុំបានធ្វើការបែងចែកជាពីរជំពូកដូចខាងក្រោម៖

### ជំពូកទី១ សញ្ញាណទូទៅនៃការរៀបចំក្រុងដូនកែវ

នៅក្នុងជំពូកនេះ ក្រុមខ្ញុំបានបែងចែកជាបីចំណុចបន្ថែមទៀតដោយ ចំណុចទី១ ទិដ្ឋភាពទូទៅនៃក្រុងដូនកែវ ចំណុចទី២ សមត្ថកិច្ចពាក់ព័ន្ធក្នុងការរៀបចំក្រុងដូនកែវ និងចំណុចទី៣ បង្ហាញពីកត្តាដែលនាំឱ្យមានការរៀបចំក្រុងដូនកែវ។

### ជំពូកទី២ ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់នៅក្រុងដូនកែវ ខេត្តតាកែវ

នៅក្នុងជំពូកនេះផងដែរ ក្រុមខ្ញុំបានបែងចែកជាបួនចំណុចបន្ថែមទៀតដោយ ចំណុចទី១ ការរៀបចំសោភ័ណភាពក្នុងក្រុងដូនកែវ ចំណុចទី២ ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងដូនកែវ ចំណុចទី៣ បញ្ហាប្រឈម និងដំណោះស្រាយ និងចំណុចទី៤ លទ្ធផលដែលសម្រេចបាន និងទិសដៅអនាគត។

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំ

# ក្រុងដូនកែវ

# ជំពូកទី១

# សញ្ញាណទូទៅនៃការរៀបចំក្រុងដូនកែវ

យោងទៅតាមភាពជាក់ស្តែងក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពរបស់ក្រុងដូនកែវនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយមកនេះ សង្កេតឃើញថាក្រុងដូនកែវបានរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពបានយ៉ាងល្អប្រសើរ។ នេះដោយសារតែរដ្ឋបាលក្រុង និងអាជ្ញាធរពាក់ព័ន្ធទាំងអស់មានការយកចិត្តទុកដាក់ជាខ្លាំងទៅលើការរៀបចំសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខ សុខសុវត្ថិភាព និងគិតពីសុខមាលភាពរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុង។ ជាក់ស្តែងដោយមានការសហការបានយ៉ាងល្អរវាងកងកម្លាំងសមត្ថកិច្ចអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ។ ក្នុងនោះរដ្ឋបាលក្រុងបានយកចិត្តទុកដាក់រៀបចំជួសជុលកែលម្អផ្លូវ និងការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែមក្នុងក្រុងដូចជា សាងសង់ផ្លូវក្រាលកៅស៊ូ ផ្លូវបេតុង ដាក់លូ ដាក់ភ្លើងនៅតាមដងផ្លូវ ដាំដើមឈើ និងសួនច្បារជាដើម។ ទោះបីជានៅក្នុងគម្រោងខ្លះនៅសេសសល់ដែលរដ្ឋបាលក្រុងអនុវត្តន៍ពុំទាន់មានប្រសិទ្ធិភាព និងមិនទាន់មានការផ្លាស់ប្តូរក៏ដោយក្តីរដ្ឋបាលក្រុងបានខិតខំបន្តជំរុញការកែលម្អដើម្បីធានាឱ្យបាននូវលទ្ធផលល្អប្រសើរបន្ថែមទៀត។ តាមរយៈការចូលរួមសហការពីប្រជាពលរដ្ឋរួមជាមួយ និងមន្ត្រីជំនាញដែលពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់បានជំរុញឱ្យក្រុងដូនកែវ មានការអភិវឌ្ឍជាបន្តបន្ទាប់ដោយបានរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ របៀបរៀបរយឱ្យបានកាន់តែមានភាពល្អប្រសើរ និងរីកចម្រើនបន្ថែមទៀត។

## ១.១. ទិដ្ឋភាពទូទៅនៃក្រុងដូនកែវ

### ១.១.១. ទីតាំងភូមិសាស្ត្រ

ក្រុងដូនកែវមានទីតាំងភូមិសាស្ត្រស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា មានចម្ងាយ៧៨គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ២ និង៨៧គីឡូម៉ែត្រតាមផ្លូវជាតិលេខ៣ ព្រមទាំង៧៥គីឡូម៉ែត្រតាមផ្លូវដែកពីរាជធានីភ្នំពេញដែលមានព្រំប្រទល់ជាប់នឹងស្រុកចំនួន០៤ គឺខាងជើងជាប់នឹងស្រុកសំរោង ខាងត្បូងជាប់នឹងស្រុកទ្រាំង ខាងកើតជាប់នឹងស្រុកអង្គរបុរី និងខាងលិចជាប់នឹងស្រុកត្រាំកក់។[១] ដោយមានចំនួន ០៣សង្កាត់គឺសង្កាត់រកាក្នុង សង្កាត់រកាក្រៅ និងសង្កាត់បារាយណ៍ និងមានភូមិចំនួន ៤០ភូមិដោយមានផ្ទៃដីប្រមាណ ៩,៤៦៩,៧២ ហិកតា។ ក្រុងដូនកែវមានសក្តានុពលដែលគ្រាំទ្រដល់ការរស់នៅការធ្វើដំណើរការប្រកបការងារនិងការលំហែកម្សាន្តព្រមទាំងមានអំណោយផលល្អដល់ទំនាក់ទំនងសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន។

[១] របាយការណ៍ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងដូនកែវប្រចាំឆ្នាំ២០២៣, ទំព័រទី១

ក្រុងដូនកែវជាមជ្ឈមណ្ឌលសេដ្ឋកិច្ចស្នូល សង្គមកិច្ច វប្បធម៌ ដ៏រស់រវើករបស់ខេត្តតាកែវដែលមានទំនាក់ទំនងដ៏ល្អប្រសើរជាមួយរាជធានីភ្នំពេញ និងបណ្តាលស្រុកដទៃទៀតទូទាំងខេត្តតាកែវ។[២]

### ១.១.២. ស្ថានភាពប្រជាសាស្ត្រ

ក្រុងដូនកែវ ជាក្រុងមួយក្នុងចំណោមក្រុង ស្រុក ទាំង១០ នៃខេត្តតាកែវ ស្ថិតនៅចំកណ្តាលជាបេះដូងនៃខេត្តតាកែវ ដែលមានព្រំប្រទល់ខាងជើងជាប់ស្រុកសំរោង ខាងកើតជាប់នឹងស្រុកអង្គរបុរី ខាងលិចជាប់នឹងស្រុកត្រាំកក់ និងខាងត្បូងជាប់នឹងស្រុកទ្រាំង។ ដែលមានដង់ស៊ីតេប្រជាជន ៤៧៨នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា និងមានសក្តានុភាពខាងសេដ្ឋកិច្ច ដោយមានទីផ្សារដ៏ធំ ដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់សម្រាប់ធ្វើចរាចរណ៍ទំនិញទាំងក្នុងស្រុក និងក្រៅស្រុកវិស័យកសិកម្មក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។

ដោយប្រជាពលរដ្ឋប្រមាណ ៥០,១៩% ប្រកបរបរធ្វើស្រែ ដោយទទួលបានទិន្នផលខ្ពស់ តម្លៃសមរម្យពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យដោយក្រុងដូនកែវមានប្រព័ន្ធធារាសាស្ត្រស្រោចស្រពគ្រប់គ្រាន់ និងមានប្រព័ន្ធគមនាគមន៍ខ្វែងខ្វាត់ល្អងាយស្រួលក្នុងការធ្វើដំណើរ និងដឹកជញ្ជូនទិន្នផល។ កត្តាស្ថេរភាពនយោបាយ សន្តិសុខសុវត្ថិភាព និងការអនុវត្តផ្សព្វផ្សាយច្បាប់ បច្ចុប្បន្នក្រុងដូនកែវមានកំណើនវិនិយោគទុនទាំងក្នុងប្រទេស និងក្រៅប្រទេសមកបណ្តាក់ទុន បង្កើតជារោងចក្រសហគ្រាស សិប្បកម្មសំបូរបែប ដែលផ្តល់នូវឱកាសការងារជាច្រើនដល់ប្រជាពលរដ្ឋធ្វើអោយកម្រិតជីវភាពមានការកើនឡើង និងជាពិសេសរួមចំណែកយ៉ាងសំខាន់ណាស់ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។[៣]

#### ១.១.២.១. ដង់ស៊ីតេប្រជាជន

ក្រុងដូនកែវមានដីសរុបចំនួន ៩.៤៦៩,២២ហិកតា ចែកចេញជាដីលំនៅដ្ឋាន ១.០៧៥,៥៩ហិកតា ផ្ទៃដីធ្វើស្រែវស្សាមានចំនួន ៣.៥០០ហិកតា ដីធ្វើស្រែប្រាំងមានចំនួន ៣.០០០ហិកតា និងផ្ទៃដីផ្សេងៗទៀតមានចំនួន ១.៧២៧,៤១ហិកតា។ ក្រុងនេះមានគ្រួសារសរុបចំនួនប្រមាណ ៩.៥៧១គ្រួសារ និងមានប្រជាជនសរុបប្រមាណ ៤៥.២៥១នាក់ ស្រីប្រមាណ ២៣.៤៦៤នាក់ អាយុ១៨ឆ្នាំឡើងសរុបប្រមាណ ២៩.៨៩៥នាក់ ស្រីប្រមាណ ១៥.៤៤២នាក់ ដង់ស៊ីតេប្រជាជន ៤៧៨នាក់ក្នុងមួយម៉ែត្រក្រឡា។[៤]

[២] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី១

[៣] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី៩

[៤] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី៤

#### ១.១.២.២. ជីវភាពប្រជាជន

យោងតាមប្រភពទិន្នន័យនៃភាពក្រីក្រឆ្នាំ២០២០ អាត្រាភាពក្រីក្រចុះមកត្រឹម១២% យោងតាមសូចនាករក្នុងក្រុងដូនកែវចំពោះជីវភាពរបស់ប្រជាពលរដ្ឋកាន់តែមានភាពល្អប្រសើរឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ដោយក្រុងដូនកែវ ជាក្រុងតែមួយគត់នៃខេត្តតាកែវ ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងក្រុង ដោយប្រកបមុខរបររកស៊ីចិញ្ចឹមជីវិតទៅតាមប្រភេទផ្សេងៗគ្នាដែលមានដូចជាវិស័យឧស្សាហកម្ម និងវិស័យកសិកម្មជាដើម ដែលជាមូលដ្ឋានបង្កើនសេដ្ឋកិច្ចគ្រួសារ និងជួយបង្កើនដល់សេដ្ឋកិច្ចឱ្យកាន់មានភាពរីកចម្រើនផងដែរ។

តួយ៉ាងវិស័យឧស្សាហកម្ម និងវិស័យកសិកម្ម បានចូលរួមចំណែកក្នុងការអភិវឌ្ឍមានដូចជាៈ

**ក. វិស័យឧស្សាហកម្ម**

ក្នុងក្រុងដូនកែវ មានរោងចក្រចំនួន ០៨កន្លែង ដែលមានកម្មករបម្រើការងារសរុបចំនួន ៣.១៦៧នាក់ ក្នុងនោះស្រីចំនួន ២.៩១៣នាក់ និងមានសិប្បកម្មសរុបមាន ៨៩មូលដ្ឋានដែលជាកត្តារួមចំណែកលើកកម្ពស់សេដ្ឋកិច្ចប្រជាពលរដ្ឋក្នុងក្រុង និងបានស្រូបយកកម្លាំងការងារចំនួន ៦១៧នាក់។ ពាក់ព័ន្ធសិប្បកម្មផលិតចំណីអាហារនៅក្រុងដូនកែវទាមទារ និងចាំបាច់ឱ្យមានការត្រួតពិនិត្យកម្រិតខ្ពស់នូវ អនាម័យ គុណភាពពីអង្គការដែលមានសមត្ថកិច្ចដើម្បីធានាដល់ការប្រើប្រាស់ដែលគ្មានផលប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ។

**ខ. វិស័យកសិកម្ម**

ក្រុងដូនកែវ ជាទីប្រជុំជនដែលមានផ្ទៃដីសរុប ៩.៤៦៩,២២ហិកតា ក្នុងនោះផ្ទៃដីធ្វើស្រែវស្សាមានចំនួន ៣.៥០០ហិកតា ដីស្រែប្រាំងមានចំនួន ៣.០០០ហិកតា ដីចំការមានចំនួន ១៨២,២២ហិកតា ផ្ទៃដីផ្សេងៗទៀតមានចំនួនសរុប ២.៧៨៧ហិកតា។ ប្រជាពលរដ្ឋប្រកបរបរកសិកម្មស្មើ ៥០.១៩% គ្រួសារចិញ្ចឹមគោស្មើ ២៣% ចិញ្ចឹមមាន់ស្មើ ៥៨.៣៨% ប្រកបមុខរបរផ្នែកសេវាកម្មស្មើ ៤៧.៣៩%។[៥]

## ១.២. សមត្ថកិច្ចពាក់ព័ន្ធក្នុងការរៀបចំក្រុងដូនកែវ

### ១.២.១. សមាសភាព

សមត្ថកិច្ចសំខាន់ៗដែលពាក់ព័ន្ធការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាព របៀបរៀបរយគឺរដ្ឋបាលក្រុងដែលក្នុងនោះមានក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងរួមជាមួយមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។ ដោយយោង

[៥] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី៤

តាមអនុក្រឹត្យលេខ ១៨២ អនក្រ.កប ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីមុខងារ និងបានកំណត់រចនាសម្ព័ន្ធរដ្ឋបាលក្រុងដូចខាងក្រោម៖




### ១.២.១.១. ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាក្រុងត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោត ឱ្យស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ក្រុមប្រឹក្សាក្រុង គឺជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[៦] ក្រុមប្រឹក្សាក្រុងមានអាណត្តិ (ប្រាំ) ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ជាក់ស្តែងសមាជិកក្រុមប្រឹក្សាក្រុងដូនកែវសម្រាប់អាណត្តិទី៣ មានចំនួន ១៧នាក់ ក្នុងនោះមាន ០១រូប ជាប្រធានក្រុមប្រឹក្សា និង១៦រូប ជាសមាជិកក្រុមប្រឹក្សា។[៧]

---

[៦] អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦១

[៧] អនុក្រឹត្យ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣, លេខ ២២ អនក្រ.បក, ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩, មាត្រា២

យោងតាមអនុក្រឹត្យលេខ ២១៦ អនប្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា ៧៥ នៅក្នុងកថាខណ្ឌទី១ គឺក្រុមប្រឹក្សាក្រុង ត្រូវបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី (៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលរួមមាន៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

**ក. កិច្ចប្រជុំក្រុមប្រឹក្សាក្រុង**

កិច្ចប្រជុំក្រុមប្រឹក្សាមានពីរ គឺកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។ កិច្ចប្រជុំក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬលើកលែងតែរបៀបវារៈនៃកិច្ចប្រជុំរបស់ខ្លួនបានតម្រូវឱ្យពិភាក្សាជាសម្ងាត់ប៉ុណ្ណោះ។ ក្រុមប្រឹក្សា ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញរបស់ខ្លួនឱ្យបានទៀងទាត់យ៉ាងហោចណាស់ចំនួន ១២ដងក្នុងមួយឆ្នាំទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញរបស់ខ្លួនបានទៅតាមការចាំបាច់ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ។ តាមការស្នើរបស់ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សា ១/៣ នៃចំនួនក្រុមប្រឹក្សាទាំងមូលដោយអភិបាល ឬគណៈអភិបាល។

ដោយយោងតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា ៦៧ កថាខណ្ឌទី១ គឺកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដែលអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

**ខ. សិទ្ធិអំណាចក្រុមប្រឹក្សាក្រុង**

ដោយយោងតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, មាត្រា ៦៦ ក្រុមប្រឹក្សាក្រុង មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈដីការបស់ខ្លួន និងប្រើប្រាស់អំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចនានា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ហើយត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តន៍ដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។

ដោយយោងតាមអនុក្រឹត្យលេខ ២១៦ ដដែលនេះ មាត្រា ៧២ កថាខណ្ឌទី១ ក្រុមប្រឹក្សាក្រុងត្រូវបាន ប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

### ១.២.១.២. គណៈអភិបាលក្រុង

សាលាក្រុងនីមួយៗត្រូវតែមានគណៈអភិបាលក្រុង ដែលនៅក្នុងនោះរួមមានអភិបាលក្រុងចំនួន ០១រូប និងអភិបាលរងក្រុងមួយចំនួនដែលត្រូវបានតែងតាំងឡើងដោយសមស្របទៅតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[៩] ជាក់ស្តែងអភិបាលនៃគណៈអភិបាលក្រុងដូនកែវមានចំនួន ០៦រូប ក្នុងនោះមានចំនួន ០១រូបជាអភិបាលក្រុង និងចំនួន ០៥រូបជាអភិបាលរងក្រុង។ ដោយអភិបាលក្រុង និងអភិបាលរងក្រុងមិនមែនជាក្រុមប្រឹក្សាក្រុងឡើយ។

- **កិច្ចប្រជុំគណៈអភិបាលក្រុង**

កិច្ចប្រជុំរវាងអភិបាល និងអភិបាលរងនៅក្នុងគណៈអភិបាលរបស់ខ្លួន។ គណៈអភិបាលត្រូវជួបប្រជុំគ្នា ជាទៀងទាត់ប្រចាំអឌ្ឍមាស។ ក្រៅពីប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែ គណៈអភិបាលជួបប្រជុំតាមការ ចាំបាច់ទៅតាមសំណើរបស់អភិបាល។ កិច្ចប្រជុំអាចដំណើរការទៅបានលុះត្រាតែសំឡេងអភិបាល អភិបាលរង បានលើសពាក់កណ្តាលនៃសមាសភាពគណៈអភិបាលទាំងមូល។ សេចក្តីសម្រេចនៃកិច្ចប្រជុំគណៈអភិបាល ដែលអាចយកជាការបាន គឺលុះត្រាតែសំឡេងអនុម័តបានលើសពីពាក់កណ្តាលនៃចំនួនសមាសភាពរបស់ គណៈអភិបាលទាំងមូលប៉ុន្តែប្រសិនបើនៅក្នុងករណីមានចំនួនសំឡេងស្មើគ្នា គឺត្រូវយកសំឡេងអធិបតីរបស់ អង្គប្រជុំមានឧត្តមានុភាព។

អភិបាល គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ ក្នុងករណីអភិបាលអវត្តមាន អភិបាលស្តីទីជាអ្នក កោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំហើយគ្រប់កិច្ចប្រជុំរបស់គណៈអភិបាលត្រូវតែមានកំណត់ហេតុដែលរៀបចំ ឡើងដោយនាយករដ្ឋបាល និងត្រូវមានហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

[៩] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨២

### ១.២.២. តួនាទី និងភារកិច្ច

ជាការពិតមុខតំណែងនីមួយៗគឺជាតួនាទី និងភារកិច្ចដែលត្រូវបានបែងចែកដើម្បីបម្រើជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងដំណើរការនៃការងារកុំឱ្យមានបញ្ហាកកស្ទះហើយដើម្បីរៀបចំទីក្រុងមួយបានទាល់តែមានការចូលរួមចាត់ចែងពីរដ្ឋបាលក្រុងនីមួយៗផងដែរ។

#### ១.២.២.១. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង

តួនាទី និងភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាក្រុងមានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលក្រុងលើកំណត់ហេតុ និងឯកសារមួយចំនួនដូចជា៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាក្រុង កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាក្រុង
- សំណើដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាក្រុងតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្រុមប្រឹក្សាក្រុង ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែងដោយផ្អែកតាមករណីមួយចំនួនដូចជា៖
  - បាត់បង់លក្ខណៈសម្បត្តិជាអភិបាល ឬអភិបាលរង
  - អសមត្ថភាព
  - បំពេញការងារមិនបានល្អ
  - មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
  - បោះបង់ចោលការងារ
  - និងប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាក្រុង និងប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងរយៈពេលដប់ពីរ (១២)ខែ សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[៩]

---

[៩] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦៩ កថាខណ្ឌទី១

### ក. ចំពោះភារកិច្ចរបស់ក្រុមប្រឹក្សាក្រុងក្នុងការកសាងផែនការអភិវឌ្ឍន៍ក្រុង

ណែនាំផ្នែកគោលនយោបាយសម្រាប់កសាងផែនការអភិវឌ្ឍន៍ក្រុង ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង។ តាមដាន និងវាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ក្រុង តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុង ពិនិត្យ និងអនុម័តសំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុង នៅក្នុងករណីចាំបាច់។[១០]

### ខ. របៀបរបបការងារ និងការប្រើប្រាស់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាក្រុងត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តន៍ដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។ ក្រុមប្រឹក្សាក្រុង អាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ នៅក្នុងករណីនេះ គណៈអភិបាលក្រុងត្រូវដឹកនាំដោយនាយករដ្ឋបាលសាលាក្រុង និងការិយាល័យពាក់ព័ន្ធនៃសាលាក្រុងដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬដល់អនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

ក្រុមប្រឹក្សាក្រុងត្រូវឱ្យគណៈអភិបាលចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយដែលក្នុងក្រុមប្រឹក្សាក្រុងបានអនុម័តរួចព្រមទាំងចាត់ចែងអនុវត្តន៍ឱ្យមានប្រសិទ្ធិភាព។ ករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួនហើយដែលកិច្ចការនោះ ច្បាប់គ្រប់គ្រង ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទ និងនីតិវិធីក្នុងការប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួនក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាពដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានា ធ្វើការបញ្ជាក់នូវបែបបទនីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ។ ក្នុងករណីកិច្ចការណាមួយដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែង

---

[១០] សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង, ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧, ទំព័រទី២

មិនច្បាស់លាស់ ឬមិនសមស្រប និងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួនហើយដែលក្រុមប្រឹក្សាក្រុងមិនអាចអនុវត្តន៍បាន ក្រុមប្រឹក្សាក្រុងត្រូវចាត់តាំងឱ្យគណៈអភិបាលក្រុងធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្អែកតាមយន្តការនៃ គ.ជ.អ.ប. អាចធ្វើការសម្របសម្រួលជាមួយនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។[១១]

ក្រុមប្រឹក្សាខេត្ត ត្រូវមានតួនាទីក្នុងការប្រតិភូកម្មអំណាចក្នុងនាមជាអ្នកតំណាងរាជរដ្ឋាភិបាលដើម្បីផ្តល់នូវការគាំទ្រ និងត្រួតពិនិត្យនីត្យានុកូលភាពទៅលើសេចក្តីសម្រេចនឹងសកម្មភាពរបស់រដ្ឋបាលក្រុងដើម្បីធានាថារដ្ឋបាលក្រុងបានបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងស្របតាមគោលនយោបាយរបស់ជាតិ។ ការធ្វើប្រតិភូកម្មនេះរួមមានដូចខាងក្រោមៈ

- ការវាយតម្លៃ និងរៀបចំយុទ្ធសាស្ត្រសមស្របផ្តល់ការគាំទ្រខាងសមត្ថភាពដល់ក្រុមប្រឹក្សាក្រុងព្រមទាំងចាំបាច់មន្ត្រីបុគ្គលិកនៃក្រុមប្រឹក្សាទាំងអស់។
- ការណែនាំ និងសម្របសម្រួល គាំទ្រដល់ក្រុមប្រឹក្សាក្រុងក្នុងការអនុវត្តការងារ ភារកិច្ច និងធនធានដែលបានប្រគល់ឱ្យស្របទៅតាមច្បាប់ លិខិបទដ្ឋានគតិយុត្ត និងគោលនយោបាយរបស់ជាតិ និងត្រូវធានាថាអភិបាលក្រុងបានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់សង្កាត់នៅក្នុងក្រុង។

ក្រុមប្រឹក្សាខេត្តត្រូវបំពេញតួនាទីខាងលើនេះ លើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ក្រុង និងសង្កាត់ឱ្យស្របតាមគោលការណ៍នៃច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យនេះ លិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេចរបស់ គ.ជ.អ.ប.។ ក្រុមប្រឹក្សាខេត្ត ត្រូវធ្វើប្រតិភូកម្មអំពីការគាំទ្រ និងការត្រួតពិនិត្យនីត្យានុកូលភាពនេះដល់គណៈអភិបាលខេត្តដើម្បីអនុវត្តន៍កិច្ចការប្រចាំថ្ងៃ ហើយការអនុវត្តការងារប្រចាំថ្ងៃគណៈអភិបាលជាខ្សែរយៈទំនាក់ទំនងទៅវិញទៅមករវាងរដ្ឋាភិបាល ក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាលជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ព្រមទាំងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងខេត្ត។ គណៈអភិបាលត្រូវស្នើសុំគោលការណ៍ណែនាំ និងធ្វើសេចក្តីរាយការណ៍អំពីការអនុវត្តតួនាទី ភារកិច្ចខាងលើនេះរាល់កិច្ចប្រជុំសាមញ្ញនៃក្រុមប្រឹក្សារបស់ខ្លួន ហើយនៅក្នុងករណីចាំបាច់ ក្រុមប្រឹក្សាខេត្ត អាចកោះប្រជុំវិសាមញ្ញដើម្បីពិនិត្យពិភាក្សាអំពីការគាំទ្រការធ្វើប្រតិភូកម្មខាង

[១១] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦៦, មាត្រា៦៨ កថាខណ្ឌទី១ កថាខណ្ឌទី៤ មាត្រា៧២ កថាខណ្ឌទី២ កថាខណ្ឌទី៣

លើនេះ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃដោយផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប. និងត្រូវចេញប្រកាសដើម្បីកំណត់អំពីគោលការណ៍ និងនីតិវិធីនានាពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មនេះ។[១២]

### គ. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុងមានពីរប្រភេទគឺ កិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាក្រុងអាចប្រជុំសាមញ្ញយ៉ាងហោចណាស់ ១២/១ឆ្នាំ និងប្រជុំវិសាមញ្ញ ក្រុមប្រឹក្សាក្រុង អាចប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ។ កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញអាចយកជាការបានលុះត្រាតែកិច្ចប្រជុំទាំងនេះប្រព្រឹត្តទៅត្រឹមត្រូវទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាក្រុង។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាក្រុង ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានាសេចក្តីសម្រេចនោះពុំមានសុពលភាពទេ។ រាល់កិច្ចប្រជុំរបស់ខ្លួនក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍គោលនយោបាយរបស់រដ្ឋបាលក្រុង និងវិធានការបែបបទនៃនីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាក្រុង
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាក្រុងប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន មន្ទីរ ឬការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងជាមួយដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលក្រុង
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធានរួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង

[១២] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៨៦

- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាក្រុង ដើម្បីជួបប្រាស្រ័យទាក់ទងគ្នាជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង រួមទាំងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាសង្កាត់ និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។[១៣]

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាក្រុង ត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំដែលបានរៀបរាប់ខាងលើនេះ ក្រុមប្រឹក្សាក្រុងអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន៖

- ការកោះអញ្ជើញអភិបាលក្រុង ឬអភិបាលរងក្រុង ឬគណៈអភិបាលក្រុងទាំងមូល ឬបុគ្គលដែលពាក់ព័ន្ធទាំងមូលមកសាកសួរអំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ឬហេតុការណ៍ណាមួយដែលកើតមានក្នុងក្រុង ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវ ឬស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងការសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើការអង្កេតនេះព្រមទាំងណែនាំដល់គណៈអភិបាលក្រុងអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការអង្កេតនោះ
- ការធ្វើប្រតិភូកម្មមុខងារភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- ការពិនិត្យស្រាវជ្រាវ និងធ្វើសេចក្ដីរាយការណ៍ទៅក្រសួងមហាផ្ទៃក្នុងករណីដូចជា៖
    - ក្នុងករណីដែលមានការរំលោភអំណាចកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាត្រូវរាយការណ៍លាយលក្ខណ៍អក្សរជាបន្ទាន់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
    - ក្នុងករណីការប្រើប្រាស់តួនាទី ឬអំណាចរបស់ខ្លួន ដើម្បីកេងប្រវ័ញ្ច ឬធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬក្រុមមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធានសាធារណៈណាមួយ

[១៣] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៧០

- ក្នុងករណីការមិនបានប្រើប្រាស់តួនាទី ឬអំណាចរបស់ខ្លួនដើម្បីទប់ស្កាត់ជនម្នាក់ទៀតដែលស្ថិតនៅក្រោមអំណាច ឬការត្រួតពិនិត្យរបស់ខ្លួន នៅពេលដែលខ្លួនបានដឹងអំពីកំហុសឆ្គងរបស់ជននោះដែលបានកេងប្រវ័ញ្ច ឬធ្វើទុក្ខបុកម្នេញដល់បុគ្គលណាម្នាក់ ឬក្រុមមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬធនធានសាធារណៈ
- ការរំលោភសិទ្ធិស្របច្បាប់ ឬសិទ្ធិមនុស្សរបស់ជនណាម្នាក់
- ការកាន់កាប់ ឬការរឹបអូសទ្រព្យសម្បត្តិសាធារណៈ ឬទ្រព្យសម្បត្តិឯកជន និងធនធានធម្មជាតិមកធ្វើជារបស់ខ្លួនដោយខុសច្បាប់
- ការធ្វើអន្តរាយដល់បរិស្ថានធនធានធម្មជាតិ
- ការដកយកថវិកា ឬទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមិនត្រឹមត្រូវ ការស្នើសុំ ឬការទទួលប្រាក់ ឬរង្វាន់អ្វីមួយជាថ្នូរនឹងការធ្វើ ឬមិនធ្វើកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការរបស់ជននោះ ហើយដែលការចំណាយ ឬរង្វាន់នោះមិនបានកំណត់នៅក្នុងច្បាប់
- ភាពមិនប្រក្រតីនៅក្នុងការអនុវត្តច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬប្រកាស ភាពមិនប្រក្រតីនៅក្នុងការអនុវត្តដីការបស់ក្រុមប្រឹក្សា
- ការធ្វើសេចក្តីសម្រេច នៅក្នុងវិសាលភាពនៃភារកិច្ចផ្លូវការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍គ្រួសាររបស់ខ្លួន។[១៤]

➢ ពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាក្រុង ឬសមាជិកក្រុមប្រឹក្សាក្រុង ឬគណៈអភិបាលក្រុង ឬអភិបាលរងក្រុង ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង

➢ ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន

➢ ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

➢ ពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ រៀបចំដោយគណៈអភិបាលក្រុង

[១៤] ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨, មាត្រា៤៧-មាត្រា៤៩

- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងយល់ឃើញថាមានការចាំបាច់។[១៥]

### ១.២.២.២. តួនាទី និងភារកិច្ចរបស់គណៈអភិបាលក្រុង

**ក. គណៈអភិបាលក្រុងមានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

គណៈអភិបាលក្រុង ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាក្រុងអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង ដើម្បីក្រុមប្រឹក្សាក្រុងធ្វើការពិភាក្សាអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រុង និងអំពីរបៀបរបបបែបបទនីតិវិធីនៃការអនុវត្តមុខងារភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្រ្ត និងការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥) ឆ្នាំ និងកម្មវិធីវិនិយោគបី (៣) ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុង
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការកំណត់យុទ្ធសាស្រ្ត ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាក្រុង ពិនិត្យ និងអនុម័ត មិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង៖
  - ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាក្រុង និងសកម្មភាពលទ្ធផលនៃការអនុវត្ត

[១៥] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៧១

- របាយការណ៍ហិរញ្ញវត្ថុ
- ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលក្រុង និងបុគ្គលិក
- វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
- វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
- កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាចាំបាច់ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

➢ របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស

➢ ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជនដូចជាការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់ ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ច និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់ និងកិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាក្រុងរបស់ខ្លួន។[១៦]

**ខ. គណៈអភិបាលក្រុងក្នុងតួនាទី ជាតំណាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល**

នៅក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងក្រុង អភិបាលក្រុងមានភារកិច្ចដូចខាងក្រោម៖

➢ ណែនាំដល់ការិយាល័យអង្គភាព ទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅក្រុង ឱ្យអនុវត្តន៍តួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ ហើយសម្របសម្រួលទិសដៅដល់ការិយាល័យអង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងក្រុង ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលក្រុងត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាពទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា

[១៦] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨៦

និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការ សម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង អភិបាលក្រុងត្រូវសម្របសម្រួល តម្រង់ទិសការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងក្រុង ក្នុងការធ្វើសមាហរណកម្ម ផែនការថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង និងពិនិត្យវាយតម្លៃផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់។

- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុងជាមុន ក្នុងការផ្តល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួងស្ថាប័ននានាប្រចាំនៅក្នុងក្រុងរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលក្រុងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ឱ្យច្បាស់លាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនដល់អភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី
- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័ន ដែលប្រចាំនៅក្នុងក្រុងរបស់ខ្លួនផ្ទាល់ ករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលក្រុងត្រូវរាយការណ៍ជាលាយលក្ខណ៍អក្ស និងជាបន្ទាន់ទៅអភិបាលខេត្ត អភិបាលខេត្តត្រូវណែនាំដល់មន្ទីរ អង្គភាពសាមីប្រចាំនៅខេត្ត ដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារដែលមានការចូលរួមពីរដ្ឋបាលក្រុង ដែលពាក់ព័ន្ធឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី អភិបាលក្រុងមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួងស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។[១៧]
- អភិបាលក្រុង ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងក្រុងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងក្រុង។ អភិបាលក្រុង គឺជាប្រធានគណៈបញ្ជាការឯកភាពក្រុង

[១៧] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៩២ កថាខណ្ឌទី១

ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធ និងសង្កាត់ក្នុងក្រុងដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងក្រុង។[១៨]

យោងតាមអនុក្រឹត្យលេខ ២១៦ អនក្រ.បក ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក មាត្រា ៩២ កថាខណ្ឌ ទី២ ដើម្បីធានាឱ្យអភិបាលក្រុងបានធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល និងអនុវត្តន៍នូវភារកិច្ចខាងលើនេះ ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំក្រុង ត្រូវដាក់ជូនអភិបាលក្រុងដើម្បីពិនិត្យ និងផ្តល់យោបល់។ ប្រសិនបើអភិបាលក្រុងឯកភាព អភិបាលក្រុង ត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយនឹងប្រធានការិយាល័យអង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ សេចក្តីរាយការណ៍ក្រៅពីនោះរបស់ការិយាល័យអង្គភាព និងទីភ្នាក់ងារនានារបស់ក្រុងស្ថាប័នដែលប្រចាំនៅក្នុងក្រុងត្រូវចម្លងជូនសាលាក្រុង។

### គ. របៀបរបបការងារនៃគណៈអភិបាលក្រុង

នៅក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន គណៈអភិបាលក្រុង អភិបាលក្រុង ឬអភិបាលរងក្រុងត្រូវពិនិត្យនូវចំណុចមួយចំនួន ដែលបានពាក់ព័ន្ធនឹងរបៀបរបបក្នុងការអនុវត្តការងារមានដូចខាងក្រោម៖

- នៅក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ស្ថាប័ននានាស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា
- នៅក្នុងការអនុវត្តតួនាទី ភារកិច្ច និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាជាចាំបាច់ អភិបាលក្រុង ត្រូវយកការងារទាំងនោះមកពិគ្រោះក្នុងគណៈអភិបាលក្រុងរបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន
- អភិបាលក្រុង ត្រូវទទួលខុសត្រូវចំពោះមុខនៃក្រុមប្រឹក្សាក្រុងអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន ហើយអភិបាលរងក្រុងត្រូវទទួលខុសត្រូវចំពោះអភិបាលក្រុងលើភារកិច្ចនានា

[១៨] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៩៣

ដែលអភិបាលក្រុងបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលក្រុងទទួលខុសត្រូវអំពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន

- ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលក្រុងត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស និងការប្រជុំអឌ្ឍមាសទី២ នៃខែនីមួយៗជាការប្រជុំប្រចាំខែ។ ក្រៅពីប្រជុំប្រចាំអឌ្ឍមាស គណៈអភិបាលក្រុងអាចកោះប្រជុំតាមការចាំបាច់វៀងរាល់កិច្ចប្រជុំខាងលើ និងការប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុឱ្យបានច្បាស់លាស់
- គណៈអភិបាលក្រុង ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលក្រុង និងអភិបាលរងក្រុង ដើម្បីសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួនហើយអភិបាលក្រុងត្រូវទទួលបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន
- អភិបាលក្រុង ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តន៍សេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួនលើកលែងតែលិខិតបទដ្ឋានគតិយុត្តដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខា។ អភិបាលក្រុង អាចប្រគល់សិទ្ធិដល់អភិបាលរងក្រុងក្នុងការចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួនក្នុងក្របខណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងក្រុងនីមួយៗ។ អភិបាលក្រុងត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារលិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុង
- អភិបាលក្រុង មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងក្រុងណាមួយដែលបានប្រើប្រាស់អំណាចមិនស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធីហើយការប្រគល់ សិទ្ធិក្នុងការចុះហត្ថលេខានេះអភិបាលក្រុងត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។ ក្នុងករណីអភិបាលក្រុងអវត្តមាន អភិបាលក្រុងត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលក្រុងស្តីទី។ ប្រសិនបើអភិបាលក្រុងអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងក្រុង ស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលក្រុងត្រូវធ្វើជាអភិបាលក្រុងស្តីទី
- ក្នុងករណីអភិបាលក្រុងស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលក្រុងស្តីទី និងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលក្រុងស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តន៍ជូនអភិបាលក្រុង នៅពេលអភិបាលក្រុងមានវត្តមានវិញ។ គណៈអភិបាលក្រុង អភិបាលក្រុង អភិបាលរងក្រុងដែលបានសម្រេច ឬដែលបានអនុវត្តន៍កិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុងហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុង ការសម្រេចនេះ

ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលក្រុង អភិបាលក្រុង និងអភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ពីការសម្រេច ឬសកម្មភាពខាងលើនេះ។[១៩]

**ឃ. ភារកិច្ចរបស់គណៈអភិបាលក្រុង ក្នុងការកសាងផែនការអភិវឌ្ឍន៍ក្រុង**

ដឹកនាំសម្របសម្រួលការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ស្របតាមការណែនាំរបស់ក្រុមប្រឹក្សាក្រុង ដឹកនាំសិក្ខាសាលាវេទិកាពិគ្រោះយោបល់នានាក្នុងដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង ពិនិត្យផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍មុនដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត ដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង។ ដាក់សំណើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុង ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័តដឹកនាំ និងសម្របសម្រួលការធ្វើវិសោធនកម្មផែនការអភិវឌ្ឍន៍ក្រុង តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ក្រុងតាមការណែនាំរបស់ក្រុមប្រឹក្សា។[២០]

**ង. ទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង**

- អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាក្រុងបានសម្រេចរួចគណៈអភិបាលក្រុង ត្រូវទទួលខុសត្រូវចាត់ចែងអនុវត្តន៍ក្នុងនាមក្រុមប្រឹក្សាក្រុងរបស់ខ្លួន។ ដូច្នេះគណៈអភិបាលក្រុង គឺជាអ្នកអនុវត្តន៍សេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាក្រុង ត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តន៍ដោយគណៈអភិបាលក្រុង ដើម្បីធានាថាគណៈអភិបាលក្រុងអនុវត្តន៍កិច្ចការទាំងនោះ បានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាលើការសម្រេចរបស់ក្រុមប្រឹក្សាក្រុង
- គណៈអភិបាលក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាក្រុង
- គណៈអភិបាលក្រុង ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាក្រុងរបស់ខ្លួន ពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាក្រុង និងមានគណនេយ្យភាពចំពោះរដ្ឋាភិបាល អំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា
- អភិបាលក្រុង ដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវរៀបចំសេចក្តីរាយការណ៍អំពីសកម្មភាព លទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័ននានា

---

[១៩] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨៩-មាត្រា៩៧

[២០] សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង, ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧, ទំព័រទី២

ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួន

- ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលក្រុង ក្នុងនាមតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាក្រុងអាចតម្រូវឱ្យអភិបាលក្រុងធ្វើសេចក្ដីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាក្រុង
- ក្រុមប្រឹក្សាក្រុងអាចផ្ដល់អនុសាសន៍ និងការណែនាំដល់អភិបាលក្រុងអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាព និងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។ អភិបាលក្រុងត្រូវ ទទួលយកអនុសាសន៍ និងការណែនាំពីក្រុមប្រឹក្សាក្រុងរបស់ខ្លួនដើម្បីធ្វើការណែនាំសម្របសម្រួល និងតម្រង់ទិសដល់ការិយាល័យអង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការឆ្លើយតបតម្រូវការទាំងនោះហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួនវិញ។[២១]

## ១.៣. កត្តាដែលនាំឱ្យមានការរៀបចំក្រុងជូនកែទ

ជាការពិតណាស់ នៅក្នុងការរៀបចំក្រុងមួយត្រូវបានធ្វើឡើងជាចាំបាច់ត្រូវការគិតគូរឱ្យបានហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ។ មុនឈានទៅដល់ការរៀបចំក្រុង ឬអភិវឌ្ឍន៍អ្វីមួយមិនមែនកើតឡើងដោយសារតែភាពចៃដន្យនោះទេ គឺវាបណ្ដាលមកពីភាពខ្វះចន្លោះដែលជាហេតុនាំឱ្យកើតមានឡើងនៅបញ្ហាផ្សេងៗ។ ហើយការមានភាពខ្វះចន្លោះ ឬបានលេចឡើងនូវបញ្ហាផ្សេងៗ ឬមានការខ្វះខាតហើយបញ្ហាទាំងអស់នេះជាតម្រូវការឱ្យធ្វើការកែប្រែ និងរៀបចំក្រុងជាចាំបាច់។ យ៉ាងណាមិញយើងក្រឡេកមើលតាមតំបន់នានាដូចជា ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង តែងតែមានការរៀបចំគម្រោង ឬដាក់ផែនការសកម្មភាពអភិវឌ្ឍន៍នៅតាមតំបន់នានាដែលកំពុងជួបនូវបញ្ហាដែលនឹងត្រូវរៀបចំឱ្យមានភាពល្អប្រសើរឡើងជាងមុន។

### ១.៣.១. កំណើនប្រជាជន

ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់ៗ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនក្នុងក្រុង ជាលក្ខណៈធម្មជាតិបានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកកំណើនដោយសារមានចំណាកស្រុកពី

[២១] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៧៣, មាត្រា៨៤, មាត្រា៨៦

ជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកតំបន់នេះ ជាទីជនបទគ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។

ចំនួនប្រជាជនពិភពលោកបានកើនឡើងដល់ចំនួន ៦,១ពាន់លាននាក់ ក្នុងពាក់កណ្ដាលឆ្នាំ២០០០ទៅហើយ ដោយឡែកបច្ចុប្បន្នកំពុងកើនឡើងជាមធ្យមចំនួន ៧,៧លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ខាងមុខចំនួនប្រជាជនពិភពលោកនឹងមានការកើនឡើងខ្លាំងនៅចន្លោះពីចំនួន ៧,៩ ទៅ ១០,៩ពាន់លាននាក់។ បើទោះបីជាមានប្រទេសមួយចំនួនបានលេចចេញនូវអត្រិភាពនៃអត្រាមរណៈភាពខ្ពស់ ដោយសារតែជំងឺអេដស៍ក៏ដោយ ក៏កំណើនប្រជាជននៅតែខ្ពស់ដដែល។ យ៉ាងណាមិញ ចំនួនប្រជាជននៅក្នុងប្រទេសអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះ គឺមិនត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងរយៈពេល៥០ឆ្នាំខាងមុខឡើយ ដោយសារតែកម្រិតនៃការមានកូនត្រូវបានគេដាក់ឱ្យស្ថិតក្រោមកម្រិតកំណត់។ ផ្ទុយទៅវិញ ចំនួនប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានព្យាករណ៍ថានឹងកើនឡើងពី ៤,៩ពាន់លាននាក់នៅក្នុងឆ្នាំ២០០០ និងកើនឡើងដល់ ៨,២ពាន់លាននាក់ក្នុងឆ្នាំ២០៥០។ កំណើនយ៉ាងឆាប់រហ័សនេះ ត្រូវបានគេរំពឹងថានឹងកើតឡើងក្នុងចំណោមក្រុមប្រទេសអភិវឌ្ឍន៍ចំនួន ៤៨ប្រទេស ដែលចំនួនប្រជាជនរបស់ពួកគេត្រូវបានរំពឹងថានឹងកើនឡើងជិតបីដងទៅ៥០ឆ្នាំខាងមុខ។ ចំណែកឯអន្តោប្រវេសន៍អន្តរជាតិ ត្រូវបានគេព្យាករណ៍ថានឹងមានកំណើនដង់ស៊ីតេប្រជាជនខ្ពស់ខ្លាំងនៅក្នុងសតវត្សទី២១នេះ។[២២]

### ១.៣.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកណាស់នៅក្នុងការកំណត់ ប៉ុន្តែជាទូទៅភាពក្រីក្រសំដៅដល់ការដែលជាតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមភាគច្រើនការកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាបដែលគេមិនអាចចាយវាយបានគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ ជាតម្រូវការរូបកាយតាមរយៈចំណីអាហារ លំនៅឋាន ការងារធនធានទឹក អគ្គិសនី អនាម័យ សុខមាលភាពសង្គមមានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម និងនិយាយដោយឡែកសិទ្ធិពលរដ្ឋលើសិទ្ធិនយោបាយក៏នៅតែមានកម្រិតដែរ។ ការសម្គាល់ពីភាពក្រីក្របានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលរូបណាមួយ ព្រោះតែបញ្ហាផ្សេងៗដូចជាចំនួននៃឧក្រិដ្ឋកម្ម អំពើហិង្សា ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះបានឡើយ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេ

[២២] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៩

សន្មត់ថាជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង ២០% ចំនួនប្រជាជនពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយ ៩០% ក្នុងចំនួននេះកំពុងស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[២៣]

➢ **ភាពក្រីក្រនៅជនបទ**

ស្ថិតនៅបរិការណ៍នៃបច្ចុប្បន្នភាព ស្ថានភាពក្រីក្រនៃប្រទេសកំពុងអភិវឌ្ឍន៍ មានការកើនឡើងជាលំដាប់ កំណើននេះអាស្រ័យដោយស្ថានភាពសេដ្ឋកិច្ចសង្គម ប្រជារាស្ត្រ ភូមិសាស្ត្រនយោបាយ គ្រោះធម្មជាតិការប្រែប្រួលអាកាសធាតុ និងកង្វះដីបង្កបង្កើនផលជាដើម។ ភាពក្រីក្រនៅជនបទនាំឱ្យមានចំណាកស្រុកទៅទីក្រុង ហើយចរន្តការនេះនឹងកើនឡើងនៅពេលដែលស្ថានភាពនៅតំបន់កាន់តែលំបាក។ ដូច្នេះការបង្កើនសកម្មភាពសេដ្ឋកិច្ចនៅជនបទជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធិភាពជាទីបំផុតដើម្បីគ្រប់គ្រងការធ្វើចំណាកស្រុកនេះ។

➢ **ភាពក្រីក្រនៅទីក្រុង**

កាលណាមានភាពក្រីក្រនៅក្នុងទីក្រុង គឺពិតជាមានបង្កផលពិបាកយ៉ាងខ្លាំង។ ជាទូទៅយើងពុំមាននូវលក្ខណៈសមភាពទេ កាលណាប្រសិនជាយើងធ្វើការប្រៀបធៀបពីភាពក្រីក្រ ដោយការដាក់បន្ទាត់មួយក្រឹតឱ្យស្មើគ្នានោះ។ ឧទាហរណ៍ ការប្រើប្រាស់ថវិកា៣លានដុល្លារសហរដ្ឋអាមេរិកដូចគ្នា តែបុគ្គលម្នាក់នោះនៅជនបទចំណែកបុគ្គលម្នាក់ទៀតនៅទីក្រុងមិនអាចស្មើគ្នាទេនៅក្នុងការចំណាយលុយ។ មូលហេតុ គឺដោយសារនៅក្នុងទីក្រុងមានការចំណាយខ្ពស់ជាងជនបទដាច់ឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះ អ្នករស់នៅតាមជនបទអាចមានឱកាសស្វែងរកការចិញ្ចឹមជីវិត តាមរយៈការទទួលអំណោយភោគផលពីធម្មជាតិច្រើនជាងអ្នកនៅក្នុងទីក្រុង។ ជារួមប្រសិនបើមានភាពក្រីក្រនៅក្នុងទីក្រុងហើយ អាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវតែបង្កើតឱ្យមានសេវាកម្មគ្រប់វិស័យដើម្បីទាក់ទាញឱ្យអ្នកវិនិយោគនានា បង្កើតគ្រឹះស្ថាន រោងចក្រ សហគ្រាស ឬសេវាកម្មផ្សេងៗនៅក្នុងទីក្រុងដើម្បីឱ្យប្រជាពលរដ្ឋនៅក្នុងទីក្រុងមានការងារធ្វើហើយក៏បានជួយដល់ប្រជាជនដែលរស់នៅទីជនបទកំពុងជួបនូវភាពក្រីក្រខ្វះខាតនូវការងារធ្វើបានទទួលនូវការងារធ្វើផងដែរ។ ដូច្នេះភាពក្រីក្រនេះក៏ជា មូលហេតុមួយដែលនាំឱ្យមានការរៀបចំក្រុង។

កត្តានៃភាពក្រីក្រនេះ ក៏ជាកត្តាធ្វើឱ្យកើតមានឡើងនូវបញ្ហាផ្សេងៗដែលបង្កភាពប៉ះពាល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយផងដែរ។ នេះក៏ដោយសារកត្តាជីវភាពក្រីក្រប្រជាពលរដ្ឋភាគច្រើនគ្មានទីលំនៅសម្រាប់រស់នៅឱ្យបានសមរម្យធ្វើឱ្យអ្នកខ្លះត្រូវដេក ឬសម្រាកតាមចិញ្ចើមផ្លូវ និងសួនច្បារជាដើម។ម្យ៉ាងទៀតដោយតែការខ្វះខាតអាហារហូបចុកមិនបានគ្រប់គ្រាន់ ប្រជាពលរដ្ឋមួយចំនួនក៏ត្រូវដើរសុំទានដើម្បីបំពេញតម្រូវការក្រពះ។

[២៣] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១៩

បញ្ហាទាំងអស់នេះហើយ បានបង្កភាពប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ដែលជាហេតុធ្វើឱ្យអាជ្ញាធរក្រុង ត្រូវយកចិត្តទុកដាក់ស្វែងរកដំណោះស្រាយ និងរៀបចំធ្វើយ៉ាងណាឱ្យមានភាពកាន់តែល្អប្រសើរ។

### ១.៣.៣. ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធវិស័យបរិស្ថាន គឺកង្វះដីសម្រាប់បង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើនក្នុងករណីដែលដីរបស់ពួកគេទទួលបានពីដូនតា ឪពុកម្តាយ របស់ខ្លួនត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីនៅសល់មានទំហំតូចមិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងឡើយហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីជាតិទៀត។

ប្រសិនបើក្រឡេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាកង្វះប្រព័ន្ធធារាសាស្ត្រទឹកស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលឱ្យបានគ្រប់គ្រាន់។ ករណីនេះច្រើនកើតមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់មេគង្គក្រោម។[២៤] បញ្ហាខាងលើនេះបណ្តាលឱ្យមានការធ្វើចំណាកស្រុកទៅកាន់ទីក្រុង។

### ១.៣.៤. គមនាគមន៍ និងចរាចរណ៍

គមនាគមន៍ គឺជាកត្តាសំខាន់មួយផងដែរ ដែលជំរុញឱ្យមានការរៀបចំក្រុង។ ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយរបស់ក្រុងក៏អាស្រ័យទៅលើកត្តាផ្លូវថ្នល់ផងដែរ។ ការរីកចម្រើនផ្នែកកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការរីកចម្រើនខាងផ្នែកគមនាគមន៍ ទាំងផ្លូវថ្នល់ ផ្លូវទឹក និងផ្លូវដែកដែលសុទ្ធសឹងតែជាសសៃឈាមនៃសេដ្ឋកិច្ច។

គមនាគមន៍ គឺជាលក្ខណៈវិនិច្ឆ័យសំខាន់មួយឱ្យយើងដឹងពីការអភិវឌ្ឍរបស់ក្រុងណាមួយ ឬប្រទេសណាមួយ។ កាលណាក្រុងមានការរីកចម្រើនផ្នែកគមនាគន៍មានផ្លូវថ្នល់ខ្វាត់ខ្វែងដែលអាចសម្រួលដល់ការដឹកជញ្ជូន និងការធ្វើដំណើរផ្សេងៗទៀតបានយ៉ាងល្អប្រសើរ ដោយគ្មានការកកស្ទះ ឬជួបនូវបញ្ហាផ្សេងៗនោះនឹងធ្វើឱ្យក្រុងនោះមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អប្រសើរព្រមទាំងជំរុញឱ្យសេដ្ឋកិច្ចរបស់ក្រុង និងប្រទេសនោះមានការរីកចម្រើនផងដែរ។ ផ្ទុយទៅវិញប្រសិនបើក្រុង ឬប្រទេសមួយខ្វះខាតនូវគមនាគមន៍ និងបង្កឱ្យមានការកកស្ទះរាំងស្ទះដល់ការដឹកជញ្ជូន ឬការធ្វើដំណើរផ្សេងៗហើយនាំឱ្យបាត់បង់សោភ័ណភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយព្រមទាំងជាឧបសគ្គដល់ការរីកចម្រើននៃសេដ្ឋកិច្ចផងដែរ។

[២៤] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី២០

- **ចរាចរណ៍** បញ្ហាចរាចរណ៍ គឺជាកត្តាមួយដែលនាំឱ្យមានការរៀបចំក្រុង និងនាំឱ្យប្រទេសជាតិមានការអភិវឌ្ឍជឿនលឿនទៅមុខជាលំដាប់ផងដែរ។ កាលណាប្រទេសមួយមាននូវបញ្ហាកកស្ទះចរាចរណ៍នៅក្នុងទីក្រុងហើយពិតណាស់វានាំឱ្យមានគុណវិបត្តិ សម្រាប់ប្រជាពលរដ្ឋដូចជាខាតបង់សេដ្ឋកិច្ចបានប៉ះពាល់សុខភាព មិនគោរពច្បាប់ចរាចរណ៍ថែមទាំងមានផលប៉ះពាល់ទៅដល់បរិស្ថាន តាមរយៈផ្សែងបំពង់ស៊ីម៉ាំងរថយន្ត រថយន្តក្រុង រថយន្តដឹកទំនិញផ្សេងៗ។ មិនតែប៉ុណ្ណោះនៅពេលដែលមានការកកស្ទះចរាចរណ៍នោះ ម៉ូតូ និងរថយន្ត គឺម៉ាស៊ីនមានការបញ្ចេះរហូតដោយមិនអាចពន្លត់បាន។ ជាក់ស្តែងបញ្ហាកកស្ទះចរាចរណ៍នៅក្នុងទីក្រុង គឺបានកើតចេញមកពីកត្តាបីយ៉ាងគឺៈ
- **កត្តាមនុស្ស** មនុស្សកើនឡើងច្រើន មនុស្សប្រើប្រាស់មធ្យោបាយធ្វើដំណើរតាមដងផ្លូវរៀងៗខ្លួនដែលបណ្តាលឱ្យមានបញ្ហាដូចជាការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ ហើយគ្រោះថ្នាក់ចរាចរណ៍របស់មនុស្សទៀតសោត គឺកើតចេញពីការមិនគោរពច្បាប់ មិនគោរពភ្លើងសញ្ញា ស្លាកសញ្ញា ដោយបើកបរមិនចេះយោគយល់ និងអធ្យាស្រ័យគ្នាទៅវិញទៅមកជាដើម។
- **កត្តាយានយន្ត** នៅក្នុងប្រទេសកម្ពុជាសម្បូរដោយយានយន្តមួយទឹកៗមកពីក្រៅប្រទេសលក់សម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ជាមធ្យោបាយធ្វើដំណើរក៏ជាហេតុនាំឱ្យមានផលប៉ះពាល់ដល់បរិស្ថានយ៉ាងខ្លាំងផងដែរ។
- **កត្តាផ្លូវ** មិនទាន់ឆ្លើយតបទៅតាមតម្រូវការ (ទីរួមខេត្ត និងក្រុង) ផ្លូវពុំមានស្តង់ដា (មានលក្ខណៈតូច ផ្លូវជួសជុលច្រើនដងមិនមានផ្លូវអាកាស និងមិនមានស្ពានសម្រាប់អ្នកថ្មើរជើង)។[២៥]

ជាក់ស្តែងនៅក្នុងឆ្នាំ២០១៧ មានរថយន្តគ្រប់ប្រភេទសរុបចំនួន ៤៤២.៩៧១គ្រឿង និងទោចក្រយានយន្តគ្រប់ប្រភេទមានចំនួន ១.៦០១.៤៥១គ្រឿង និងប្រជាពលរដ្ឋមានរហូតដល់ចំនួន ១៧លាននាក់។ ក្រៅពីបញ្ហាការកើនឡើងនៃយានយន្ត និងហេដ្ឋារចនាសម្ព័ន្ធផ្លូវក៏មានបញ្ហាចោទដែលនាំឱ្យមានការកកស្ទះចរាចរណ៍ផងដែរ។ ដោយសារផ្លូវក្នុងក្រុងមានភាពទ្រុឌទ្រោម និងតូចចង្អៀតពិបាកធ្វើដំណើរ មានការប្រេះស្រាំ ខ្វះការថែទាំរថយន្តដឹកទំនិញលើសទម្ងន់យកផ្លូវថ្នល់ជាចំណត ប្រជាពលរដ្ឋខ្វះការយល់ដឹងពីការអនុវត្តច្បាប់ចរាចរណ៍ និងមានការខ្វះខាតនូវផ្លូវបំភ្លឺគ្រប់ផ្លូវ និងច្រកផ្លូវជាច្រើន។ ដូច្នេះហើយ កត្តាទាំងអស់នេះជាហេតុនាំឱ្យមានការរៀបចំក្រុងដើម្បីជាភាពងាយស្រួលដល់ប្រជាពលរដ្ឋជាពិសេសភ្ញៀវទេសចរជាតិ និងអន្តរជាតិផងដែរ។

[២៥] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី៥៤

# ជំពូកទី២

# ការរៀបចំសោភ័ណភាព និង សណ្តាប់ធ្នាប់នៅក្នុងក្រុងដូនកែវ ខេត្តតាកែវ

# ជំពូកទី២

# ការរៀបចំសោភ័ណភាព និងសណ្តាប់ធ្នាប់ នៅក្នុងក្រុងដូនកែវ ខេត្តតាកែវ

## ២.១. ការរៀបចំសោភ័ណភាពនៅក្រុងដូនកែវ

កាលណាតំបន់មួយ ឬទីកន្លែងមួយមានភាពស្រស់ស្អាតវានឹងក្លាយជាតំបន់មួយដែលពោរពេញទៅដោយភាពទាក់ទាញ ភាពល្អប្រសើរ និងភាពស្រស់បំព្រងដោយសារបរិស្ថាន និងអនាម័យនៅក្នុងតំបន់នោះ។ ពាក្យថា សោភ័ណភាព គឺជាអ្វីៗដែលធ្វើឱ្យប្រសើរឡើងជាងមុន ធ្វើឱ្យល្អហ្មត់ហ្មង និងជាអ្វីៗទាំងអស់ដែលអាចមើលឃើញនឹងភ្នែកបានហើយធ្វើឱ្យមានការចាប់អារម្មណ៍។[២៦]

សព្វថ្ងៃនេះបើយើងធ្វើការមើល និងប្រៀបធៀបក្រុងដូនកែវកាលពីមុន និងពេលបច្ចុប្បន្នយើងឃើញថាសន្ទុះនៃការអភិវឌ្ឍនៅក្នុងក្រុងមានការផ្លាស់ប្តូរគួរមានការកត់សម្គាល់ ជាពិសេសទៅទៀតនោះ គឺទៅលើបញ្ហាសោភ័ណភាពនេះ។ ក្នុងការរៀបចំនូវសោភ័ណភាពក្រុង គឺអាស្រ័យទៅលើហេតុផលជាច្រើនដែលតម្រូវឱ្យអាជ្ញាធរត្រូវយកចិត្តទុកដាក់ជាទីបំផុត ចំណែកឯផលទទួលបានពីការរៀបចំនោះមានដូចជាធ្វើឱ្យក្រុងមានភាពស្រស់ស្អាត មានផាសុកភាព ជាពិសេសមានការកែលម្អពីភាពអនាធិបតេយ្យប្រែក្លាយជាមកជាភាពស្រស់ស្អាត មានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយត្រឹមត្រូវតាមស្តង់ដា ដែលធ្វើឱ្យប្រជាជននៅក្នុងទីក្រុងផ្ទាល់មានការរស់នៅប្រកបដោយសុខដុមរមនា សុខសុវត្ថិភាពទាំងផ្លូវកាយ ផ្លូវចិត្ត សន្តិសុខ សណ្តាប់ធ្នាប់ មានផាសុកភាព អនាម័យល្អ និងមានអារម្មណ៍ស្រស់ស្រាយជាមួយនឹងសោភ័ណភាពនៅក្នុងទីក្រុង។

ហេតុដូចនេះ ទើបរដ្ឋបាលក្រុងបានខិតខំស្វះស្វែងរកមធ្យោបាយកែកុន និងស្ថាបនាដើម្បីឱ្យទីក្រុងដូនកែវទាំងមូលមានភាពរីកចម្រើនការអភិវឌ្ឍ និងមានភាពលេចធ្លោជាពិសេសដើម្បីប្រកួតប្រជែងខាងផ្នែកសោភ័ណភាពជាមួយក្រុងដទៃៗទៀតនៅក្នុងប្រទេសកម្ពុជា។

### ២.១.១. ការរៀបចំសោភ័ណភាពពេលថ្ងៃ

ការរៀបចំសោភ័ណភាពពេលថ្ងៃ គឺសម្តៅទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ ចិញ្ចើមផ្លូវ សំណង់អាគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី និងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ និងទាំងថ្មើរជើងផង ប្រកបដោយសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយល្អ

[២៦] យោងទៅតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

ថែមទៀតផង។[២៧] ក្នុងនោះយើងសង្កេតឃើញនៅក្នុងក្រុងដូនកែវមានការអភិវឌ្ឍទៅលើហេដ្ឋារចនាសម្ព័ន្ធ ការដាំដើមឈើតាមផ្លូវដើម្បីលម្អទីក្រុងមានសួនច្បារសាធារណៈ បំពាក់នៅស្លាកសញ្ញា ភ្លើងសញ្ញា គំនូសសញ្ញាចរាចរណ៍តាមដងផ្លូវ ព្រមទាំងមានសំណង់អគារ បុរីតូចធំតាមស្តង់ដាដែលបានកំណត់ផងដែរ។

❖ **ការដាំដើមឈើតាមដងផ្លូវ**

ការដាំដើមឈើដើម្បីរៀបចំលម្អទីក្រុងវាពិតជាមានសារៈសំខាន់សម្រាប់ទីក្រុងមួយ។ អភិបាលខេត្តតាកែវ និងអាជ្ញាធរក្រុងដូនកែវក្នុងក្រុងដូនកែវបានដាំដើមក្រោកពូជផ្កាពណ៌លឿងចំនួន៣០០ដើម ស្របតាមចិញ្ចើមផ្លូវជាតិលេខ២ ចាប់ពីរង្វង់មូលអូរចំបក់ដល់វិមានឯករាជ្យដើម្បីលម្អសោភ័ណភាពទីក្រុងដូនកែវ សម្រាប់ការលម្អទាំងនេះ គឺជាការទាក់ទាញចំណីភ្នែករបស់ភ្ញៀវជាតិ និងអន្តរជាតិដែលចង់មកកម្សាន្តនៅខេត្តនេះផងដែរ។

❖ **ការបំពាក់ភ្លើងសញ្ញាចរាចរណ៍**

ចំពោះការបំពាក់ភ្លើងសញ្ញា គំនូសសញ្ញា និងផ្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវបានចែងក្នុងជំពូកទី២ មាត្រា ៥ នៃច្បាប់ចរាចរណ៍ផ្លូវគោកបានចែងថា សញ្ញាចរាចរណ៍ផ្លូវគោករួមមាន ផ្លាកសញ្ញាចរាចរណ៍តាមផ្លូវ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍លើផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត។ ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើផ្លូវត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាហូរហែនៅតាមកន្លែងមានសារៈប្រយោជន៍ដែលធ្វើឱ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ។ សញ្ញាគ្រោះថ្នាក់នៅតាមផ្លូវដងផ្លូវដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ត្រូវដាក់ក្នុងចម្ងាយឱ្យសមស្របល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវដែលធ្វើឱ្យអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុនបាន។

❖ **ការដាក់គំនូសសញ្ញាចរាចរណ៍**

ការដាក់គំនូសសញ្ញាមានសារៈសំខាន់ណាស់សម្រាប់អ្នកធ្វើដំណើរនៅលើដងផ្លូវ ដែលបានបង្កលក្ខណៈងាយស្រួលសម្រាប់អ្នកបើកបរ និងអ្នកថ្មើរជើងដែលបានធ្វើការបែងចែកសិទ្ធ អាទិភាពនៃការបើកបរលើដងផ្លូវ ដូចជាគំនូសសញ្ញាពណ៌សកាត់ទទឹងផ្លូវ គំនូសសញ្ញាតាមបណ្តោយផ្លូវទ្រូងផ្លូវ គំនូសសញ្ញាព្រួញលើទ្រូងផ្លូវ និងគំនូសសញ្ញាផ្សេងៗលើទ្រូងផ្លូវ។

[២៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

❖ **ការដាក់ស្លាកសញ្ញាចរាចរណ៍**

ដោយសារតែការកើនឡើងនៃចំនួនប្រជាជន តម្រូវការនៃចំនួនយានយន្តគ្រប់ប្រភេទ ជាពិសេសរថយន្ត ជាកត្តាធ្វើឱ្យមានកកស្ទះចរាចរណ៍បណ្តាលមកពីការចតរថយន្តគ្មានសណ្តាប់ធ្នាប់នោះ រដ្ឋបាលក្រុងដូនកែវ មានការលើកស្លាកចរាចរណ៍បន្ថែមជាកត្តាសំខាន់នៃការ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ដោយបច្ចុប្បន្នមាន ស្លាកចរាចរណ៍សរុប ៤៣ស្លាក។

### ២.១.២. ការរៀបចំសោភ័ណភាពនាពេលយប់

ការរៀបចំសោភ័ណភាពពេលយប់ គឺសម្តៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានា និងតាមដង មហាវិថីនានានៅក្នុងទីក្រុង ជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រីនៅតាមសួនច្បាររាត្រីនៅតាម សួនច្បារសាធារណៈនៅក្នុងទីក្រុង។[២៨]

➢ **ការដំបង្គោលភ្លើងអគ្គិសនី**

ការដំបង្គោលភ្លើងអគ្គិសនីតាមដងផ្លូវនាពេលយប់ ជាកត្តាជួយលើកសោភ័ណភាពនៅក្នុងក្រុងជា ពិសេស គឺការបំភ្លឺផ្លូវនាពេលរាត្រីសម្រាប់អ្នកដំណើរទៅវិញទៅមកតាមដងផ្លូវ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ព្រមទាំងការរក្សានូវសន្តិសុខរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងក្រុងដូនកែវទាំងមូល និងដើម្បីសម្រួលដល់ការ ធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋ ជាពិសេសទប់ស្កាត់មិនឱ្យមានបទល្មើសកើតឡើងនៅក្នុងក្រុងនាពេលយប់។

## ២.២. ការរៀបចំសណ្តាប់ធ្នាប់ក្នុងក្រុងដូនកែវ

ការរៀបចំសណ្តាប់ធ្នាប់ល្អជារួម គឺជាការរៀបចំក្រុងដើម្បីឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់ សម្តៅដល់ការរៀបចំរាជធានី ឬ ដែលជាកន្លែងមួយមិនមានសកម្មភាពកសិកម្មឱ្យមានភាពល្អ មានសន្តិសុខ ភាពស្ងប់ស្ងៀម និងគ្មានការបំពុលទាំងប្រាំ។ អាស្រ័យដោយភូមិសាស្ត្ររបស់ក្រុងមានអំណោយផលល្អ មានការគ្រប់គ្រង ការពាររក្សាសន្តិសុខជូនប្រជាពលរដ្ឋ គឺមានភាពស្រួល។ ជាក់ស្តែងដោយមានការសហការ ល្អរវាងកងកម្លាំងសមត្ថកិច្ច អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ មានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ ក៏ដូចជាសង្គមស៊ីវិល ផ្តួបផ្សំការប្រើប្រាស់នូវវិធានការសរុប មធ្យោបាយសរុប កម្លាំងសរុប និងដាក់បទបញ្ជាស្តីពី ការលុបបំបាត់ល្បែងស៊ីសង ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនគ្រប់ប្រភេទ ដោយធានា បាននូវសុវត្ថិភាពល្អប្រសើរដែលបង្កលទ្ធភាពជូនប្រជាពលរដ្ឋ អាចធ្វើដំណើរឆ្លងកាត់ការទំនាក់ទំនងសេដ្ឋកិច្ច

[២៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

សង្គមកិច្ចយ៉ាងល្អប្រសើរគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។[២៩] បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង បានរៀបចំយន្តការឆ្លើយតបទៅនឹងគោលការណ៍របស់គោលនយោបាយដែលមាន ៧ចំណុចទទួលបានជោគជ័យ ជាពិសេសគណៈបញ្ជាការឯកភាពក្រុង បានរៀបចំគណៈក្រុមប្រជាការពារតាមភូមិនៃមូលដ្ឋានទាំង៣សង្កាត់ចាប់តាំងពី ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ននេះមានសរុប ៣៤២នាក់។[៣០] ទន្ទឹមនឹងនេះដែរ រដ្ឋបាលក្រុងបានរៀបចំកម្មវិធីចុះជួបប្រជាពលរដ្ឋដល់មូលដ្ឋានតាមរយៈវេទិកាសាធារណៈទទួលសំណូមពរ និងដោះស្រាយបញ្ហាជាច្រើនឈរនៅលើគោលការណ៍ ឈ្នះ ឈ្នះ ទទួលបាននូវលទ្ធផលល្អប្រសើរជូនប្រជាពលរដ្ឋ។

លើសពីនេះទៅទៀតមន្ត្រីមានសមត្ថកិច្ចបានខិតខំរៀបចំសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋក្នុងពិធីផ្សេងៗថែមទៀតផង។ នៅក្នុងនោះផងដែរ ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈដែលមាន៣សង្កាត់ស្ថិតនៅក្រុងដូនកែវគឺ សង្កាត់បារាយណ៍ សង្កាត់រកាក្នុង និងសង្កាត់ក្រៅ ដែលបានរៀបចំនៅសណ្តាប់ធ្នាប់ដូចជា៖

- **សង្កាត់បារាយណ៍**

ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈសង្កាត់បារាយណ៍បានផ្សព្វផ្សាយពង្រឹងនូវការការពារសន្តិសុខសណ្តាប់ធ្នាប់នៅក្នុងមូលដ្ឋានបានប្រជុំចលនាប្រការពារ និងផ្សព្វផ្សាយផែនការសកម្មភាពសុវត្ថិភាពចរាចរផ្លូវគោកតាមមូលដ្ឋានដែលមានរយៈពេល១២ខែ។[៣១]

- **សង្កាត់រកាក្នុង**

ចំណែកឯសង្កាត់រកាក្នុងវិញ បានរៀបចំប្រជុំពង្រឹងសមត្ថភាពប្រជាការពារដែលនៅក្នុងនោះមានចំនួន៤វគ្គ មានរយៈពេល១២ខែ។[៣២]

[២៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

[៣០] កម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី១០

[៣១] កម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី២២

[៣២] កម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី២៣

➢ **សង្កាត់រកាក្រៅ**

ក្នុងនោះផងដែរ ខាងផ្នែករដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈសង្កាត់រកាក្រៅ បានពង្រឹងនូវការអនុវត្តភូមិឃុំមានសុវត្ថិភាពទូទាំងសង្កាត់ដែលមានចំនួន ១៤វគ្គ មានរយៈពេល២ឆ្នាំ សាងសង់ប៉ុស្តិ៍ភូមិ ឃុំ មានសុវត្ថិភាពដែលមានទូទាំងសង្កាត់ មានចំនួន ១៤កន្លែង ហើយមានរយៈពេល២ឆ្នាំ អប់រំផ្សព្វផ្សាយច្បាប់អំពើហិង្សា មានចំនួន ១៤វគ្គ មានរយៈពេល២ឆ្នាំ អគ្រានុកូលដ្ឋានទូទាំងសង្កាត់ មានចំនួន ១៤វគ្គហើយមានរយៈពេល២ឆ្នាំ វគ្គពង្រឹងសមត្ថភាពសមាជិកភូមិ មានចំនួន១វគ្គ មានរយៈពេល២ឆ្នាំ ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកមានចំនួន ១៤វគ្គ មានរយៈពេល២ឆ្នាំ ផ្តល់នូវមួកសុវត្ថិភាពចំនួន ១០០មួក មានរយៈពេល២ឆ្នាំ ផ្សព្វផ្សាយពីល្បែងស៊ីសង មានចំនួន ១៤វគ្គ មានរយៈ២ឆ្នាំ និងផ្សព្វផ្សាយការប្រើប្រាស់គ្រឿងញៀនមានចំនួន ១៤វគ្គ មានរយៈពេល២ឆ្នាំ។[៣៣]

### ២.២.១. សន្តិសុខ

ដើម្បីឱ្យទីក្រុងមួយមានសណ្តាប់ធ្នាប់ គឺត្រូវធ្វើយ៉ាងណាធានាឱ្យមាននូវ សន្តិសុខ សុវត្ថិភាពដែលជាសេចក្តីសុខសាន្ត និងគ្មានភាពចលាចលផ្សេងៗកើតឡើង។ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ស្របតាមគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដើម្បីជូនប្រជាពលរដ្ឋឱ្យរស់នៅប្រកប ដោយសុវត្ថិភាព និងសន្តិភាពនោះ ក្រុមប្រឹក្សា និងគណៈអភិបាលក្រុងដោយមានការជួយជ្រោមជ្រែងពីស្ថាប័នជំនាញពាក់ព័ន្ធនានា ជាពិសេសដោយមានការចង្អុលបង្ហាញពីគណៈបញ្ជាការឯកភាព រដ្ឋបាលខេត្ត ទើបរដ្ឋបាលក្រុងដូនកែវបានបង្រ្កាបសកម្មភាពបទល្មើសផ្សេងៗដូចជាការចែកចាយ និងសេពគ្រឿងញៀន ក្មេងទំនើង ចោរលួច ឆក់ ប្លន់ អំពើហិង្សា ការល្មើសច្បាប់ចរាចរណ៍ផ្លូវគោក រួមជាមួយ និងបទល្មើសដទៃជាច្រើនទៀតហើយព្រមទាំងបានរៀបចំសណ្តាប់ធ្នាប់ក្នុងពិធីបុណ្យផ្សេងៗទៀត។

លើសពីនេះរាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ក្នុងគោលបំណងធានាការពារសុខសុវត្ថិភាពជូនប្រជាពលរដ្ឋតាមភូមិ ឃុំនីមួយៗមិនត្រឹមតែរក្សាការពាររូបរាងកាយរបស់បុគ្គលម្នាក់ៗនោះទេថែមទាំងទប់ស្កាត់មិនឱ្យកើតមានអសន្តិសុខលើទ្រព្យសម្បត្តិដែលជាកម្លាំងញើសឈាមរបស់ប្រជាពលរដ្ឋ និងមួយវិញទៀតគិតគូរលើសុខភាពអនាម័យថែមទៀតផង។ ជាការពិតណាស់ការការពារសន្តិសុខ គឺមិនសំដៅត្រឹមតែបរិបទក្នុងសង្គមនោះទេ ប៉ុន្តែសន្តិសុខបានផ្តោតទៅលើសុខសុវត្ថិភាពបីសំខាន់ៗរួមមាន៖

---

[៣៣] កម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី២៥

➢ **សុវត្ថិភាពបុគ្គល** ការធានាការពារសុវត្ថិភាពបុគ្គល គឺសម្តៅទៅលើទីកន្លែងដែលជាមជ្ឈមណ្ឌលមួយមានមនុស្សរស់នៅប្រកបដោយសេចក្តីសុខផ្លូវកាយ ឬសុខសុវត្ថិភាពរូបរាងកាយរបស់បុគ្គលម្នាក់ៗត្រូវបានការពារ។ ដោយការបញ្ចៀសមិនឱ្យមានការប៉ះពាល់ដល់រូបរាងកាយដល់ប្រជាពលរដ្ឋដោយកត្តាមួយចំនួនដូចជា ក្មេងទំនើង អំពើហិង្សាគ្រប់រូបភាព ជាពិសេសបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលបង្កជាភាពព្រួយបារម្ភណ៍ដល់ប្រជាជននៅក្នុងមូលដ្ឋាន រហូតឈានដល់ការដាក់ចេញនូវយុទ្ធសាស្ត្រក្នុងផែនការអភិវឌ្ឍក្រុងដូនកែវផងដែរ។ ក្នុងនោះបានជំរុញឱ្យមានការពង្រឹងនូវការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ជាពិសេសផ្តោតសំខាន់លើការគោរពច្បាប់ចរាចរណ៍ ព្រមទាំងរៀបចំនូវដំណោះស្រាយដោយធ្វើយ៉ាងណាឱ្យមានគ្រោះថ្នាក់ចរាចរណ៍កាន់តែការមានការថយចុះ។ គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាពបានចូលរួមយ៉ាងសកម្មក្នុងការការពារសុវត្ថិភាពបុគ្គលផងដែរ ហើយគោលនយោបាយនេះមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ចរាចរណ៍ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គ្រប់ប្រភេទ
- គ្មានអំពើអាណាចារ ការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភទ ការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ និងបទល្មើសគ្រប់ប្រភេទ
- គ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានគ្រោះថ្នាក់ដោយគ្រាប់យុទ្ធភ័ណមិនទាន់ផ្ទុះ
- មានវិធានការណ៍ទប់ស្កាត់គ្រប់គ្រង និងការឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- គ្មានការត្រួតពិនិត្យខុសច្បាប់។[៣៤]

[៣៤] ផែនការណែនាំ ស្តីពីការចាត់តាំងអនុវត្តន៍គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព, លេខ០២០ ផ.ក ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

- **សុវត្ថិភាពសម្ភារៈ** បុគ្គលម្នាក់ៗមាននូវសម្ភារៈផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ ដូច្នេះគេតែងតែស្រឡាញ់ និងការពារនូវទ្រព្យខ្លួន ដោយមិនចង់ឱ្យមានជនណាម្នាក់មកបំពារបំពាននោះទេ។ ប៉ុន្តែករណីខ្លះគេមិនអាចការពារទ្រព្យរបស់ខ្លួនឯងបាននោះទេ ព្រោះថាមានការគំរាមកំហែងដល់អាយុជីវិតរបស់ពួកគេជាហេតុដែលត្រូវមានសមត្ថកិច្ចដើម្បីទទួលបានការជួយសង្គ្រោះ។ ដើម្បីឱ្យទីក្រុងមួយមានសន្តិសុខពេញលេញ លុះត្រាតែមានការធានានូវសុវត្ថិភាពគ្រប់រូបភាព សូម្បីតែតែសុវត្ថិភាពសម្ភារៈរបស់ប្រជាជន។ ចំពោះពាក្យថាសុវត្ថិភាពសម្ភារៈនេះសម្តៅលើការទទួលបានការការពារទ្រព្យសម្បត្តិ និងការយកចិត្តទុកដាក់ប្រកបដោយសុខសុវត្ថិភាព។ ជាក់ស្តែងដើម្បីធានាឱ្យបាននូវ សុវត្ថិភាពខាងផ្នែកសម្ភារៈ សកម្មភាពនៃការប្រព្រឹត្តបទល្មើសផ្សេងៗដូចជា លុះត្រាតែនៅក្នុងមូលដ្ឋាននោះគ្មានសកម្មភាពនៃការប្រព្រឹត្តអំពើជួញដូរ និងប្រើប្រាស់គ្រឿងញៀន ករណីគ្រឿងញៀនជាបញ្ហាដែលបង្កចលាចលដល់សង្គម ជាការពិតបុគ្គលដែលពាក់ព័ន្ធគ្រឿងញៀននេះតែងតែមានតម្រូវការថវិកាច្រើនក្នុងការទិញ និងលក់នូវសារធាតុញៀននោះ។ ប្រសិនបើមានគ្មាននូវថវិកាគ្រប់គ្រាន់ជាហេតុនាំឱ្យបុគ្គលនោះព្យាយាមរិះរកនូវគ្រប់វិធីដើម្បីធ្វើយ៉ាងណាឱ្យតែមានប្រាក់ដែលខ្លួនត្រូវការជួនការពេលខ្លះឈានដល់ការប្រព្រឹត្តបទល្មើសគំរាមកំហែងយកទ្រព្យរបស់អ្នកដទៃ ដើម្បីយកមកបំពេញតម្រូវការរបស់ខ្លួនផងដែរ។ គ្មានអំពើលួច ឆក់ ប្លន់ និងការចាប់ជំរិតគ្រប់ប្រភេទ សម្តៅក្នុងមូលដ្ឋានគ្មានការគំរាមកំហែងយក ទ្រព្យរបស់អ្នកដទៃមកធ្វើជារបស់ខ្លួនដោយពុំមានការអនុញ្ញាតពីម្ចាស់នៃទ្រព្យនោះ ឬអំពើដែលអាចបណ្តាលឱ្យម្ចាស់ទ្រព្យត្រូវទទួលរងនូវសកម្មភាពរំលោភបំពានផ្សេងៗថែមទៀតផង។ គ្មានការលេងល្បែងស៊ីសងខុសច្បាប់ ការប្រព្រឹត្តល្បែងស៊ីសងតែងតែមានការភ្នាល់ដោយប្រើនូវប្រាក់ ហើយគ្រប់ល្បែងស៊ីសងទាំងអស់តែងតែមានឈ្នះ និងចាញ់។ ដូច្នេះជាធម្មតានៅពេលដែលចាញ់ល្បែងបុគ្គលដែលចាញ់តែងតែចង់ស្រង់ដើមមកវិញដែលសកម្មភាពនេះអាចធ្វើឈានដល់ការខាតបង់ទ្រព្យទាំងអស់ ហើយខណៈដែលមកដល់ផ្លូវទាល់ច្រកបុគ្គលមួយចំនួនច្បាស់ជាសម្លឹងឃើញទ្រព្យអ្នកដទៃ។
- **សុវត្ថិភាពចំណីអាហារ** ការបរិភោគចំណីអាហារពិតជាមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់ជីវិត ប៉ុន្តែប្រសិនបើ ការទទួលទានអាហារគ្មានគុណភាព ឬប្រើប្រាស់បច្ចេកទេសផលិតមិនត្រឹមត្រូវតាមស្តង់ដាវានឹងជះផលអាក្រក់ដល់ការសុខភាពជាទម្ងន់ ដូច្នេះរាល់អាហារដាក់លក់លើទីផ្សារត្រូវមានការត្រួតពិនិត្យគុណភាព និងសុពលភាពរបស់មុខទំនិញនីមួយៗឱ្យមានភាពជាក់លាក់។ ម៉្យាងទៀតក្នុងនាមជាប្រជាជនធម្មតា គឺមិនអាចមើលមិនដឹងពីសមាសធាតុផ្សំដែលប៉ះពាល់ដល់សុខភាពនោះទេ

ដូចនេះវាបានក្លាយជាតួនាទីរបស់មន្ត្រីមានជំនាញក្នុងការត្រួតពិនិត្យមើលលើអនាម័យចំណីអាហារ ដែលវាជាកិច្ចការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអាចស្នើរសុំសហការពីស្ថាប័នឯកទេសផ្សេងៗ ដែលនៅក្នុងនោះមានដូចជា ក្រសួងសុខាភិបាល គឺនាយកដ្ឋានឱសថគ្រឿងសម្អាង ក្រសួងឧស្សាហកម្ម ក្រសួងបរិស្ថាន ក្រសួងកសិកម្ម គឺនាយកដ្ឋានសេដ្ឋសាស្ត្រដែលគ្រប់គ្រងការនាំចេញថ្នាំសម្លាប់សត្វនិងការចាក់ថ្នាំបង្ការសត្វផងដែរ និងក្រសួងជាច្រើនទៀតដើម្បីការពារសុវត្ថិភាពខាងចំណីអាហារ ក៏ត្រូវការមន្ត្រីពាក់ព័ន្ធដទៃទៀតដែរ។ យោងតាមសេចក្តីណែនាំលេខ ១៨ អយក.សណន, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ ស្តីពីចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនដែលត្រូវបានហាមឃាត់មានចំនួន ០៦ប្រភេទដូចខាងក្រោម៖

- ចំណីអាហារគ្រប់ប្រភេទដែលហួសកំណត់កាលបរិច្ឆេទ
- គ្រឿងស្រវឹង និងផលិតផលថ្នាំជក់គ្រប់ប្រភេទ
- ចំណីអាហារដែលមិនមានប្រភពច្បាស់លាស់
- ភេសជ្ជៈប៉ូវកម្លាំង ភេសជ្ជៈផ្អែមខ្លាំង កាហ្វេ ការ៉េម និងទឹកស៊ីរ៉ូគ្រប់ប្រភេទ
- ស្ករសូកូឡា ស្ករគ្រាប់ និងស្ករកៅស៊ូគ្រប់ប្រភេទ
- ចាហ៊ួយគ្រប់ប្រភេទ នំដូណាត់ និងនំផ្អែមខ្លាំង។[៣៥]

### ២.២.២. បញ្ហាចរាចរក្រុងដូនកែវ

បញ្ហាចរាចរណ៍ គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ការជួយអភិវឌ្ឍន៍ប្រទេសជាតិមានភាពរីកចម្រើន។ កាលណាប្រទេសមានបញ្ហាកកស្ទះចរាចរណ៍នៅក្នុងក្រុង ជាការពិតណាស់វាមានគុណវិបត្តិផ្នែកសេដ្ឋកិច្ចដល់ប្រជាពលរដ្ឋ។ បញ្ហាកកស្ទះចរាចរណ៍ជាផ្នែកមួយដែលគួរឱ្យព្រួយបារម្ភពីព្រោះវាបានឱ្យមានការបំពុលបរិស្ថាន និងប៉ះពាល់ទៅដល់សុខភាពមនុស្ស។ នៅក្នុងនោះផងដែរចំពោះក្រុងដូនកែវ ក៏មានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើការកកស្ទះចរាចរណ៍ ពីព្រោះការស្ទះចរាចរណ៍បានធ្វើឱ្យខ្យល់អាកាសមានសភាពអួរអាប់ ដោយសារការបញ្ចេញនូវផ្សែងពុលពីយានយន្តចាស់ៗដែលចរាចរនៅលើដងផ្លូវថ្នល់ដែលបណ្តាលឱ្យមាននូវគុណវិបត្តិសម្រាប់ប្រជាជនជាច្រើនដូចជា ខាតបង់ពេលវេលា ជាពិសេសប៉ះពាល់ដល់សុខភាព ព្រមទាំងបំពុលបរិស្ថានតាមរយៈផ្សែងបំពុលទាំងនេះផងដែរ។ ជាក់ស្តែងការកកស្ទះចរាចរណ៍ គឺបណ្តាលមកពីកត្តាបីយ៉ាងរួមមាន៖

[៣៥] សេចក្តីណែនាំ ស្តីពីចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន, លេខ១៨ អយក. សណន ថ្ងៃទី២ ខែឧសភា ឆ្នាំ ២០១៩

- **កត្តាមនុស្ស** កត្តាធនធានមនុស្សបានកើនឡើង ចំណែកឯតម្រូវការក៏មានការកើនឡើងទៅតាមជីវភាពប្រចាំថ្ងៃផងដែរ។ មនុស្សភាគច្រើនបានប្រើប្រាស់មធ្យោបាយដោយយានជំនិះផ្ទាល់ខ្លួនដែលមានកកស្ទះចរាចរណ៍ និងបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍កើតឡើងនៅពេលដែលខ្វះការប្រុងប្រយ័ត្នមិនគោរពនូវច្បាប់ចរាចរណ៍ បើកបរខ្វះការអធ្យាស្រ័យគ្នាទៅវិញទៅមក។
- **កត្តាយានយន្ត** នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ប្រជាជនមួយចំនួនធំមានការប្រើប្រាស់នូវយានយន្តមួយទឹកៗដែលនាំចូលពីបរទេស ពីព្រោះប្រជាជនចំណាយទៅតាមលទ្ធភាពដែលខ្លួនមានសម្រាប់បម្រើនៅជីវភាពប្រចាំថ្ងៃរបស់ខ្លួនកត្តានេះក៏ជាហេតុបំពុលបរិស្ថានផងដែរ។
- **កត្តាផ្លូវថ្នល់** កត្តាផ្លូវថ្នល់មិនទាន់បានឆ្លើយតបទៅតាមតម្រូវការនៅឡើយទេ ពីព្រោះទីរួមខេត្ត និងក្រុងពុំទាន់មានផ្លូវលក្ខណៈស្តង់ដានៅមានលក្ខណៈតូចមានការខូច ជួសជុលច្រើនដង និងមិនទាន់មានផ្លូវអាកាសនៅឡើយ។[៣៦]

### ២.២.៣. ភាពស្ងប់ស្ងៀម

ភាពស្ងប់ស្ងៀម គឺសំដៅលើកន្លែងទាំងឡាយណា ដែលមិនអនុញ្ញាតឱ្យមានការរំខានដោយមានសម្លេងតាមរយៈការហាមឃាត់មិនឱ្យមានការសាងសង់ រោងចក្រ ឬសហគ្រាស នៅជិតលំនៅឋានរបស់ប្រជាពលរដ្ឋ សាលារៀន និងមន្ទីរពេទ្យជាដើមពីព្រោះបង្កការរំខានដល់ប្រជាពលរដ្ឋ។

❖ **ផាសុកភាព**

ផាសុកភាពសម្តៅលើ ប្រណិតភាពនៃការរស់នៅដែលមានភាពស្រស់ស្រាយ ភាពសប្បាយរីករាយមិនធុញថប់។ ដោយឡែកយោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ផាសុកភាពសំដៅលើសេចក្តីសម្រាន្តសេចក្តីសប្បាយ។[៣៧] ដូច្នេះផាសុកភាពជារួមមានន័យថា ភាពប្រកបដោយសេចក្តីសុខ និងសប្បាយ។ ដើម្បីទទួលបាននូវផាសុកភាពមួយដែលជាទីគាប់ចិត្តលុះត្រាតែមានអនាម័យបរិស្ថាន មានសុខភាពល្អប្រសើរផងដែរ។ ម៉្យាងវិញទៀតបញ្ហានេះពាក់ព័ន្ធនឹងការរៀបចំក្រុងដែលវាមានសារៈសំខាន់ណាស់ក្នុងការផ្តល់នូវផាសុកភាពដល់ប្រជាជនតាមរយៈការផ្តល់សេវាសុខភាពសាធារណៈ និងការគ្រប់គ្រងស្ថានភាពបរិស្ថានផងដែរ។ ជាទូទៅក្រុងជាទីប្រជុំជនដែលមានការប្រមូលផ្តុំនូវចំនួនប្រជាជនជាច្រើនជាងនៅតាមជនបទ

[៣៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី១

[៣៧] យោងទៅតាមវចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

ជាពិសេសមានដំណើរការសកម្មភាពជាច្រើន ដែលបណ្តាលឱ្យមានក្រុងងាយរងទទួលផលប៉ះពាល់ពីការបំពុលបរិស្ថានកើតចេញពីរោងចក្រសិប្បកម្មសហគ្រាសកាកសំណល់ផ្សេងៗ។

## ២.៣. បញ្ហាប្រឈម និងដំណោះស្រាយ

### ២.៣.១. បញ្ហាប្រឈម

ការរៀបចំទីក្រុងនីមួយៗ តែងតែជួបប្រទះផលវិបាក និងបញ្ហាជាច្រើន ដូចជាតម្រូវការខ្ពស់ផ្នែកថវិកាសម្ភារៈ ធនធានមនុស្ស និងប្រភពធនធានដទៃទៀត។ ឧទាហរណ៍ ជាក់ស្តែងដើម្បីសាងសង់អគារមួយបានគេត្រូវចំណាយ និងប្រើប្រាស់នូវឧបករណ៍ និងសម្ភារៈជាច្រើន ពីព្រោះការសាងសង់អគារដែលមានទំហំធំគឺទាមទារនូវទំហំពលកម្មច្រើន ក៏ដូចជាចំណាយប្រាក់ឈ្នួលទៅលើកម្មករដូចគ្នា។ លើសពីនេះទៅទៀតដើម្បីឱ្យសំណង់អគារអាចទ្រទ្រង់បានល្អលុះត្រាតែមានគម្រោងការគណនាច្បាស់លាស់ និងការសាងសង់តាមស្តង់ដារ និងមាត្រដ្ឋានត្រឹមត្រូវ។ ជាការពិតណាស់សម្រាប់ការរៀបចំក្រុងដូនកែវក៏នូវតែមានការប្រឈមមុខនឹងបញ្ហាទាំងនេះផងដែរ ហើយកត្តាប្រឈមនោះរួមមានដូចជា ធនធានមនុស្ស កង្វះគម្រោងថវិកា និងកង្វះបច្ចេកទេស។

#### ២.៣.១.២. ធនធានមនុស្ស

ផ្នែកធនធានមនុស្ស ជាកត្តាចម្បងដែលមិនអាចខ្វះបានទោះបច្ចុប្បន្នកាន់តែទំនើប ដោយមានការប្រើប្រាស់នូវគ្រឿងយន្តជំនួសកម្លាំងមនុស្សពិតមែន ក៏នៅតែមានការគ្រប់គ្រងពីមនុស្សដដែរ។ ម៉្យាងទៀតធនធានមនុស្សនៅក្រុងដូនកែវមានការខ្វះខាតដោយសារតែកត្តាជីវភាពទើបធ្វើឱ្យមានប្រជាជនមានការចំណាកស្រុកទៅកាន់ទីក្រុង និងទៅធ្វើការនៅប្រទេសដទៃ។ ពីព្រោះកត្តាជីវភាពមានការរាំងស្ទះដល់ការរស់នៅពួកគាត់ជាហេតុបណ្តាលឱ្យពួកគាត់ព្យាយាមស្វែងរកលំនៅឋានថ្មីដែលអាចទទួលយកបានសម្រាប់ជីវភាពប្រចាំថ្ងៃ។ បញ្ហានេះជាកត្តា ប្រឈមនៅក្នុងការរៀបចំក្រុងដូនកែវផងដែរ។

បញ្ហាមួយទៀតដ៏សំខាន់ដែលបង្កផលវិបាកដល់ការអភិវឌ្ឍមួយកម្រិតទៀតនោះ គឺកង្វះសមត្ថភាពចំណេះដឹង ជំនាញ និងបច្ចេកទេស គឺមិនទាន់ពេញលេញតាមតម្រូវការជាក់ស្តែងនោះទេ ដូច្នេះហើយជាបញ្ហាធនធានមនុស្សជាកត្តាដែលជះផលប៉ះពាល់ដល់ការរៀបចំក្រុង។

### ២.៣.១.៣. កង្វះគម្រោងថវិកា និងកង្វះបច្ចេកទេស

**ក. កង្វះគម្រោងថវិកា**

ជាក់ស្ដែងប្រទេសកម្ពុជាសព្វថ្ងៃជាប្រទេសកំពុងអភិវឌ្ឍន៍ និងមិនទាន់រីកចម្រើនដូចប្រទេសមួយចំនួននៅឡើយទេ ដោយហេតុថាប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមជាច្រើន ជាពិសេសសង្គ្រាមផ្ទៃក្នុងដែលអូសបន្លាយរយៈ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ ក្រោយថ្ងៃរំដោះរាជរដ្ឋាភិបាលព្យាយាមអភិវឌ្ឍន៍ប្រទេសរហូតមកដល់បច្ចុប្បន្ន។ បើក្រឡេកមើលគម្រោងអភិវឌ្ឍន៍នីមួយៗវិញ គឺត្រូវការចំណាយទុនច្រើនហើយជាញឹកញាប់ប្រទេសកម្ពុជាតែងតែទទួលបានជំនួយមានសំណង និងឥតសំណងជាច្រើនពីបណ្ដាប្រទេសផ្សេងៗ។

ដើម្បីដំណើរការរៀបចំក្រុងបាន លុះត្រាតែមានការដាក់សំណើទៅថ្នាក់ជាតិ និងរងចាំការអនុញ្ញាតកញ្ចប់ថវិកាជាតិដែលផ្ដល់សម្រាប់ការអភិវឌ្ឍ។ ដូចនេះប្រសិនបើខាងថ្នាក់ជាតិអនុញ្ញាត និងភ្ជាប់មកជាមួយនូវកញ្ចប់ថវិកាវាមិនជាបញ្ហានោះទេ ប៉ុន្តែបើផ្ទុយទៅវិញបើគម្រោងត្រូវចំណាយច្រើនលើសពីលទ្ធភាពរបស់រដ្ឋច្បាស់ណាស់គម្រោងនោះនឹងត្រូវអូសបន្លាយដោយរងចាំការផ្ដល់ជំនួយពីប្រទេសដទៃ។

**ខ. កង្វះបច្ចេកទេស**

ដោយសារប្រទេសកម្ពុជា ជាប្រទេសមួយកំពុងអភិវឌ្ឍន៍ ដូច្នេះហើយទើបធ្វើឱ្យការរៀបចំក្រុងមានផលវិបាកជាមូលហេតុខ្វះបច្ចេកទេស និងមិនទាន់មានឧបករណ៍ទំនើបក្នុងការសាងសង់ ដូចជាការរៀបចំសោភ័ណភាព និងសណ្ដាប់ធ្នាប់ជាដើម។ ដោយសារតែហេតុផលនេះទើបធ្វើឱ្យមានសំណង់ភាគច្រើននៅប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ។ អ្វីដែលគួរឱ្យកត់សម្គាល់មិនត្រឹមតែកង្វះនូវឧបករណ៍ប៉ុណ្ណោះទេ ស្របពេលដែលប្រទេសកម្ពុជាទើបតែងើបពីសង្គ្រាមប៉ុន្មានសតវត្សចុងក្រោយធ្វើឱ្យបាត់បង់នូវបុគ្គលឆ្នើមក៏ដូចជាអ្នកមានចំណេះដឹងជាច្រើនរូប។ ជាហេតុនាំឱ្យបច្ចុប្បន្នមានការទាមទារនូវបុគ្គលដែលមានជំនាញខ្ពស់ជាច្រើននៅក្នុងការអភិវឌ្ឍ ហើយដោយសារជំនាញបច្ចេកទេសក្នុងស្រុកនៅមានកម្រិតនៅឡើយ ទើបបណ្ដាលឱ្យមាននូវតម្រូវការអ្នកបច្ចេកទេស ជាការពិតណាស់នៅក្នុងវិស័យសំណង់នាពេលបច្ចុប្បន្នមិនត្រឹមតែរីកចម្រើននោះទេ គឺមានគម្រោងសាងសង់នីមួយៗកាន់តែប្រណិត និងទំនើបដែលជាតម្រូវការទីផ្សារ ដូច្នេះវិស្វករដែលទើបតែចាប់ផ្ដើមការងារមិនអាចកាន់កាប់ការងារសំខាន់ៗនោះទេ លុះត្រាតែជាវិស្វករអាជីពដែលមានជំនាញបទពិសោធន៍ការងារច្រើនឆ្នាំ ទើបអាចទទួលបានឱកាសការងារកាន់គម្រោងនេះបាន។ ហើយបញ្ហានេះជាបញ្ហាចោទនៅក្នុងការទាមទារឱ្យមានវិស្វករមកពីបរទេសដែលគេមានជំនាញ និងការយល់ដឹងជាងវិស្វករនៅក្នុងស្រុក ទើបប្រឡូកនៅក្នុងការងារដែលមិនមែនជាវិស្វករអាជីពនោះទេ។ ដោយឡែកងាកទៅមើលបច្ចុប្បន្ន

ភាពរបស់ក្រុងដូនកែវវិញក៏នៅមានការខ្វះខាតបញ្ហាបច្ចេកទេសឧបករណ៍មិនទាន់មានគ្រប់គ្រាន់ និងអ្នកមានជំនាញបច្ចេកទេសផងដែរ។

### ២.៣.១.៤. ការបំពុលបរិស្ថាននាំងច្រាំ

កាលពីមុនបញ្ហាបរិស្ថានមិនសូវកើតមានឡើងដែលនាំឱ្យមានការព្រួយបារម្ភនោះទេ ពីព្រោះដោយចំនួនប្រជាជនតម្រូវការ និងការអភិវឌ្ឍនៅមានកម្រិតនៅឡើយ។ ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃកំណើនប្រជាជន និងតម្រូវការសម្រាប់ជីវភាពប្រចាំថ្ងៃមានការកើនឡើងនាពេលបច្ចុប្បន្ន និងការរីកចម្រើននៃសេដ្ឋកិច្ចយ៉ាងឆាប់រហ័សកំពុងបង្កឱ្យមានការបំពុលបរិស្ថានកើតមានឡើង។ សកម្មភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចបានបង្កើតជាផលវិបាកផ្នែកបរិស្ថានរួមមាន ការបំពុលទាំង៥ គឺការបំពុលទឹក ការបំពុលដី ការបំពុលខ្យល់ ការបំពុលសំឡេង និងការបំពុលសំណល់រឹងរាវ។

បរិស្ថាន គឺជាកត្តាមួយជំរុញឱ្យមានការរៀបចំក្រុងឱ្យមានភាពល្អប្រសើរផងដែរ។ បញ្ហាអំពីបរិស្ថានគឺប្រទេសទូទាំងសកលលោកទៅហើយដែលបានគិតគូរអំពីបញ្ហាបរិស្ថាន។ ដូច្នេះក្រុងដូនកែវ គឺជាក្រុងមួយដែលស្ថិតនៅក្នុងខេត្តតាកែវ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធបានគិតគូរយ៉ាងខ្លាំងទៅលើបញ្ហាបរិស្ថាននេះ ដើម្បីឱ្យប្រជាពលរដ្ឋនៅក្រុងទទួលបាននូវជាសុកភាពល្អ។

ប៉ុន្តែសំរាមនៅតែជាបញ្ហាចោទចំពោះបរិស្ថាននៅឡើយ ដោយសារប្រទេសមួយចំនួនកំពុងអភិវឌ្ឍន៍ ហើយការប្រមូលសំរាមនៅមានភាពខ្វះខាត បទពិសោធន៍ មធ្យោបាយ និងធនធាននៅក្នុងការគ្រប់គ្រងប្រមូលសំរាម កាកសំណល់រឹងរាវ ហើយការចូលរួមប្រើប្រាស់សេវាប្រមូលសំរាម និងបង់ថ្លៃសេវារបស់ប្រជាពលរដ្ឋប្រើប្រាស់នៅមានកម្រិតនៅឡើយ និងកត្តាប្រជាពលរដ្ឋមិនចូលរួមសហការ។ ចំណែកឯក្រុងស្រុកមួយចំនួនមិនទាន់មានដីសម្រាប់ជាទីលានចាក់សំរាមនៅឡើយ។

#### ក. ការបំពុលទឹក

ការបំពុលទឹកអាចត្រូវគេឱ្យនិយមន័យយ៉ាងច្រើនផ្សេងៗពីគ្នា។ ជាទូទៅការបំពុលទឹក គឺជាធ្វើឱ្យទឹកកខ្វក់ដល់ទឹកនៅពេលដែលសារជាតុបំពុលនានាបានហូរចូលនៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រតិកម្មដកយកសារជាតុបំពុលចេញ។ ហើយការបំពុលទឹកភាគច្រើនបណ្តាលមកពីកាកសំណល់ដែលចេញពីរោងចក្រឧស្សាហកម្ម កសិកម្ម និងតាមផ្ទះដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពមនុស្ស និងសត្វក៏ដូចជាគុណភាពបរិស្ថាននៃប្រភពទឹកទាំងមូល។ ទឹកពិតជាមានសារៈប្រយោជន៍ណាស់សម្រាប់ទ្រទ្រង់ដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិ ម៉្យាងទៀតការបំពុលទឹក គឺជាសកម្មភាពទាំងឡាយណាដែលធ្វើឱ្យទឹកប្រើ

ប្រាស់ខុសពីលក្ខណៈដើម ហើយការជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបរិស្ថានទៅតាមកម្រិតនៃការបំពុលទាំងនោះ។ ការបំពុលទឹកអាចកើតឡើងដោយមូលហេតុជាច្រើនដូចជា៖

- **ការបំពុលដោយឧស្សាហកម្ម**

ដោយសារឧស្សាហកម្ម ជាកន្លែងដែលបញ្ចេញចាមពលច្រើន និងមានផ្ទុកសារធាតុគីមី ការបំពុលដោយសារសំណល់អាចបង្កគ្រោះថ្នាក់ដល់សតិបញ្ញាកុមារ និងធ្វើឱ្យការលូតលាស់យឺតជាងធម្មតា។ ក្នុងនោះឧស្សាហកម្មដែលបំពុលច្រើនជាងគេ គឺឧស្សាហកម្មផលិតក្រដាស និងផលិតចំណីអាហារ។

- **ការបំពុលដោយកសិកម្ម**

ដើម្បីធ្វើស្រែចម្ការ ដាំដំណាំ បន្លែផ្លែឈើ ឱ្យទទួលបានទិន្នផលល្អ កសិករមួយចំនួនពួកគាត់បានប្រើប្រាស់នូវ ថ្នាំគីមី សម្លាប់សត្វល្អិតដូចជាដង្កូវ និងសត្វល្អិតជាដើម។ ការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ។ កសិដ្ឋានចិញ្ចឹមជ្រូក គោ មាន់ ទាជាដើម គឺបង្កើតឱ្យមានលាមក និងទឹកនោមដែលបញ្ចេញនូវឧស្ម័នពុលទៅក្នុងខ្យល់ហើយជ្រាបចូលចូលក្នុងដីបំពុលទឹកផងដែរ។

- **ការបំពុលដោយវិទ្យុសកម្ម**

រោងចក្រនុយក្លេអ៊ែរ ដែលមានផ្ទុកសារធាតុអ៊ុយរ៉ាញ៉ូម ដើម្បីផលិតគ្រឿងអគ្គិសនីដែលពួកយោធាប្រើប្រាស់នៅក្នុងនាវាមុជទឹក និងផលិតគ្រាប់បែកដោយបន្សល់សំណល់ និងបញ្ចេញកាំរស្មីថាមពល ជាហេតុនាំឱ្យគ្រោះថ្នាក់ដល់សុខភាពបណ្តាលឱ្យស្លាប់ មានជម្ងឺមហារីក ធ្វើឱ្យគ្មានកូន ឬទារកមានកាយសម្បទាមិនល្អគ្រប់គ្រាន់ជាដើម។

- **ការបំពុលដោយសំណល់ផ្សេងៗ**

ការបោះបង់ដោយសំណល់ដូចជា ថង់ប្លាស្ទិក កាតុង ក្រដាស កែវ សំណល់សេរីរាង្គ សំបកដបសំបកកង់ឡាន សំបកកង់ម៉ូតូ វត្ថុទាំងអស់នេះមិនងាយរលាយក្នុងធម្មជាតិនោះទេ ទោះបីជារលាយក៏មានរយៈពេលយូរដែលធ្វើឱ្យបរិស្ថានមិនមានភាពល្អប្រសើរ និងស្រស់ស្រាយ។ មិនតែប៉ុណ្ណោះការបោះចោលសំរាមពាសវាលពាលកាលនាំឱ្យស្ទះលូ និងមានផលប៉ះពាល់ទៅដល់មានភាវៈមានជីវិតដែលរស់នៅក្នុងទឹកផងដែរ។[៣៨]

[៣៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣, ទំព័រទី២៨

## ខ. មូលហេតុដែលនាំឱ្យមានការបំពុលខ្យល់

ការបំពុលខ្យល់មានប្រភពចេញពីការដុតឥន្ធនៈ តួយ៉ាងប្រេងឥន្ធនៈ ប្រេងម៉ាសូត និងធ្យូងសម្រាប់ការដឹកជញ្ជូនការប្រើប្រាស់នៅក្នុងវិស័យឧស្សាហកម្ម និងថាមពល។ ការដុតប្រេងឥន្ធនៈទាំងនេះបានបញ្ចេញផ្សែងពុលចូលទៅក្នុងបរិយាកាសដែលបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើគុណភាពខ្យល់ និងសុខភាពមនុស្សយ៉ាងខ្លាំង។

កត្តាចម្បងដែលបង្កើតឱ្យមានការបំពុលខ្យល់បានកើតចេញពីឧស្សាកម្ម ការដឹកជញ្ជូន ការដុតបញ្ចេះប្រេងឥន្ធនៈនិងកសិកម្មផងដែរ។ ការបំពុលខ្យល់ ស្ថិតនៅក្នុងចំណោមបញ្ហាប្រឈមផ្នែកសុខភាពធំបំផុតសម្រាប់ប្រជាជន។ នេះបើយោងតាមការបញ្ជាក់ពីអង្គការសុខភាពពិភពលោក បើសិនគ្មានការដោះស្រាយទេការស្លាប់របស់ប្រជាជននឹងបន្តកើនឡើងខ្លាំងនៅពេលអនាគត។

បើតាមទិន្នន័យអង្គការសុខភាពពិភពលោកប្រជាជនពិភពលោក៩០%ភាគរយ ដែលស្រូបយកខ្យល់កខ្វក់ជារៀងរាល់ថ្ងៃ ហើយក្នុងមួយឆ្នាំមនុស្សប្រហែលប្រាំពីរ ៧លាននាក់បានស្លាប់ ដោយសារតែការបំពុលខ្យល់ក្នុងនោះមានកើតជម្ងឺមហារីក ជម្ងឺផ្លូវដង្ហើម ជម្ងឺសួតជាដើម។ អង្គការអន្តរជាតិដដែលនេះបានបន្ថែមទៀតថាកម្រិតនៃការបំពុលខ្យល់ខ្លាំងជាងគេបានកើតឡើងនៅតំបន់ខាងកើតមេឌីទែរ៉ាណេ និងអាស៊ីអាគ្នេយ៍ ដោយកម្រិតការបំពុលនោះកើតឡើងប្រាំដងលើសកម្រិតស្តង់ដាកំណត់របស់ខ្លួនឯណោះ។ ចំណែកអ្នកស្លាប់កើតរហូតដល់៩០%ភាគរយ គឺស្ថិតនៅក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមដែលរងការបំពុលដោយសារ កំណើនឧស្សាហកម្ម ការដឹកជញ្ជូន កសិកម្ម និងការដុតប្រេងឥន្ធនៈនៅតាមលំនៅឋាននានាផងដែរ។ បច្ចុប្បន្នការបំពុលនៅក្នុងក្រុងដូនកែវកំពុងរងនូវការបំពុល ហើយនៅក្នុងការបំពុលនោះទៀតសោតគឺកើតចេញពីមូលហេតុចម្បងៗដូចខាងក្រោម៖

- **ការបំពុលដោយយានយន្ត**

យើងសង្កេតឃើញថានៅក្នុងក្រុងដូនកែវ តម្រូវការយានយន្តមានកំណើនកើនឡើងនៅតាមតម្រូវការរបស់ប្រជាពលរដ្ឋសម្រាប់ធ្វើដំណើរ។ ចំណែកឯចរាចរណ៍ ក៏មានការធ្វើដំណើរច្រើនដែលជាហេតុនាំឱ្យកម្រិតឧស្ម័នពុលដែលត្រូវបានបញ្ចេញទៅបរិយាកាសខ្ពស់។ លើសពីនេះ នៅក្នុងប្រទេសកម្ពុជាប្រជាជនភាគច្រើនប្រើប្រាស់នូវយានយន្តចាស់ៗទៅតាមលទ្ធភាពដែលពួកគាត់មានដែលបាននាំចូលពីប្រទេសដទៃដែលវាបញ្ចេញផ្សែងពុលទៅក្នុងបរិយាកាសច្រើនជាងរថយន្តថ្មី។

- **ការបំពុលដោយធូលី**

ធូលី ជាមូលហេតុដែលបណ្តាលឱ្យមានការបំពុលខ្យល់ផងដែរ។ សង្កេតឃើញថា នៅក្នុងក្រុងដូនកែវ កត្តាចម្បងនៅក្នុងការធ្វើឱ្យមានធូលីនោះ មកពីការដឹកជញ្ជូននៅសម្ភារៈសំណង់ មកពីការបើកបរនៅលើផ្លូវលំ ឬមកពីផ្លូវមិនទាន់បានជួសជុលជាហេតុបណ្តាលឱ្យមានដី ធូលីច្រើន។ ជាក់ស្តែងនៅតាមការដ្ឋានសំណង់ មានការទុកដាក់នៅសម្ភារៈសំណង់មិនបានត្រឹមត្រូវក៏ជាមូលហេតុឱ្យមាននូវធូលី ដី នោះចូលទៅក្នុង បរិយាកាសដែរ។

- **ការបំពុលដោយចំហេះអុស ធ្យូង**

ការប្រើប្រាស់អុស ធ្យូង ជាប្រភពថាមពលចម្អិនអាហារ គឺជាទំនៀមទម្លាប់មួយដែលប្រជាជនខ្មែរជា ពិសេសនៅតាមទីជនបទ។ ប៉ុន្តែការប្រើប្រាស់អុស ធ្យូងនេះមានផលប៉ះពាល់ខ្លាំងដល់បរិស្ថាន ដោយនៅក្នុង នោះចំហេះអុស ធ្យូង បានបង្កើតនូវឧស្ម័នកាបូនិច និងឧស្ម័នពុលជាច្រើនទៀតចូលបរិស្ថាន។

**គ. មូលហេតុនាំឱ្យមានការបំពុលដី**

ការបំពុលដី គឺត្រូវបានកំណត់ថាជាការសឹករិចរិល ឬការបំផ្លាញផ្ទៃដី និងដីដែលជាលទ្ធផលនៃការ កើតចេញពីសកម្មភាពរបស់មនុស្ស។ មូលហេតុនៃការបំពុលដី គឺជាបញ្ហាធំមួយនៅជុំវិញពិភពលោកហើយ បណ្តាលមកពីកត្តាផ្សេងៗគ្នា និងបុព្វហេតុចម្បងមួយចំនួនដូចខាងក្រោម៖

- **សកម្មភាពធ្វើកសិកម្ម**

ជាការពិតណាស់ ការធ្វើកសិកម្មត្រូវបានគេរកឃើញថារកមូលហេតុផ្ទាល់ មានការកាប់បំផ្លាញព្រៃ ឈើ៨០%ភាគរយនៅលើពិភពលោក។ ភាគច្រើនផ្ទៃដីកសិកម្មនេះត្រូវបាន ទាមទារដើម្បីបានដាំដំណាំ សម្រាប់ចំណីសត្វ ជាពិសេសគោ ក្របី សម្រាប់ឧស្សាហកម្មសាច់។ ម្យ៉ាងវិញទៀតបានកើនឡើងនៃកំណើន ប្រជាជនក្នុងពិភពលោក គឺការកើនឡើងនូវតម្រូវការផ្គត់ផ្គង់ស្បៀងអាហារដែលជាមូលហេតុបណ្តាលឱ្យព្រៃឈើ និងវាលស្មៅត្រូវបានប្តូរទៅជាដី ស្រែចម្ការ ការដាំដំណាំឱ្យទទួលបានផ្លែផ្កាល្អ កសិករត្រូវប្រើប្រាស់នូវសារធាតុ គីមីដើម្បីសម្លាប់សត្វល្អិត។

- **ការចាក់សំរាម**

ការរំលោភបំពានបំពានបរិស្ថានធំបំផុត គឺបំពុលដោយកាកសំណល់ ដែលបានបណ្តាលឱ្យមានការ ប៉ះពាល់ទៅលើសុខភាពដូចជា មហារីក បញ្ហារលូតកូន ជម្ងឺសរសៃប្រសាទជាដើម។ ហើយចំពោះអង្គធាតុ

ដែលចេញពីសំរាម គឺជាទឹករំអិលរាវដែលមានសារធាតុពុលខ្ពស់ផ្ទុកទៅដោយសារធាតុគីមីច្រើន ហើយក៏នាំប៉ះពាល់ដែលបានជះឥទ្ធិពលអាក្រក់ដល់បរិស្ថានជាមួយ និងភាវៈរស់គ្រប់ប្រភេទ។

- **សកម្មភាពធ្វើឧស្សាហកម្ម**

សកម្មភាពធ្វើឧស្សាហកម្ម គឺឧស្សាហ៍បញ្ចេញនូវកាកសំណល់ពុល និងវត្ថុធាតុដើម(គីមី)ទៅលើដី ឬបរិយាកាសដែលពួកគេតាំងនៅលើដី។ ការប្រើប្រាស់នូវសារធាតុសារធាតុគីមីមិនត្រឹមត្រូវទៅលើដំណាំកសិផលសារធាតុគីមីទាំងអស់នោះ ជ្រៀបចូលទៅក្នុងដីដែលធ្វើឱ្យមានការប៉ះពាល់នូវគុណភាពដី។ ផ្ទុយទៅវិញប្រសិនបើមានការប្រើប្រាស់សារធាតុគីមីនោះ ទៅតាមការណែនាំបានត្រឹមត្រូវ និងមិនបណ្តាលឱ្យមានផលប៉ះពាល់ដល់គុណភាពដីនោះឡើយ

**ឃ. ការបំពុលដោយសំឡេង**

សំឡេង គឺជាផ្នែកមួយដែលធ្វើឱ្យមានការបំពុលទៅដល់បរិស្ថាន។ ក្នុងនោះ មានការសង្កេតឃើញថា ក្រុងដូនកែវជាក្រុងមួយដែលទទួលរងនូវការបំពុលសំលេង ដោយសំឡេងនោះបណ្តាលមកពីកត្តាមួយចំនួន ដូចជាយានយន្ត រោងកុន ការសាងសង់នៅក្នុងការដ្ឋាន ឬសំណង់អាគារជាដើម។ យោងតាមអនុក្រឹត្យ ស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង ការបំពុលដោយសំឡេងមានប្រភពពីរគឺៈ

- **ប្រភពចល័ត** ជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍មាន យន្តហោះ នាវាដឹកជញ្ជូន គ្រឿងយន្ត និងប្រភពបំពងសំឡេងគ្រប់ប្រភេទ។ នៅក្នុងក្រុងដូនកែវគឺជា ក្រុងមួយដែលកំពុងអភិវឌ្ឍន៍ និងមានការសាងសង់នូវផ្ទះល្វែង បុរី អាគារ កត្តានៃការសាងសង់នេះ គឺតម្រូវឱ្យមានការដឹកជញ្ជូននូវសម្ភារៈសម្រាប់សាងសង់ហើយមានការផ្ទុកនូវសម្ភារៈនោះជាច្រើនជាហេតុនាំឱ្យមានសំឡេងក៏កើតមានឡើងដែរ។ កត្តាចរាចរណ៍នៅពេលដែលមានយានយន្តគ្រប់ប្រភេទចរាចរណ៍នៅលើផ្លូវថ្នល់ការជួសជុលផ្លូវវាក៏ជាកត្តាមួយបង្កើតសំឡេងដែរ។
- **ប្រភពដោយអចល័ត** ជាប្រភពដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍រួមមានដូចជា រោងចក្រសហគ្រាស ឃ្លាំងស្តុកសម្ភារៈការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ។ ចំពោះការបំពុលសំឡេងដោយប្រភពអចល័ត។ នៅក្រុងដូនកែវវិញ បណ្តាលមកពីកន្លែងកម្សាន្ត សិប្បកម្ម រោងកុន និងការបុកគ្រឹះនៅការដ្ឋានសំណង់ដែលសាងសង់នៅផ្ទះល្វែង បុរី ជាហេតុបណ្តាលឱ្យមានការបំពុលសំឡេងជារៀងរាល់ថ្ងៃ។

### ង. ការបំពុលដោយកាកសំណល់រឹង រាវ

សំណល់រឹង សំដៅលើធាតុ ឬរបស់រឹងដែលលែងប្រើប្រាស់ហើយត្រូវបានបញ្ចេញចោលពីប្រភពបំពុល។ ឯសំណល់រាវ សំដៅលើវត្ថុរាវដែលបានបញ្ចេញពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬចូលទៅក្នុងលូ ទោះបីជាបានធ្វើប្រតិកម្ម ឬមិនបានធ្វើប្រតិកម្មក្តី។ ទន្ទឹមនឹងនេះ ប្រភពសំណល់ទាំងអស់នេះ បានចេញពីប្រភពលំនៅឋានរបស់ប្រជាពលរដ្ឋ អាគាររដ្ឋបាលសាធារណៈ បរិវេនមន្ទីរពេទ្យ ដឹកជញ្ជូន និងតំបន់អាជីវកម្ម ឬសេវាកម្មដែលបានបញ្ចេញសំណល់រឹង រាវ សារធាតុពុល ឬសារធាតុដែលបង្កឱ្យមានគ្រោះថ្នាក់ ដោយផ្ទាល់ក្តី ឬមិនផ្ទាល់ក្តីចូលទៅក្នុងតំបន់សាធារណៈ។

### ២.៣.២. ដំណោះស្រាយ

នៅក្នុងក្រុងការរៀបចំក្រុងមួយ គឺតែងតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលស្របពេលដែលផែនការអភិវឌ្ឍន៍ទាំងអស់នោះត្រូវការផ្នែកធនធានមនុស្ស ថវិកា និងបញ្ចេញបច្ចេកទេសផ្សេងៗ ហើយនឹងត្រូវប្រើប្រាស់ប្រើប្រាស់រយៈពេលវែង ដែលមានន័យថាគម្រោងត្រូវចំណាយដើមទុន និងប្រើពេលវេលាយូរ។

#### ២.៣.២.១. ដំណោះស្រាយធនធានមនុស្ស

ធនធានមនុស្ស គឺជាផ្នែកមួយយ៉ាងសំខាន់សម្រាប់ក្នុងការអភិវឌ្ឍប្រទេស ហើយបច្ចុប្បន្ននេះប្រទេសកម្ពុជាបានកំពុងយកចិត្តទុកដាក់ ក្នុងការជំរុញឱ្យមានការអភិវឌ្ឍផ្នែកធនធានមនុស្ស ដើម្បីធ្វើយ៉ាងណាឱ្យប្រទេសកម្ពុជាមានធនធានគ្រប់គ្រាន់សម្រាប់បម្រើវិស័យនានាដែលកំពុងតែរីកចម្រើន។ ទោះជាយ៉ាងណាក្តី នៅតែមានបញ្ហាប្រឈមខ្លះដែលជាឧបសគ្គផ្នែកធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា។ ចំពោះបញ្ហាប្រឈមនៅក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សមានដូចជា៖

- ការគ្រប់គ្រង និងការអភិវឌ្ឍអាជីពមន្ត្រីរាជការ មិនទាន់ត្រូវបានរៀបចំជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងមិនទាន់មានការពិពណ៌នាមុខតំណែងឱ្យបានច្បាស់លាស់នៅឡើយដូចជា ដូចជាមានការបែងចែកការងារការរៀបចំការពិពណ៌នាមុខតំណែង
- ការគិតគូរអំពីតម្រូវការនៃការអភិវឌ្ឍសមត្ថភាពមន្ត្រី ដូចជាការរៀបចំការបណ្តុះបណ្តាលទៅតាមមុខតំណែង កំណត់តម្រូវការនៃការបណ្តុះបណ្តាល ការរៀបចំថវិកាសម្រាប់បណ្តុះបណ្តាល
- ការជ្រើសរើសមន្ត្រីដែលមានសមត្ថភាព និងស្របតាមតម្រូវការរបស់ក្រសួងស្ថាប័ន
- ការពង្រាយមន្ត្រី តាមជំនាញ ទីកន្លែងការងារ និងការវាយតម្លៃគុណផលមន្ត្រី

- ការលើកទឹកចិត្តមន្ត្រី ដូចជាបរិយាកាសការងារ ការឡើងថ្នាក់នឹងឋានន្តរសក្តិ ការឈបប់សម្រាក ប្រាក់បៀវត្ស
- ឥរិយាបថ និងវិន័យមន្ត្រីរាជការ។[៣៩]

### ២.៣.២.២. ដំណោះស្រាយគម្រោងថវិកា និងបច្ចេកទេស

#### ក. ដំណោះស្រាយគម្រោងថវិកា

ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំទាន់បានចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រថវិកានោះទេ ដោយការរៀបចំគម្រោងប្រចាំឆ្នាំរបស់រដ្ឋបាលទាំងនេះ គឺផ្អែកលើការអភិវឌ្ឍរយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំ រំកិលរបស់រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំរួចដាក់ជូនក្រុមប្រឹក្សារៀងៗខ្លួនដើម្បីពិនិត្យ និងអនុម័ត។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌត្រូវបញ្ជូនទៅរដ្ឋបាលរាជធានីខេត្តសាមី ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌមិនត្រូវបានបូកបញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការាជធានីខេត្តទេ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌបន្ទាប់ពីក្រុមប្រឹក្សាធ្វើការត្រួតពិនិត្យរួចរាល់ មន្ទីរសេដ្ឋកិច្ច និងហរិញ្ញវត្ថុធ្វើការបូកសរុបថវិកានេះនៅតាមបណ្តាខេត្តនីមួយៗ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ។ ថវិកាក្រុងត្រូវគ្រោងបញ្ចូលថវិកាសង្កាត់ ដែលជាថវិកាបានពីការវិភាជន៍ និងផ្ទេរពីមូលនិធិឃុំ សង្កាត់ ព្រមទាំងចំណូលផ្ទាល់នៅមូលដ្ឋាន។ អភិបាលនៃគណៈក្រុងត្រូវធ្វើការបែងចែក និងជូនដំណឹងអំពីកញ្ចប់ថវិការបស់សង្កាត់ដល់រដ្ឋបាលសង្កាត់នីមួយៗ។ គម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវបានអនុម័តជាផ្លូវការរួចរាល់ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធពត៌មានវិទ្យាសម្រាប់គ្រប់គ្រងហរិញ្ញវត្ថុសាធារណៈ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល និងចំណាយថវិការបស់ខ្លួនជាប្រចាំខែ ត្រីមាស ឆមាស និងបំណាច់ឆ្នាំរួចត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។[៤០]

#### ខ. ដំណោះស្រាយបច្ចេកទេស

បច្ចុប្បន្នប្រទេសកម្ពុជា នៅមានការខ្វះខាតអ្នកមានជំនាញបច្ចេកទេសនៅឡើយ ហើយកង្វះខាតទាំងអស់នេះក៏ព្រោះតែប្រទេសកម្ពុជា នៅជាប្រទេសកំពុងអភិវឌ្ឍន៍ ទាំងវិស័យឧស្សាហកម្ម វិស័យអភិវឌ្ឍន៍ហេដ្ឋា

[៣៩] របាយការណ៍ ស្តីពីការកែលម្អការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស របស់ឯកឧត្តម ថោ សេដ្ឋាណា

[៤០] សៀវភៅ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥, ទំព័រទី១០-១១

រចនាសម្ព័ន្ធនានា និងទៅលើផ្នែកផ្សេងៗទៀត។ ការអភិវឌ្ឍទាំងអស់នេះ គឺចាំបាច់ត្រូវការអ្នកជំនាញបច្ចេកទេសដើម្បីកសាងនូវការអភិវឌ្ឍគ្រប់វិស័យទាំងអស់។

យោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកែប្រែប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសមានចំណូលកម្រិតមធ្យមខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ដោយប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រ៤គឺៈ

- **យុទ្ធសាស្ត្រទី១ៈ** កៀងគរ និងទាក់ទាញវិនិយោគទុនផ្ទាល់ពីបរទេស និងវិនិយោគឯកជននៅក្នុងស្រុក ដោយផ្តោតលើឧស្សាហកម្មធំៗការអភិវឌ្ឍ និងការពង្រឹងទីផ្សារ និងការអភិវឌ្ឍការផ្ទេរបច្ចេកវិទ្យា
- **យុទ្ធសាស្ត្រទី២ៈ** អភិវឌ្ឍន៍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម
- **យុទ្ធសាស្ត្រទី៣ៈ** ការកែលម្អបរិស្ថាននិយ័តកម្មដើម្បីពង្រឹងភាពប្រកួតប្រជែង
- **យុទ្ធសាស្ត្រទី៤ៈ** ការអភិវឌ្ឍធនធានមនុស្ស បណ្តុះបណ្តាលជំនាញ ការកែលម្អទំនាក់ទំនងវិជ្ជាជីវៈ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជា ប្រព័ន្ធដឹកជញ្ជូន ឡូជីស្ទីក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត សេវាសាធារណៈ សេវាសង្គមកិច្ច និងសេវាហិរញ្ញវត្ថុ។[៤១]

### ២.៣.២.៣. ដំណោះស្រាយការបំពុលទាំងប្រាំ

**ក. ដំណោះស្រាយនៃការបំពុលទឹក** ដែលត្រូវយកមកអនុវត្តន៍មានដូចជាៈ

- ប្រើប្រាស់ទឹកសន្សំសំចៃខ្ពស់
- មិនត្រូវបោះចោលកាកសំណល់ទាំងឡាយណាដែលបណ្តាលឱ្យមានការកង្វក់ទឹក
- មិនត្រូវប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីគីមីដែលមិនបានត្រួតពិនិត្យត្រឹមត្រូវ
- អប់រំប្រជាជនឱ្យបានយល់ច្បាស់ពីបញ្ហាបរិស្ថាន តម្លៃនៃការខូចខាត បញ្ចូលការអប់រំបរិស្ថានក្នុងកម្មវិធីសិក្សាតាំងពីកម្រិតទាបរហូតដល់កម្រិតខ្ពស់នៃប្រព័ន្ធអប់រំ
- ក្រសួងពាក់ព័ន្ធត្រូវមានវិធានការត្រឹមត្រូវក្នុងការថែរក្សាបរិស្ថានត្រូវចេះគ្រប់គ្រង និងតាមដានជាតិពុលទាំងឡាយដែលបណ្តាលឱ្យកង្វក់ទឹក ហើយត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញនៅក្នុងការត្រួតពិនិត្យ និងចេះប្រើប្រាស់ឧបករណ៍រកជាតិពុលជាដើម
- ណែនាំអប់រំ ដល់ម្ចាស់រោងចក្រ សិប្បកម្ម សហគ្រាស រមណីយដ្ឋាន ក៏ដូចជាភោជនីយដ្ឋានឱ្យធ្វើអាងសម្អាតកាកសំណល់ទាំងឡាយមុននឹងបង្ហូរចូលទៅក្នុងទឹក

[៤១] ដកស្រង់ពីគេហទំព័រ https://educatoin.ams.com.kh/education-update/national/news/labor-official-cambodia-still-lacks-human-resources-technical-skills-while-in-high-demand/ ដកស្រង់ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤

- បង្កើតក្រុមចុះត្រួតពិនិត្យនឹងការដាក់ពិន័យចំពោះអ្នកទាំងឡាយណាដែលធ្វើឱ្យមានកង្វក់ទឹក។[៤២]

គួរបញ្ជាក់ផងដែរថា ការត្រួតពិនិត្យរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពពុល គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[៤៣] ទន្ទឹមជាមួយគ្នានេះ ត្រូវបានហាមឃាត់ជាដាច់ខាតរាល់ការចាក់ចោល ឬការបង្ហូរចេញសំណល់រាវពីប្រភពបំពុលណាមួយដែលមិនអនុវត្តន៍តាមកម្រិតស្តង់ដា នៃការបញ្ចេញសំណល់រាវ។[៤៤]

**ខ. ដំណោះស្រាយនៃការបំពុលខ្យល់**

នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេងមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ដូចជា ការរៀបចំនូវសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងការការពារគុណភាពខ្យល់ ស្តង់ដាគុណភាពខ្យល់បរិយាកាស និងខ្យល់ក្នុងអាគារស្តង់ដានៃការបញ្ចេញផ្សែងចំហាយឧស្ម័ន សំឡេង រំញ័រ ពីប្រភពចល័ត និងប្រភពអចល័ត និងស្តង់ដាសារធាតុបំពុលបរិស្ថាន ដែលមានផ្ទុកនៅក្នុងសារធាតុឥន្ទនៈផូស៊ីល ក៏ដូចជាត្រួតពិនិត្យមធ្យោបាយគ្រប់គ្រង ឬបរិក្ខាប្រព្រឹត្តកម្មផ្សែង ចំហាយឧស្ម័ន សំឡេង រំញ័រតាមទីតាំង ឬសកម្មភាពផលិតកម្ម ឬសេវាកម្មផ្សេងៗ។ ភ្ជាប់ជាមួយគ្នានេះផងដែរការត្រួតពិនិត្យនូវបរិមាណជាតិពុលសារធាតុឆេះ ការបញ្ចេញសារធាតុ បំពុលខ្យល់ និងសំឡេងពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[៤៥] ចំណែកឯការ ត្រួតពិនិត្យនូវបញ្ចេញឧស្ម័នពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថានដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។[៤៦]

**គ. ដំណោះស្រាយនៃការបំពុលដី** ដែលត្រូវយកមកអនុវត្តន៍មានដូចជា៖

- បញ្ឈប់រាល់សកម្មភាពនៃការបោះចោលសំណល់រឹងលើដី
- ត្រូវធ្វើការរៀបចំគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់សំណល់រឹងទាំងអស់ឱ្យបានល្អ
- ធ្វើការរៀបចំកន្លែង និងបច្ចេកទេសនៃការបំផ្លាញចោលនូវកាកសំណល់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមិនប៉ះពាល់ដល់បរិស្ថាន

---

[៤២] ដកស្រង់ពីគេហទំព័រ https://www.khsearch.com/qna/5111 ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៤

[៤៣] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា១៨

[៤៤] អនុក្រឹត្យលេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩, មាត្រា៦

[៤៥] អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា១៧

[៤៦] អនុក្រឹត្យលេខ ៤២ អនក្រ.បក, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា១៨

- ការកំណត់ប្រភេទ ឬកម្រាស់ និងទំហំនៃថង់ប្លាស្ទិក។ អនុក្រឹត្យស្តីពី ការគ្រប់គ្រងថង់ប្លាស្ទិកបានកំណត់ហាមឃាត់ការនាំចូល ការផលិតក្នុងស្រុក ការប្រើប្រាស់ និងចែកចាយនូវថង់ប្លាស្ទិកស្តើងមានដៃយួរគ្រប់គ្រងលើកលែងតែថង់ប្លាស្ទិកមានកម្រាស់ចាប់ពី ០.០៣មីលីម៉ែត្រឡើងទៅនិងមានរង្វាស់ទទឹងផ្នែកបាតខាងក្រោមចាប់ពី ២៥ម៉ែត្រ ឬ១០អ៊ីងឡើងទៅ
- ធ្វើការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យសាធារណជនចូលរួមក្នុងសកម្មភាពកិច្ចការពារបរិស្ថាននានា
- រាល់លំនៅឋាន ផ្សារទំនើប កន្លែងកម្សាន្ត និងស្ថាប័នទាំងអស់មានកាតព្វកិច្ចទុកដាក់ និងរៀបចំបែងចែកសំណល់រឹងដាច់ដោយឡែកពីសំណល់ផ្សេងៗទៀតតាមគោលការណ៍របស់ក្រសួងបរិស្ថាន
- រាល់ការប្រមូល ស្តុកទុក ដោះបំបែក ធ្វើប្រតិកម្ម ឬបោះបង់ សំណល់រឹង ត្រូវអនុវត្តន៍ឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន
- ហាមដាច់ខាតរាល់ការដុត ឬវាយបំបែកសំណល់ដែលបង្កឱ្យមានផលប៉ះពាល់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ និងបរិស្ថាន។ ឧទាហរណ៍ដូចជា សំណល់អាគុយ សំណល់ថ្មពិល ឬ សំណល់បរិក្ខាអគ្គិសនី និងអេឡិចត្រូនិច។[៤៧]

**ឃ. ដំណោះស្រាយដោយបំពុលសំឡេង**

ដោយយោងតាមអនុក្រឹត្យស្តីពីការបំពុលខ្យល់ និងការរំខានដោយសំលេង បានកំណត់អំពីការត្រួតពិនិត្យនូវសំឡេងរំខានពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។[៤៨] ចំពោះត្រួតពិនិត្យនូវការរំខានដោយសំឡេងពីប្រភពចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យត្រូវធ្វើការពិនិត្យដោយប្រកាសរួមរបស់អន្តរក្រសួង។[៤៩]

**ង. ដំណោះស្រាយការបំពុលពីសំណល់រឹង រាវ**

តាមការប្រកាសអន្តរក្រសួងលេខ ៨០ រវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាននៅក្នុងឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម និងកាកសំណល់រឹងនៅក្នុងថ្នាក់ខេត្ត ក្រុង មានវិសាលភាពគ្រប់គ្រងសំណល់រឹងទាំងឡាយដោយរាប់បញ្ចូលទាំងការប្រមូលការសម្អាត ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ និងការបោះចោលសំរាមសំណល់រឹងគ្រប់ប្រភេទ ដែលមានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់

[៤៧] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិច, លេខ ១៦៨ អនក្រ.បក, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧, មាត្រា១៤

[៤៨] អនុក្រឹត្យលេខ ៤២ អនក្រ.បក, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា១៧

[៤៩] អនុក្រឹត្យលេខ ៤២ អនក្រ.បក, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០, មាត្រា១៨

អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធនានា។ ក្នុងការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងនៅថ្នាក់រាជធានី ខេត្ត ក្រុងប្រកបដោយប្រសិទ្ធភាពទូទាំងប្រទេស។ ប្រកាសអន្តរក្រសួងលេខ៨០ ផ្តល់ឱ្យអាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- ការដាក់ធុងសំរាមឱ្យបានគ្រប់គ្រងដើម្បីធានានូវសោភ័ណភាព និងបរិស្ថាន
- ដាក់ស្លាកហាមឃាត់ចោលសំរាម និងអប់រំឱ្យមានការទុកដាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ
- រៀបចំ និងកំណត់ទីលានចាក់សំរាម សំណល់រឹងបណ្តោះអាសន្នឱ្យបានសមរម្យ ដោយគ្មានការរំខានដល់ចរាចរណ៍ សុខភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម
- ប្រមូលសំរាម និងដឹកជញ្ជូនសំរាម សំណល់រឹងបោះចោលឱ្យបានទៀងទាត់ នៅទីលានចាក់សំរាមដែលបានកំណត់ដោយអាជ្ញាធរដែនដី និងសមត្ថកិច្ចដែលពាក់ព័ន្ធ
- ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានការសហការជាមួយស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនានាត្រូវអប់រំផ្សព្វផ្សាយព័ត៌មានទៅដល់សាធារណជន អំពីការទុកដាក់សំរាម សំណល់រឹងតាមរយៈវិធីសាស្ត្រប្រកបដោយអនាម័យ និងសុវត្ថិភាពបរិស្ថាន។ ដើម្បីកាត់បន្ថយសំរាម សំណល់រឹង ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវតែជំរុញ និងលើកទឹកចិត្តឱ្យមានសកម្មភាពកែច្នៃសំរាម ឬដំណើរការកែច្នៃសំរាមនៅក្នុងមូលដ្ឋានរបស់ខ្លួន
- មន្ទីរបរិស្ថានខេត្តក្រុង និងការិយាល័យបរិស្ថានស្រុកខណ្ឌត្រូវដើរតួនាទីជាសេនាធិការឱ្យអាជ្ញាធរមូលដ្ឋាន ក្នុងការរៀបចំផែនការគ្រប់គ្រង ដូចជាចូលរួមសកម្មភាពក្នុងការប្រមូលការស្តុកសំរាមបណ្តោះអាសន្ន ការដឹកជញ្ជូន ការចាក់សំរាមក្នុងទីលានចាក់សំរាមដោយត្រូវសហការ និងតាមដានការអនុវត្តផែនការទាំងនោះផងដែរ។ ត្រូវរាយការណ៍អំពីការអនុវត្តផែនការសកម្មភាពអំពីការប្រមូលការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់សំរាមដោយត្រូវធ្វើរបាយការណ៍នេះត្រូវកាន់ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានព្រមទាំងក្រសួងមានការពាក់ព័ន្ធទៀតផង។[៥០]

ដោយយោងតាមអនុក្រឹត្យលេខ ១១៣ ដែលទទួលបានការអនុម័តកាលពីខែសីហា ឆ្នាំ២០១៥ បានកំណត់អាណត្តិកាន់តែច្បាស់លាស់ និងមានភាពល្អប្រសើរដល់រដ្ឋបាលក្រុង ស្រុក ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង។ ដោយអនុក្រឹត្យនេះ មានគោលបំណង នៅក្នុងការពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា លើការគ្រប់គ្រងសំរាម សំណល់រឹងទៅតាមទី

[៥០] ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងនៅក្នុងថ្នាក់ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា, លេខ ៨០, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣

ប្រជុំជនប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារនៃការគ្រប់គ្រងសំណល់រឹង ទីប្រជុំរដ្ឋបាលរាជធានីទៅឱ្យរដ្ឋបាលខណ្ឌកំណត់រកវិធានការចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាព សុវត្ថិភាពក្នុងការគ្រប់គ្រងសំរាមសម្រាប់សំណល់រឹងទីប្រជុំជនលើកកម្ពស់ការយល់ដឹងសាធារណៈ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុវត្តវិធានការគ្រប់គ្រងសំណល់រឹងទីប្រជុំជន។[៥១]

## ២.៤. លទ្ធផលសម្រេចបាន និងទិសដៅអនាគត

### ២.៤.១. ស្ថានភាពបច្ចុប្បន្ន

នៅក្នុងភូមិសាស្ត្ររដ្ឋបាលក្រុងដូនកែវចែកចេញជា ០៣សង្កាត់ ៤០ភូមិ មានក្រុមប្រឹក្សាក្រុងនៃអាណត្តិទី៣ ចំនួន ១៧នាក់ ស្រី០៤នាក់ និងក្រុមប្រឹក្សាសង្កាត់អាណត្តិទី៤ ចំនួន ២៩នាក់ ស្រី០៦នាក់។ លើសពីនេះក្រុងដូនកែវ ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ដោយគណៈអភិបាលក្រុង ០៥នាក់ ស្រី០១នាក់ ដែលជាសេនាធិការផ្ទាល់របស់ក្រុមប្រឹក្សាក្រុង ក្នុងការរៀបចំកម្មវិធីវិនិយោគដើម្បីអនុវត្តផែនការ និងសម្របសម្រួលកិច្ចការទូទៅដូចជាការងារសម្របសម្រួលកិច្ចអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិបរិស្ថាន និងរដ្ឋបាលសន្តិសុខសណ្តាប់ធ្នាប់សាធារណៈផ្សេងៗ។

ក្រុងដូនកែវមានផ្ទៃដីសរុបចំនួន ៩.៤៦៩,២២ហិកតា ចែកចេញជាលំនៅដ្ឋាន ១.០៧៩,៥៩ហិកតា ផ្ទៃដីស្រែវស្សាចំនួន ៣.៥០០ហិកតា ដីស្រែប្រាំងចំនួន ៣.០០០ហិកតា ដីចំការ ១៦២,២២ហិកតា និងផ្ទៃដីផ្សេងៗ ១.៧២៧,៤១ហិកតា។ ក្រុងដូនកែវមានគ្រួសារសរុបប្រមាណ ៩.៥៧១ គ្រួសារ មានប្រជាពលរដ្ឋសរុបប្រមាណ ៤៥.២៥១នាក់ ស្រីប្រមាណ ២៣.២៤៦នាក់ អាយុ១៨ឆ្នាំឡើងសរុបប្រមាណ ២៩.៨៩៥នាក់ ស្រីប្រមាណ ១៥.៤៤២នាក់ដង់ស៊ីតេប្រជាជន ៤៧៨នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា។

សម្រាប់ឆ្នាំ២០២១ ជាឆ្នាំទី៣ នៃអាណត្តិទី៣ របស់ក្រុមប្រឹក្សាក្រុង ដែលត្រូវបានបោះឆ្នោត នៅខែឧសភា ឆ្នាំ២០១៩ ដោយទទួលបានជោគជ័យ ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្រុមប្រឹក្សាក្រុងរួមជាមួយគណៈ អភិបាលក្រុងបានអនុវត្តន៍នូវតួនាទីភារកិច្ចរបស់ខ្លួនដើម្បីអភិបាលកិច្ចល្អ និងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានស្របតាមច្បាប់គោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តិនានា។ ក្រុងដូនកែវបានរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ២០២០-២០២៤ របស់ខ្លួន តាមរយៈការពិគ្រោះយោបល់

[៥១] អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥, មាត្រា២

ជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដែលផែនការអភិវឌ្ឍន៍នេះបានកំណត់ អំពីយុទ្ធសាស្ត្រសំខាន់ៗសកម្មភាពជាអាទិភាពសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៅក្រុងដូនកែវ។

ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង បន្ទាប់ពីបានរៀបចំកសាងផែនការអភិវឌ្ឍន៍ ៥ឆ្នាំក្រុង ២០២០-២០២៤ និងបានបន្តរៀបចំកម្មវិធីវិនិយោគបីឆ្នាំ២០២២-២០២៤បន្តទៀត។ ដោយយោងតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ ២១៩ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា ១២ អនុក្រឹត្យ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីបីឆ្នាំរំកិលរាជធានី ខេត្ត ស្រុក ខណ្ឌ។ កម្មវិធីបីឆ្នាំរំកិលក្រុងដូនកែវ បានរៀបចំឡើងតាមសេចក្តីណែនាំ ដោយមានការចូលរួម ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សហគមន៍ មូលដ្ឋាន ក្រុមតំណាងផលប្រយោជន៍ជាពិសេសក្រុមយុវជន និងកុមារ ក្រុមប្រឹក្សាសង្កាត់ ការិយាល័យរដ្ឋបាលក្រុង អង្គការសង្គមស៊ីវិល វិស័យឯកជន អ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ច របស់ក្រុងក្នុងការវិភាគស្ថានភាព សក្តានុពល បញ្ហាប្រឈម និងតម្រូវការនានាដោយលើកឡើងថាជាសំណើគម្រោងដែលមាន លក្ខណៈចាំបាច់សម្រាប់បម្រើផលប្រយោជន៍ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

កម្មវិធីបីឆ្នាំរំកិលក្រុងដូនកែវបានកំណត់អំពីគម្រោងវិនិយោគបីឆ្នាំរំកិលក្រុង មូលនិធិគាំទ្រតាមប្រភពក្របខណ្ឌចំណាយរយៈពេលមធ្យម (បីឆ្នាំ) និងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោង ដែលជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន និងសក្តានុពលនានាដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកម្ពស់គុណភាពសេវាសំដៅឆ្លើយតបតម្រូវការប្រជាពលរដ្ឋ និងចូលរួមកាត់បន្ថយភាពក្រីក្រ។

កម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២២-២០២៤) ក្រុងដូនកែវមានបីជំពូក ជំពូកទី១ បរិយាយអំពីស្ថានភាពសេដ្ឋកិច្ច ជំពូកទី២ បរិយាយអំពី គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល ជំពូកទី៣ បរិយាយអំពីការតាមដានការត្រួតពិនិត្យសម្រាប់រយៈពេលបីឆ្នាំខាងមុខ។[៥២]

### ២.៤.២. ផ្នែកសង្គមកិច្ច

ភាពរើសអើងលើជនពិការ អ្នកជម្ងឺអេសដ៍ ចាស់ជរាគ្មានទីពឹង កុមាររងគ្រោះ ងាយរងគ្រោះដោយជម្ងឺអេសដ៍ និងឪពុកម្តាយបោះបង់ចោល នៅមានខ្លះនៅក្នុងសង្គមយើងក៏ដូចជានៅក្នុងក្រុងដូនកែវផងដែរ។

[៥២] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី៥

ដើម្បីកាត់បន្ថយភាពអសកម្ម ក៏ដូចជាកាត់បន្ថយដើម្បីឈានទៅលុបបំបាត់ចោល ដោយធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងការរើសអើងជនពិការ កុមាររងគ្រោះ ងាយរងគ្រោះដោយមេរោគអេសដ៍ និងឪពុកម្តាយបោះបង់ចោលជាដើម។ ការបង្កើតសមាគមមនុស្សចាស់មានអាយុលើសពី ៦០ឆ្នាំ មានទីពឹង និងគ្មានទីពឹងត្រូវបានលើកឡើងក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២២-២០២៤)។[៥៣]

➢ **វិស័យអប់រំ**

រហូតមកដល់ឆ្នាំសិក្សា(២០២១-២០២២) នេះ ក្នុងក្រុងដូនកែវមានសាលារៀនសរុបចំនួន២១សាលា ក្នុងនោះមានវិទ្យាល័យចំនួន ២សាលា មាន៦២ថ្នាក់ មានបុគ្គលិកសិក្សាចំនួន ១៦៨នាក់ ក្នុងនោះមានស្រី ៦៤នាក់ មានសិស្សចំនួន ២.៦៧៩នាក់ ក្នុងនោះមានស្រី១.៤៥៨នាក់ និងអនុវិទ្យាល័យ ៣សាលាមានថ្នាក់រៀនចំនួន ២១ថ្នាក់ មានបុគ្គលិកសិក្សាចំនួន ៥៩នាក់ ក្នុងនោះមានស្រី ២៤នាក់ មានសិស្សសរុប ៨០៨នាក់ ក្នុងនោះមានស្រី ៤៣៧នាក់។ បឋមសិក្សាមានចំនួន ១៣សាលា មានថ្នាក់រៀនចំនួន ១៣៤ថ្នាក់ មានបុគ្គលិកសិក្សាចំនួន ២២០នាក់ ក្នុងនោះមានស្រី ១០២នាក់ សិស្សសរុប ៤.៣៣០នាក់ ស្រី ២.១០៣នាក់។ មតេយ្យសិក្សារដ្ឋមានចំនួន ១៤សាលា មាន ២៣ថ្នាក់ មានបុគ្គលិកសិក្សាចំនួន ២៤នាក់ ក្នុងនោះមានស្រីចំនួន ២២នាក់ សិស្ស ៦៨៧នាក់ ក្នុងនោះមានស្រី ៣២៧នាក់។ អក្ខរកម្ម០៣សាលា មាន០៣ថ្នាក់មានបុគ្គលិកសិក្សាចំនួន ៣នាក់ ក្នុងនោះមានស្រីចំនួន ០១នាក់ មានសិស្សចំនួន ៥៥នាក់ ក្នុងនោះមានស្រី ១៨នាក់។ មត្តេយ្យសហគមន៍មានចំនួន ០២សាលា មាន០២ថ្នាក់ មានបុគ្គលិកសិក្សាសរុបចំនួន ០២នាក់ ក្នុងនោះមានស្រីចំនួន ០២នាក់ មានសិស្ស៤៣នាក់ ក្នុងនោះមានស្រី ២៤នាក់។ មត្តេយ្យឯកជនមាន ០៥សាលា ថ្នាក់រៀនមានចំនួន ១៣ថ្នាក់ មានសិស្សចំនួន ៣៩២នាក់ ក្នុងនោះមានស្រី ១៧៦នាក់ មានបុគ្គលិកសិក្សាចំនួន ១៧នាក់ ក្នុងនោះមានស្រី ១៧នាក់។ សាលាចំណេះទូទៅឯកជន ០៣សាលាមាន ៤២ថ្នាក់ មានបុគ្គលិកសិក្សាចំនួន ១០៣ថ្នាក់ ក្នុងនោះមានស្រីចំនួន ៤៤នាក់ សិស្ស ៨៧៨នាក់ ក្នុងនោះមានស្រីចំនួន ៤១៤នាក់។ ដោយសារកត្តាជីវភាពគ្រួសារ បរិស្ថានសាលារៀនគ្មានការទាក់ទាញ និងកម្រិតនៅការយល់ដឹងរបស់អាណាព្យាបាលទាបនៅក្នុងឆ្នាំសិក្សា ២០១៩-២០២០ មានកុមារ អាយុពី៣-៥ឆ្នាំ បានចូលរៀននៅមត្តេយ្យ មានកម្រិតទាបស្មើ ៥៥.៣៦% កុមារអាយុចាប់ពី ៦-១១ឆ្នាំ មិនបានចូលរៀននៅបឋមសិក្សាស្មើ ១០.៨៣% និងកុមារដែលមានអាយុពី ១២-១៤ឆ្នាំ មិនបានរៀន មាន១៨.៩១%។ ក្រុងដូនកែវ មានសក្តានុពលវិស័យអប់រំ ដោយមានសាលារៀនច្រើនយោងលើផែនការអភិវឌ្ឍន៍ក៏ដូចជាគោលនយោបាយអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជាកុមារបោះបង់ការសិក្សាមុនថ្នាក់មូលដ្ឋានមានកម្រិតទាបបំផុត។ ដូចនេះគោលដៅអាទិភាព

[៥៣] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី១៣

គឺការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ការសាងសង់រូបសំណាក់ ព្រះមហាក្សត្រ ព្រះបាទជ័យវរ្ម័ន វិរបុរស និងការថែរក្សានូវបរិស្ថាន សាលារៀនស្អាត ដើម្បីទាក់ទាញអារម្មណ៍ឱ្យចង់មករៀន។[៥៤]

- **វិស័យសុខាភិបាល និងស្រុកប្រតិបត្តិដូនកែវ**

ក្រុងដូនកែវ ជាទីប្រជុំជនចំពោះការផ្តល់សេវាសុខភាពមានទាំង មន្ទីរពេទ្យ មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និងសេវាឯកជន។ ផ្នែករដ្ឋមានមន្ទីរសុខាភិបាលខេត្ត ការិយាល័យស្រុកប្រតិបត្តិដូនកែវ មន្ទីរពេទ្យបង្អែកខេត្តតាកែវ មន្ទីរពេទ្យភ្នែកខេត្តតាកែវ មណ្ឌលសុខភាពមាន ០៣កន្លែង (រកាក្នុង រកាក្រៅ បារាយណ៍) (គ្លីនិចរក្សាសុខភាព, គ្លីនិចរក្សាសុខ, គ្លីនិចរិទ្ធយ៉ាន, គ្លីនិចសុមិនា) បន្ទប់ព្យាបាលមាន ៤៩កន្លែង ឱសថស្ថានមាន ២១កន្លែង សុទ្ធសឹងជាកន្លែងផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋ។ សម្រាប់ទិន្នន័យ ២០២១នេះ មានការកាត់បន្ថយនូវការឈឺ ស្លាប់របស់មាតា ទារក និងការលើកម្ពស់សេវាសុខភាពដូចជាការពិនិត្យផ្ទៃពោះមុនពេលសម្រាល៤ដង ឬលើសនេះបាន ៨៥% សម្រាលដោយសុវត្ថិភាពបាន ១០០% កុមារអាយុពី១២ខែ ដល់៥៩ខែ ដែលបានទទួលមេបង់ដាហ្សូលបាន ១០០% បានចុះអប់រំដល់សិស្សសាលាចំនួន៥០% បានផ្តល់អាហារបំប៉នគម្រូម្តងក្នុង ១សប្តាហ៍បាន ៤៥% បានចុះអភិបាលចំនួន ១២ដងក្នុង ១ឆ្នាំ។

មូលហេតុដោយសារកូវីដ ចុះរាតត្បាតបន្ថែមលើសពីនេះ មានជម្ងឺកូវីដ រាតត្បាតដូចជាបុគ្គលិកសុខាភិបាលមមាញឹក និងការងារកូវីដ ដែលក្រុមគ្រូពេទ្យត្រូវប្រឈមមុខនឹងការខ្វះបុគ្គលិកក៏ដូចជាធនធានមនុស្ស និងធនធានសម្ភារៈបានធ្វើចត្តាឡីស័ក និងប្រជាជនចំណុចដែលមានការសង្ស័យ និងពលករមកពីក្រៅប្រទេស។

ចំពោះសុខភាពកុមារបានចុះត្រួតពិនិត្យ រលាកផ្លូវដង្ហើមចំនួន ១២ដងក្នុង១ឆ្នាំ កុមារអាយុក្រោម ១ឆ្នាំបានចាក់ថ្នាំបង្ការជម្ងឺកញ្ច្រឹលបាន ១០០% បានផ្សព្វផ្សាយជម្ងឺគ្រុនឈាម១ដង ក្នុង១ឆ្នាំ។ ការប្រយុទ្ធប្រឆាំងជម្ងឺឆ្លងចំពោះការបង្ការជម្ងឺអេសដ៍ នៅមណ្ឌលសុខភាពបានដំណើរការនូវការផ្តល់សេវាប្រឹក្សា និងការតេស្តដោយសម្ងាត់បាន ១០០% រីឯការថែទាំ និងការព្យាបាលដែលប្រើប្រាស់ឱសថប្រឆាំងមេរោគស្វាយបាន ៧០%។ ទោះបី មានភាពប្រសើរខាងលើក៏នៅតែមានចំណុចខ្វះខាតមួយចំនួនយើងបានលើកឡើងទៅក្នុងគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់ក្រុង (២០២២-២០២៤)។[៥៥]

[៥៤] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី១១

[៥៥] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី១២

➢ **វិស័យផែនការ**

ទិន្នន័យ ជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់ក្រុងដូនកែវ។ រៀងរាល់បំណាច់ឆ្នាំនីមួយៗយើងបានបើកវគ្គបណ្តុះបណ្តាល សង្កាត់ និងភូមិ តាមនីតិវិធីក្នុងការប្រមូលទិន្នន័យឱ្យបានជាក់លាក់សុក្រឹត្យត្រឹមត្រូវច្បាស់លាស់ យើងបានចាត់អាទិភាពនៅក្នុងគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២២-២០២៤)។[៥៦]

### ២.៤.៣. ទិសដៅអនាគត

នៅក្នុងទិសដៅអនាគតនេះ មានគោលដៅនៅក្នុងការធានា និងការអភិវឌ្ឍក្រុងដូនកែវប្រកបដោយចីរភាព និងបរិយាបន្ន គណៈកម្មាធិការរៀបចំដែនដីរូបនីយកម្ម និងគណៈកម្មាធិការរៀបចំ និងនគរូបនីយកម្មក្រុងដូនកែវក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០ ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងតម្រង់ទិសការអភិវឌ្ឍដែនដីក្រុងដូនកែវទាំងមូល ស្របតាមចក្ខុវិស័យតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវត្រូវបានកសាងឡើង ដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ ប្រជាសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្ម មានជាអាទិ៍ គោលនយោបាយដីធ្លី សៀវភៅដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលនិយាយពីគោលនយោបាយជាតិ ស្តីពីលំនៅឋាន ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីការគ្រប់គ្រងអាងទន្លេ អនុក្រឹត្យស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តី

[៥៦] សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤, ទំព័រទី១៣

សម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវមានលក្ខណៈទូលំទូលាយ គ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេសសម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្នឆ្លើយតបទៅនឹងកំណើនប្រជាជន តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន ការអភិវឌ្ឍគ្រប់វិស័យក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានទឹក ទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិដែលអាចធ្វើការអភិវឌ្ឍឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ សោភ័ណភាព ចីរភាព និងចូលរួមបង្ការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ ដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅ ទឹកជំនន់ និងខ្យល់ព្យុះជាដើម។[៥៧]

### ២.៤.៣.១. យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

ដើម្បីធានានូវការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងក្រុងដូនកែវ ប្រកបដោយផាសុកភាព សុខដុមរមនា ចាំបាច់ត្រូវយកចិត្តទុកដាក់ជាចម្បងលើលំនៅដ្ឋានសមស្របចំណូល និងការងារមុខរបរចិញ្ចឹមជីវិត និងការជួយសង្គ្រោះ បានទាន់ពេលវេលាមានគ្រោះថ្នាក់ ឬហានិភ័យជាយថាហេតុកើតឡើង។ ដូចនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ចរួមមាន៖

- ធ្វើអត្តសញ្ញាណប័ណ្ណ និងកំណត់ទីតាំង ដើម្បីដោះស្រាយសំណង់មិនមានរបៀបរៀបរយនៅលើដីសាធារណៈរបស់រដ្ឋ និងដីឯកជន ជាពិសេសនៅតាមមាត់ប្រឡាយ ដងផ្លូវសាធារណៈ មាត់បឹង ជិតសួនច្បារ វិមានឯករាជ្យ ផ្សារណាត់ជាដើម ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគក្នុងការសាងសង់លំនៅដ្ឋានឱ្យមានតម្លៃសមរម្យសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប
- លើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលលើការងារមនុស្សធម៌សម្រាប់ប្រជាជនក្រីក្រ ពង្រឹងការបម្រើសេវាកម្មរដ្ឋបាលសាធារណៈ អភិបាលកិច្ចល្អ និងលើកទឹកចិត្តការប្រតិបត្តិការតាមច្រកចេញចូលតែមួយ ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដោះស្រាយហានិភ័យសង្គ្រោះបន្ទាន់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងគ្រោះមហន្តរាយនានា ដូចជាគ្រោះអគ្គិភ័យ ទឹកជំនន់ និងបាតុភូតធម្មជាតិផ្សេងៗ។[៥៨]

[៥៧] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី២

[៥៨] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី២៧

### ២.៤.៣.២. យុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធ

ក្រុងដូនកែវត្រូវបានគិតគូរ និងយកចិត្តទុកដាក់ខ្ពស់លើការកែលម្អ និងអភិវឌ្ឍន៍បណ្តាញផ្លូវថ្នល់ ផ្លូវទឹក និងការគ្រប់គ្រងធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកទេស ពត៌មានវិទ្យា គមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធដើម្បីត្រៀមខ្លួនឆ្លើយតបនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធនានា។

- **អ័ក្សអភិវឌ្ឍទេសចរណ៍ពាណិជ្ជកម្ម រាជធានីភ្នំពេញ ខេត្តតាកែវ តំបន់ឆ្នេរសមុទ្រ និងច្រកទ្វារអន្តរជាតិ**

ផ្លូវជាតិលេខ២ ជាផ្លូវជាតិសំខាន់ជាងគេ និងផ្លូវជាតិលេខ២២ ដែលតភ្ជាប់ទៅផ្លូវជាតិលេខ៣ ដែលមានតួនាទីជាអ័ក្សអភិវឌ្ឍទេសចរណ៍-ពាណិជ្ជកម្ម ចាំបាច់ពង្រឹងទទឹងផ្លូវដែលមានស្រាប់ និងធ្វើការសាងសង់ផ្លូវវាងក្រុងបន្ថែមដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូន និងចរាចរណ៍។[៥៩]

- **ផ្លូវថ្នល់**

ការរៀបចំ និងកែលម្អផ្លូវពាណិជ្ជកម្ម ដោយកំណត់យកផ្លូវជាតិលេខ២ ឆ្លងកាត់ក្រុងដូនកែវជាមហាវិថីទេសចរណ៍ក្រុងដូនកែវ ជំរុញការកសាងផ្លូវវាងក្រុង និងបណ្តាញផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៣ ដើម្បីបញ្ចៀសរថយន្តដឹកទំនិញធន់ធ្ងន់ចូលក្នុងក្រុង និងកាត់បន្ថយបញ្ហាការកកស្ទះចរាចរណ៍ គ្រោះថ្នាក់ចរាចរណ៍លើកកម្ពស់បរិស្ថានក្រុង សណ្តាប់ធ្នាប់ក្រុង និងសោភ័ណភាពក្រុង។ បង្កើតបណ្តាញផ្លូវតភ្ជាប់ទំនាក់ទំនងវាងក្នុងទីប្រជុំក្រុងទៅតំបន់ជាយក្រុង ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរ រៀបចំឱ្យមានភ្លើងសញ្ញាចរាចរណ៍ ភ្លើងបំភ្លឺនៅតាមដងផ្លូវ ផ្លាកសញ្ញា គំនូសសញ្ញាចរាចរណ៍ លេខផ្លូវឱ្យបានត្រឹមត្រូវ និងគ្រប់ផ្លូវ។ រៀបចំចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង ផ្លូវជិះកង់ ផ្លូវសម្រាប់ជនពិការភាព ចំណតរថយន្តសាធារណៈសម្រាប់មនុស្សទាំងអស់គ្នារួមទាំងជនពិការភាព និងជនដែលងាយរងគ្រោះអាចធ្វើដំណើរបានប្រកបដោយភាពងាយស្រួលដើម្បីសុវត្ថិភាពបង្កើតផ្លូវថ្មី និងតភ្ជាប់កំណាត់ផ្លូវដែលទាល់ ដើម្បីឆ្លើយតបទៅតម្រូវការចរាចរណ៍បច្ចុប្បន្ន និងអនាគត លើកទឹកចិត្តអ្នកចូលរួមគាំទ្រក្នុងការពង្រីកផ្លូវនៅតាមមូលដ្ឋាន ដើម្បីសម្រួលចរាចរណ៍ធ្វើដំណើរទៅវិញទៅមកដើម្បីកំណត់ទីតាំងសម្រាប់រៀបចំដាក់ចំណតរថយន្តក្រុង និងចំណតទូទៅនៅក្នុងទីប្រជុំក្រុង និងតាមសង្កាត់ ពង្រីក និងកែលម្អបណ្តាញផ្លូវទាំងអស់ឱ្យមានទំហំសមស្រប និងបណ្តាញបៃតងមានសោភ័ណភាពប្រទាក់ក្រឡាគ្នាជាប្រព័ន្ធនគរូបនីយកម្មមានជាអាទិ៍មហាវិថី វិថី រុក្ខវិថី អនុវិថី និងផ្លូវបម្រើឱ្យការធ្វើដំណើរ ដឹកជញ្ជូន ផ្លូវជិះកង់ ផ្លូវថ្មើរជើង និងផ្លូវសម្រាប់ជនពិការភាព ដើម្បីបង្កើតឱ្យមានជាលក្ខណៈលម្អ

[៥៩] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី១៩

សាធារណៈសម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងដំណោះស្រាយចរាចរណ៍ដ៏ល្អប្រសើរសម្រាប់ក្រុងដូនកែវ។[៦០]

❖ **ផ្លូវទឹក**

ការរៀបចំមធ្យោបាយសម្រាប់ធ្វើដំណើរតាមផ្លូវទឹកឱ្យបានច្រើនប្រភេទ ដើម្បីសម្រួលដល់ការធ្វើដំណើរទូទៅនៅវិស័យទេសចរណ៍ និងការប្រកបរបរ រៀបចំកែលម្អ និងសាងសង់កំពង់ផែសម្រាប់អ្នកដំណើរ និងទេសចរណ៍ និងកំពង់ផែលើកដាក់ដឹកជញ្ជូនទំនិញចេញចូលនៅទីតាំងសមស្រប។ រៀបចំ និងបង្កើនមធ្យោបាយទេសចរណ៍ផ្លូវទឹកឱ្យបានច្រើនដើម្បីទាក់ទាញភ្ញៀវទេសចរ និងកំណើនសេដ្ឋកិច្ច។ កែលម្អ ស្តារ និងកសាងបណ្តាញផ្លូវទឹកនៅតាមដងស្ទឹង ព្រែក អូរ ប្រឡាញ បឹង សម្រាប់បម្រើនូវវិស័យទេសចរណ៍ និងកសិកម្ម ជំរុញផ្គត់ផ្គង់ទឹក រំដោះទឹកជំនន់ រៀបចំប្រព័ន្ធដឹកជញ្ជូនឱ្យបានល្អប្រសើរ និងមធ្យោបាយដឹកជញ្ជូនស្របតាមតម្រូវការ។[៦១]

❖ **ការគ្រប់គ្រងធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត**

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងនៅក្នុងក្រុងដូនកែវ។ ប្រព័ន្ធដែលមានស្រាប់នេះត្រូវបានកែលម្អ និងពង្រីកបន្ថែម ដើម្បីរក្សាតុល្យភាពជាមួយកំណើនប្រជាជន។ ដូចនេះយុទ្ធសាស្ត្រគ្រប់គ្រងធនធានទឹក និងផ្គត់ផ្គង់ទឹកស្អាតរួមមានៈ

- បន្តលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតដោយយកចិត្តទុកដាក់លើគុណភាព និងបរិមាណ
- គ្រប់គ្រងធនធានទឹកដែលមានប្រភពពីទឹកភ្លៀងសម្រាប់សម្អាតទីក្រុង និងស្រោចដំណាំ
- សិក្សាពីជលសាស្ត្រ និងត្រួតពិនិត្យតាមដាន ដើម្បីធានានូវបរិមាណទឹកស្អាតនៃធនធានទឹកដែលអាចមានសិក្សាពីប្រភពទឹកបឹង និងស្ទឹង ដើម្បីធានានូវសក្តានុពលនៃទឹកក្រោមដី ដើម្បីផ្គត់ផ្គង់ទឹកស្អាតតំបន់ក្រុងស្តារឡើងវិញ និងដោះស្រាយដូរបំពង់ទឹកចាស់ៗ ដើម្បីកាត់បន្ថយការលេចធ្លាយ និងបង្កើតបានគុណភាពទឹកតាមតម្រូវការជាក់ស្តែង ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើន និងការប្រើប្រាស់រៀបចំស្តារ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតដោយក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាតក្រុងដូនកែវដល់ប្រជាជនក្នុងក្រុងឱ្យបាន ១០០%

[៦០] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី២០

[៦១] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី២០

- ពង្រីកបណ្តាញចែកចាយទឹក ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុន និងដើម្បីបង្កើនប្រាក់ចំណូល បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស ជំរុញរៀបចំប្រព័ន្ធឆ្លាត ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវា និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។[៦២]

❖ **ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាពត៌មាន និងគមនាគមន៍**

យុទ្ធសាស្ត្រផ្គត់ផ្គង់ថាមពលអគ្គិសនី ទូរគមនាគមន៍ បច្ចេកវិទ្យាពត៌មាន និងគមនាគមន៍រួមមាន៖

- ពង្រីក និងកែលម្អបណ្តាញអគ្គិសនីដែលមានស្រាប់ ដើម្បីថែរក្សាតុល្យភាពទៅនឹងកំណើនប្រជាជន និងតម្រូវការផ្គត់ផ្គង់អគ្គិសនីនៅក្រុងដែលមានកំណើនខ្ពស់ រៀបចំ ជួសជុល កែលម្អ និងសាងសង់បង្គោលភ្លើងបំភ្លឺផ្លូវថ្មី និងបណ្តាញខ្សែភ្លើងថ្មីសម្រាប់គ្រប់គ្រង និងចែកចាយអគ្គិសនីឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ចៀសវាងការបង្កគ្រោះថ្នាក់ និងបាត់បង់សោភ័ណភាពក្រុង ពង្រីកបណ្តាញអគ្គិសនីបន្ថែមទៅកាន់សង្កាត់បារាយណ៍នៃក្រុងដូនកែវ
- រៀបចំផ្លូវរង្វង់មូលនិងបំពាក់ភ្លើងស្តុបនៅតាមផ្លូវដែលមានចរាចរណ៍ច្រើន ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ សុវត្ថិភាពតាមដងផ្លូវ ជំរុញ និងលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ ជំរុញលទ្ធភាពរៀបចំបណ្តាញអគ្គិសនីឬបណ្តាញបញ្ជូនអគ្គិសនី បណ្តាញទូរគមនាគមន៍ខ្សែកាបគ្រប់ប្រភេទកប់ក្នុងដី ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងរក្សាដល់សោភ័ណភាពក្រុង
- ជំរុញការវិនិយោគ ការប្រើប្រាស់បច្ចេកវិទ្យាពត៌មាន និងគមនាគមន៍ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចទេសចរណ៍ ពាណិជ្ជកម្ម ឧស្សាហកម្ម និងលំនៅឋាន
- ប្រើប្រាស់បច្ចេកវិទ្យាពត៌មានវិទ្យា ទូរគមនាគមន៍ និងបច្ចេកវិទ្យាទំនើប ដើម្បីជួយសម្រួលដល់ការអភិវឌ្ឍ ការផ្តល់សេវា ប្រតិបត្តិការ ដំណោះស្រាយបញ្ហាក្នុងគោលដៅបង្កើនប្រសិទ្ធភាព និងការប្រកួតប្រជែងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន វប្បធម៌ ដោយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនបច្ចុប្បន្ន និងធានាបានចីរភាពសម្រាប់អនាគត ជំរុញអភិវឌ្ឍន៍មជ្ឈមណ្ឌលជាក្រុងតំបន់ឆ្លាតដោយផ្តោតលើវិស័យទូរគមនាគមន៍ ដឹកជញ្ជូនសាធារណៈ សន្តិសុខ និងសុវត្ថិភាព អភិវឌ្ឍន៍តំបន់នៃនគរូបនីយកម្ម និងសំណង់ ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹកស្អាត ការគ្រប់គ្រងសំណល់រឹងរាវ គ្រប់គ្រងរដ្ឋបាលការផ្តល់សេវាសាធារណៈ និងវិស័យផ្សេងទៀតស្របតាមសក្តានុពលរបស់តំបន់

[៦២] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី២១

- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធបណ្ដាញមេ បណ្ដាញចែកចាយ និងស្ថានីយទូរគមនាគមន៍ក្នុងតំបន់ជុំវិញ ដូចជាសេវាអ៊ីនធើណេតសាធារណៈ និងមជ្ឈមណ្ឌលទិន្នន័យព័ត៌មានវិទ្យា។[៦៣]

❖ **ហេដ្ឋារចនាសម្ព័ន្ធសង្គម**

យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមរួមមាន៖

- ស្ដារ និងរៀបចំលម្អសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនាសម្រាប់មនុស្សគ្រប់គ្នា រួមមានកុមារ យុវជន ស្ត្រីមានគភ៌ មនុស្សវ័យចាស់ និងជនពិការភាពឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌។ រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការភាព និងបង្គន់អនាម័យសម្រាប់ជនមានពិការភាពនៅតាមសាធារណៈ អគារសាធារណៈ និងកន្លែងផ្ដល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈគ្រប់កម្រិតនៅតាមភូមិសាស្ត្រក្នុងក្រុងស្របតាមបទបញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្ម និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យ ឱសថស្ថាន នៅតាមភូមិសាស្ត្រក្នុងក្រុងស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល ថែរក្សាទីតាំងវប្បធម៌ សាសនា និងសម្បត្តិបេតិកភណ្ឌដូចជាវត្តអារាម ព្រះពុទ្ធសាសនា ប្រាសាទបុរាណជាដើម។ ការរៀបចំឱ្យមានសួនជ្រាបទឹកនៅតាមហេដ្ឋារចនាសម្ព័ន្ធសង្គម។[៦៤]

### ២.៤.៣.៣. យុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យទឹកស្អាត

❖ **ការគ្រប់គ្រងធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត**

- សិក្សាផែនការមេ និងជម្រើសបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងទឹកស្អាត ធនធានទឹក ត្រួតពិនិត្យឱ្យអ្នកបានប្រើប្រាស់បណ្ដាញផ្គត់ផ្គង់ទឹកស្អាត
- បំពាក់បំពង់បង្ហូរទឹកថ្មីដែលមានគុណភាពខ្ពស់ជំនួសបំពង់ទឹកចាស់ៗ អភិវឌ្ឍន៍ប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មី អភិវឌ្ឍន៍រោងចក្រចម្រុះទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្រុងដូនកែវ។

[៦៣] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី២២

[៦៤] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី២២

❖ **ការគ្រប់គ្រងទឹកកខ្វក់**

- ស្តារ និងកែលម្អប្រឡាយទឹកកខ្វក់ចំនួន ០៤ខ្សែ កែលម្អ និងរៀបចំស្ថានីយបូមទឹកចំនួន ១២កន្លែង នៅសង្កាត់ទាំង៣
- ពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅ និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់
- ណែនាំម្ចាស់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងអនាម័យត្រឹមត្រូវលើកកម្ពស់ប្រព័ន្ធបង្ហូរទឹកកខ្វក់
- អភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹកថ្មីក្នុងក្រុង
- គ្រប់គ្រងសំណល់រាវក្នុងក្រុង និងប្រព្រឹត្តកម្មទឹកកខ្វក់ ជាពិសេសតំបន់លំនៅឋានថ្មីដែលត្រូវពង្រីកនៅប៉ែកខាងត្បូងក្រុង សាងសង់ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងក្រុងដូនកែវ។[៦៥]

[៦៥] ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០, ទំព័រទី៣៣-៣៤

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើរួចមក យើងសង្កេតឃើញថាក្នុងការរៀបចំទីក្រុងមួយឱ្យមាននៅសណ្តាប់ធ្នាប់ និងមានសោភ័ណភាព គឺពិតជារឿងមួយដ៏សំខាន់ ព្រោះការរៀបចំទីក្រុងមួយប្រកបដោយសោភ័ណភាព គឺជាកត្តាមួយដែលជួយជម្រុញឱ្យមានការរីកចម្រើនលើគ្រប់វិស័យទាំងអស់ទាំងវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងបរិស្ថាន ជាពិសេសការគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ និងសេវាសាធារណៈផងដែរ។ ក្នុងនោះផងដែរ ក្រុងដូនកែវ គឺជាតំបន់មួយដែលកំពុងកែប្រែខ្លួន និងកំពុងអភិវឌ្ឍន៍យ៉ាងឆាប់រហ័សដើម្បីជាចំណែកមួយក្នុងការដែលធ្វើឱ្យខេត្តតាកែវមានការអភិវឌ្ឍ។ ដូច្នេះហើយទើបលោកអភិបាលក្រុង រួមជាមួយអាជ្ញាធរដែលពាក់ព័ន្ធ កំពុងតែខិតខំព្យាយាម ត្រៀមរៀបចំទីក្រុងដូនកែវឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ តាមរយៈការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ ស្ពាន បណ្តាញលូ និងប្រព័ន្ធរំដោះទឹកផ្សេងៗទៀតផងដែរ។ ម្យ៉ាងទៀតទីក្រុងមួយដែលមានសោភ័ណភាព និងសណ្តាប់ធ្នាប់លុះត្រាតែគ្មានការបំពុលទាំងប្រាំ។ លើសពីនេះទៅទៀតការរៀបចំក្រុង គឺចាំបាច់បំផុតត្រូវរៀបចំឱ្យមានប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី និងលិខិតសាងសងសំណង់ឱ្យបានច្បាស់លាស់ជាមុនសិន ព្រោះថាប្លង់គោលជាឯកសារមួយដែលមិនអាចខ្វះបាន ត្រូវតែគោរពតាមប្លង់គោលជាដាច់ខាត បើមិនដូច្នេះទេ សំណង់ទាំងនេះមិនអនុញ្ញាតអោយសាងសង់នោះឡើយ។ ចំពោះប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ក៏មានសារៈសំខាន់ផងដែរ។ ព្រោះប្លង់នេះក៏បានកំណត់យ៉ាងច្បាស់អំពីតំបន់ដែលត្រូវប្រើប្រាស់ សម្រាប់ការពារជាតិសម្រាប់ កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ ទេសចរណ៍ ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខាសាធារណៈ។ ម្យ៉ាងវិញទៀតប្លង់នេះកំណត់ផងដែរនូវលទ្ធភាព សម្រាប់សាងសង់ព្រមទាំងគោរពទៅតាមប្លង់គោល។

លើសពីនេះទៅទៀតតាមរយៈកិច្ចខិតខំប្រឹងប្រែងកន្លងមកនេះ ក៏បានជួបប្រទះនូវបញ្ហាមួយចំនួនផងដែរ ជាការពិតគម្រោង នៃការអភិវឌ្ឍក្រុងនីមួយៗ គឺត្រូវចំណាយរយៈពេលច្រើនដើម្បីសិក្សា និងទាមទារនូវជំនាញដែលមានបច្ចេកវិទ្យា និងបច្ចេកទេសខ្ពស់ ជាពិសេសតម្រូវការថវិកាច្រើន ដែលនេះជាបញ្ហាប្រឈមក្នុងការរៀបចំក្រុង។ ទោះជាយ៉ាងណាក្តី ការរៀបចំក្រុងនៅតែអាចបន្តទៅមុខបន្តិចម្តងៗបានក្រោមជំនួយឧបត្ថម្ភផ្សេងៗទាំងថវិកា និងសម្ភារៈបច្ចេកទេសផងដែរ។ អ្វីដែលសំខាន់ក្នុងការរៀបចំក្រុងនោះ លុះត្រាតែមានការចូលរួមសហការគ្នាពីអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់រួមជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋានផងដែរ។

សរុបជារួមមក ការរៀបចំក្រុងឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ និងមានរបៀបរៀបរយល្អ គឺដើម្បីបម្រើផលប្រយោជន៍រួម និងបានជួយសម្រួលដល់ផលវិបាករបស់ប្រជាពលរដ្ឋគ្រប់ៗគ្នាឱ្យមានសុវត្ថិភាពក្នុងការរស់នៅជាពិសេសបានរួមចំណែកក្នុងការលើកមុខមាត់ក្រុងដូនកែវខេត្តតាកែវទាំងមូលផងដែរ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើឃើញថា ថ្វីត្បិតតែលោកអភិបាល និងអាជ្ញាធរក្រុងដូនកែវបាន ខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀបចំសោភ័ណភាព សណ្តាប់ធ្នាប់ និងអភិវឌ្ឍន៍ក្រុងដូនកែវក៏ពិតមែន។ ប៉ុន្តែឃើញថាការរៀបចំ និងអភិវឌ្ឍន៍ក្រុងដូនកែវនេះ បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនហើយនៅមាន ចំណុចខ្វះខាតជាច្រើនផងដែរ ហើយពុំទាន់បានបំពេញតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅឡើយទេ ជាមួយនឹងបញ្ហានេះ ក៏ជាបញ្ហាប្រឈមដែលប្រជាពលរដ្ឋចង់ឱ្យអាជ្ញាធរធ្វើការដោះស្រាយ និងកែលម្អ ជាពិសេស ទាក់ទងទៅនឹងបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈផងដែរ។ ដើម្បីដោះស្រាយនូវបញ្ហាខាងលើនេះបាន ក្រុមយើងខ្ញុំសូមជូនជាមតិយោបល់ ដើម្បីស្នើសុំ និងសំណូមពរមួយចំនួនទៅដល់លោកអភិបាល អាជ្ញាធរ ក្រុងដូនកែវមានដូចជា៖

- អាជ្ញាធរក្រុងដូនកែវ គួរតែធ្វើការរៀបចំសោភ័ណភាពមាត់បឹងក្រុងដូនកែវ និងត្រង់ចំណុចរង្វង់មូល វិមានឯករាជ្យឱ្យបានកាន់តែស្អាត ដើម្បីជាការទាក់ទាញភ្ញៀវដែលមកកម្សាន្ត ក៏ដូចជាប្រជាពលរដ្ឋ អាចមកអង្គុយលេងកម្សាន្តនៅតាមមាត់ទន្លេស្រូបយកខ្យល់អាកាស និងដើរហាត់ប្រាណប្រកបដោយ ជាសុកភាពផងដែរ។
- សំណូមពរដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ឱ្យជួយរិះរកមធ្យោបាយ និងបច្ចេកវិទ្យាជួយដល់ការកាត់បន្ថយ ការបំពុលបរិស្ថានពីកត្តាផ្សេងៗជាពិសេសពីផ្សែងដែលចេញពីយានយន្ត និងគ្រឿងចក្រផ្សេងៗក៏ដូចជា រោងចក្រជាដើម។
- សំណូមពរឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ គួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ទៅលើបញ្ហាបរិស្ថានដែល កើតមាននៅក្នុងក្រុងដូនកែវ ជាពិសេសបញ្ហាសំរាមដែលមិនទាន់មានការរៀបចំ និងទុកដាក់ឱ្យ បានត្រឹមត្រូវនៅឡើយ។ អាជ្ញាធរ គួរតែធ្វើការណែនាំដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងពីការទុកដាក់ សំរាម និងអនាម័យដើម្បីសោភ័ណភាពរបស់ក្រុងដូនកែវ។
- សំណូមពរឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ គួរតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ទៅលើបញ្ហាមួយចំនួនដូចជា សន្តិសុខ សណ្តាប់ធ្នាប់ និងបង្កើនការបង្ក្រាបក៏ដូចជាទប់ស្កាត់នូវបញ្ហាចោរកម្ម ល្បែងស៊ីសង និង បទល្មើសគ្រប់ប្រភេទ ក្មេងទំនើង និងត្រួតពិនិត្យទៅលើបញ្ហាបរិស្ថាន ដើម្បីកុំឱ្យមានផលប៉ះពាល់ ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងបរិយាកាសក្នុងក្រុងដូនកែវខេត្តតាកែវ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសារយោងជាលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨
- អនុក្រឹត្យ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣, លេខ ២២.អនក្រ.បក, ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិច, លេខ ១៦៨ អនក្រ.បក, ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧
- អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ ១១៣ អនក្រ.បក, ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០
- អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក, លេខ ២៧ អនក្រ.បក, ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩
- ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងនៅក្នុងថ្នាក់ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា, លេខ ៨០, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣
- សេចក្តីណែនាំ ស្តីពីចំណីអាហារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន, លេខ ១៨ អយក.សណន, ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩
- សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ក្រុង, ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧

- ផែនការណែនាំ ស្តីពីការចាត់តាំងអនុវត្តន៍គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព, លេខ០២០ ផ.ក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០
- របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងដូនកែវប្រចាំឆ្នាំ២០២៣
- របាយការណ៍ស្តីពីការកែលម្អការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស របស់ឯកឧត្តម ថោ សេដ្ឋាណា

## ២. ឯកសារយោងជាសៀវភៅតែងនិពន្ធ

- វចនានុក្រម សម្តេចព្រះមហាសង្ឃរាជ ជួន ណាត
- សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣
- សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលក្រុងដូនកែវ ខេត្តតាកែវ ឆ្នាំ២០២២-២០២៤
- សៀវភៅ ប្លង់គោលប្រើប្រាស់ដីក្រុងដូនកែវចក្ខុវិស័យឆ្នាំ២០៤០
- សៀវភៅ យុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធចវិការរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥

## ៣. ឯកសារយោងគេហទំព័រផ្សេងៗ

- គេហទំព័រ https://www.khsearch.com/qna/5111
- គេហទំព័រ https://educatoin.ams.com.kh/education-update/national/news/labor-official-cambodia-still-lacks-human-resources-technical-skills-while-in-high-demand/

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/ ៥០៨/ ០១៧, ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣, លេខ ២២. អនក្រ.បក, ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្ស គណៈអភិបាលស្រុក, លេខ ២១៦ អន ក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង, លេខ ៤២ អនក្រ.បក, ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

## ២. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីរូបភាពពីលើអាកាសក្រុងដូនកែវ

**ឧបសម្ព័ន្ធទី២៖** ទីតាំងសំខាន់ៗក្នុងក្រុងដូនកែវ

**ឧបសម្ព័ន្ធទី៣៖** សកម្មភាព និងសមិទ្ធផលផ្សេងៗក្នុងក្រុងដូនកែវ

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាន អនុម័តកាលពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៨ នា សម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបាន ប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងរដ្ឋបាល

# រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ជំពូកទី ១

## អំពីបទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ២.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**មាត្រា ៣.-**

ឃុំ សង្កាត់ត្រូវគ្រប់គ្រងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លើកលែងតែបញ្ហាទាំងឡាយណាដែលបានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ចែកជាខណ្ឌ ។

ខណ្ឌ ចែកជាសង្កាត់ ។

**មាត្រា ៥.-**

ខេត្ត ចែកជាក្រុង និងជាស្រុក ។

ក្រុង ចែកជាសង្កាត់ ។

ស្រុក ចែកជាឃុំ និងជាសង្កាត់ ។

**មាត្រា ៦.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះខេត្ត ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួង

ការកំណត់ព្រំប្រទល់រាជធានីភ្នំពេញ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧.-**

ការបង្កើត ការលុបចោល ការកែប្រែព្រំប្រទល់ និងការកំណត់ឈ្មោះក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៨.-**

ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន ។

**មាត្រា ៩.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជានីតិបុគ្គលនៃនីតិសាធារណៈ ។

**មាត្រា ១០.-**

នីតិបុគ្គលនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយជាតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**មាត្រា ១១.-**

នីតិបុគ្គលនីមួយៗត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**មាត្រា ១២.-**

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមាន :

-ភាពជាតំណាងសាធារណៈ

-ស្វ័យភាពរបស់មូលដ្ឋាន

-ការពិគ្រោះយោបល់ និងការចូលរួម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

-ការឆ្លើយតប និងគណនេយ្យភាព

-ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន

-ការលើកស្ទួយសមធម៌

-តម្លាភាព និងសុចរិតភាព

-វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

**មាត្រា ១៣.-**

នីតិបុគ្គលទទួលសិទ្ធិអំណាចរបស់ខ្លួន ដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដទៃទៀត ដែលស្របនឹងច្បាប់នេះ ។

## ជំពូកទី ២
## អំពីក្រុមប្រឹក្សា

### ផ្នែកទី ១
### ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**មាត្រា ១៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា “ក្រុមប្រឹក្សា” ។

**មាត្រា ១៥.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

ROYAUME DU CAMBODGE • MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**មាត្រា ១៦.-**

ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ ។

**មាត្រា ១៧.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។

ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខ-ជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ។

ក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសរើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។

**មាត្រា ១៨.-**

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រនិងកត្តាភូមិសាស្ត្រ ដូចខាងក្រោម :

-ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន(០៩)រូប ដល់ម្ភៃមួយ(២១)រូប

-ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំ(១៥)រូប

-ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ(០៧)រូប ដល់ដប់ប្រាំបួន(១៩)រូប ។

ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា ។

ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះ ចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗ ត្រូវយកតាមចំនួនសរុបរបស់ក្រុមប្រឹក្សាអាណត្តិចាស់ ។

**មាត្រា ១៩.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២០.-**

ក្រុមប្រឹក្សានីមួយៗ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ២១.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិ ដូចខាងក្រោម :

-មានសញ្ជាតិខ្មែរពីកំណើត

-មានអាយុយ៉ាងតិចម្ភៃប្រាំ(២៥)ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ២២.-**

សមាជិកក្រុមប្រឹក្សាម្នាក់ ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម :

-សាមីខ្លួនបាត់បង់លក្ខណសម្បត្តិ និងលក្ខខណ្ឌ សម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា

-សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពីពីរ(០២)ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

-សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬ បទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវសម្រេច និងប្រកាសពីការបាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ក្នុងករណីដូចខាងលើនេះ ។

**មាត្រា ២៣.-**

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួស ក្នុងរយៈពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៤.-**

ប្រសិនបើក្រុមប្រឹក្សាណាមួយអនុវត្តផ្ទុយពីបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញ ឬ ច្បាប់ ឬ ព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំជាលាយលក្ខណ៍អក្សរដល់ក្រុមប្រឹក្សានោះឱ្យគោរព និងអនុវត្តបទប្បញ្ញត្តិទាំងនោះ នៅក្នុងអំឡុងពេលជាក់លាក់ និងសមហេតុផល ។

ក្នុងករណីក្រុមប្រឹក្សានោះនៅតែមិនព្រមអនុវត្តតាមការណែនាំ រាជរដ្ឋាភិបាលត្រូវរំសាយក្រុមប្រឹក្សានោះដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សា ក្នុងករណីណាមួយដូចខាងក្រោម :

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីដូចមានចែងក្នុងមាត្រា ៦ និងមាត្រា ៧ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប (២៤០)ថ្ងៃ

-ក្រុមប្រឹក្សាដែលត្រូវរំសាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០)ថ្ងៃ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះ ។

**មាត្រា ២៦.-**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយ ប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

**មាត្រា ២៧.-**

ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

**មាត្រា ២៨.-**

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។

ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

**មាត្រា ២៩.-**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ ។

**មាត្រា ៣០.-**

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាង

**មាត្រា ៣១.-**

ក្រុមប្រឹក្សា ត្រូវបំពេញមុខងារ និងភារកិច្ច ដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះត្រូវបានអនុវត្ត ។

**មាត្រា ៣២.-**

ក្រុមប្រឹក្សា ប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីកា ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ២ នៃច្បាប់នេះ ។

**មាត្រា ៣៣.-**

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេច នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ។

**មាត្រា ៣៤.-**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាលនិងអភិបាល ។

**មាត្រា ៣៥.-**

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា ។

**មាត្រា ៣៦.-**

នៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬ ដីកាតាមការចាំបាច់ទាក់ទិនទៅនឹង :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ (៥) ឆ្នាំ រួមទាំងសមាសភាគនៃផែនការនោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ

-កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

**មាត្រា ៣៧.-**

ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ។

**មាត្រា ៣៨.-**

ក្នុងការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ :

-ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

-ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

នីតិវិធីនៃការពិគ្រោះយោបល់នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៣៩.-**

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍ ដែលរួមមាន :

-ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

-ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍសំខាន់ៗរួមមាន :

+ តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ

+ សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់នានា

+ ការកាត់បន្ថយភាពក្រីក្រ

+ តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ រួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

-ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នោះ

-ផែនការគ្រប់គ្រងគ្រោះមហន្តរាយ

-ផែនការហិរញ្ញវត្ថុ ដោយត្រូវរាប់បញ្ចូលទាំងផែនការអភិវឌ្ឍមូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ (១២) ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី (៣)ឆ្នាំចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

-យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍ ដើម្បីធានាឱ្យមានតម្លាភាពនិងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

ROYAUME DU CAMBODGE LE MINISTÈRE DU PALAIS ROYAL

-សូចនាករបំពេញការងារសំខាន់ៗ និងគោលដៅនានាទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍ

ក្រុមប្រឹក្សាត្រូវកំណត់ឱ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ។

បែបបទ នីតិវិធីជាក់ស្ដែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

## មាត្រា ៤០.-

ក្រុមប្រឹក្សា ត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំ ទៅលើការអនុវត្តផែនការអភិវឌ្ឍរបស់ខ្លួន ដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ :

-ក្រុមប្រឹក្សាប្រភេទរួមគ្នា

-ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត

-ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

-អ្នកពាក់ព័ន្ធនានា។

## មាត្រា ៤១.-

ក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍបន្ទាប់ពីបានអនុម័តរួចហើយភ្លាម ។

សាធារណជន អាចពិនិត្យឯកសារផែនការនេះ នៅការិយាល័យរបស់ក្រុមប្រឹក្សា ដោយឥតគិតថ្លៃ ឬ អាចស្នើសុំជាវឯកសារផែនការនេះពីក្រុមប្រឹក្សា ដោយគិតត្រឹមតម្លៃដើម ។

## មាត្រា ៤២.-

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដែលផ្ដោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

-តម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំសម្រាប់ទទួលមុខងារ ភារកិច្ច និងធនធានថ្មីៗ

-សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាន និងចាំបាច់

-ការកាត់បន្ថយភាពក្រីក្រ

-តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្រុមជនងាយរងគ្រោះដោយរួមបញ្ចូលទាំងជនក្រីក្រ ជនជាតិដើមភាគតិច ។

**មាត្រា ៤៣.-**

ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុ ឱ្យមានតម្លាភាព និងមានគណនេយ្យភាព ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ។

**មាត្រា ៤៤.-**

រាជធានី ខេត្ត ក្រុង ស្រុក ត្រូវមានថវិកាផ្ទាល់របស់ខ្លួន ដែលហៅកាត់ថាថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ។

ខណ្ឌ និងសង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់រាជធានី ។

សង្កាត់ចំណុះក្រុង ត្រូវមានថវិការបស់ខ្លួននៅក្នុងថវិការបស់ក្រុង ។

ក្រុមប្រឹក្សាត្រូវអនុម័តលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីនិងប្រតិទិននៃការកសាងថវិការដ្ឋជារៀងរាល់ឆ្នាំ ។

ក្រុមប្រឹក្សាត្រូវអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងនិងការអនុវត្តគម្រោងថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវរៀបចំឡើងដោយគោរពតាមគោលការណ៍សំខាន់ៗទាំងអស់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ត្រូវពិនិត្យឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ដើម្បីស្នើធ្វើវិសោធនកម្ម ឬ ដាក់ចេញនូវលិខិតបទដ្ឋានថ្មី ឱ្យសមស្របសម្រាប់ទ្រទ្រង់ដល់គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលចែងក្នុងច្បាប់នេះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ២៨៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨៦.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញ្ញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី២៤ ខែឧសភាឆ្នាំ ២០០៨.

ចរល.០៥០៨.៥៥៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខ: ៥៥៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៨
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត របស់ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង របស់ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ព្រមទាំងទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ក្នុងខេត្ត និងរដ្ឋបាលទាំងនេះជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

រដ្ឋបាលខេត្តដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត ។

រដ្ឋបាលក្រុងដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលក្រុង ។

រដ្ឋបាលស្រុកដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ។

**មាត្រា ៣.-**

ខេត្ត ក្រុង ស្រុក ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ ។

**មាត្រា ៤.-**

ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងខេត្ត ត្រូវមានក្រុមប្រឹក្សារៀង១ខ្លួនជាតំណាង ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៥.-**

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ទទួលសិទ្ធិអំណាចរបស់ខ្លួនដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

## ជំពូកទី២

## រដ្ឋបាលខេត្ត

### ផ្នែកទី១

### ក្រុមប្រឹក្សាខេត្ត

**មាត្រា ៦.-**

ក្រុមប្រឹក្សាខេត្តដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ

ជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៧.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលនៅជាធរមាន។

**មាត្រា ៨.-**

ក្រុមប្រឹក្សាខេត្ត មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៩.-**

ក្នុងអំឡុងត្រីមាសទី៤នៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាខេត្តត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នៅតាមក្រុងនិងស្រុកនានាក្នុងខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត សមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីឱ្យក្រុមប្រឹក្សាខេត្តជម្រាបជូនក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានា អំពីសកម្មភាពរបស់ក្រុមប្រឹក្សាខេត្តក្នុងរយៈពេលមួយ(០១)ឆ្នាំ ការឆ្លើយតបចំពោះសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ការពិភាក្សាស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម និងការប្រមូលមតិយោបល់នានាពីអ្នកចូលរួម ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាខេត្ត ជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ។

គណៈអភិបាលខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុប វាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះយ៉ាងយូរដប់ប្រាំ(១៥)ថ្ងៃបន្ទាប់។ ក្នុងការបូកសរុបវាយតម្លៃនេះ ត្រូវលើកឡើងនូវគោលការណ៍ វិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ក្នុងក្របខ័ណ្ឌតួនាទីសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត។ ចំពោះកិច្ចការទាំងឡាយណា ដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលខេត្តត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងអំពីគោលការណ៍ វិធានការ ដោះស្រាយ

តាមសមត្ថកិច្ចរៀងៗខ្លួន។ ចំពោះកិច្ចការដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ថ្នាក់ជាតិ រដ្ឋបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា ១០.-**

ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះ ត្រូវបានអនុវត្តដោយមានការតាមដាននិងវាយតម្លៃជាប្រចាំ។

**មាត្រា ១១.-**

កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត អាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

សេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាខេត្ត អាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះ គណៈអភិបាលខេត្តត្រូវដឹកនាំនាយករដ្ឋបាលសាលាខេត្ត និងទីចាត់ការពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

គណៈអភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ទីចាត់ការនានានៃសាលាខេត្ត រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យពិភាក្សា និងអនុម័ត។

អភិបាលខេត្ត ត្រូវណែនាំនាយករដ្ឋបាលសាលាខេត្ត ឱ្យរៀបចំដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច ឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលខេត្ត។

ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យអភិបាលខេត្តចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**មាត្រា ១៣.-**

ប្រធានក្រុមប្រឹក្សាខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលខេត្តលើ :

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខេត្ត
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាខេត្ត
- សំណើដកហូតអភិបាលខេត្តឬអភិបាលរងខេត្តចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខេត្ត
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តរយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខេត្ត
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលខេត្ត ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

**មាត្រា ១៤.-**

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលខេត្ត និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារ តាមការចាំបាច់ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាខេត្ត
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត

- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាខេត្ត ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៥.-**

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខេត្តត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំដូចមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាខេត្តអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន :

- ការកោះអញ្ជើញអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬគណៈអភិបាលខេត្ត ឬបុគ្គលដែលពាក់ព័ន្ធ មកសាកសួរអំពីការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ឬហេតុការណ៍ណាមួយដែលកើតមានក្នុងខេត្ត ឬការដោះស្រាយបញ្ហាបន្ទាន់និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលខេត្ត
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តយល់ថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលខេត្តអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យ ស្រាវជ្រាវ និងការធ្វើសេចក្ដីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាខេត្ត ឬសមាជិកក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលខេត្ត
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្តយល់ឃើញថាចាំបាច់។

**មាត្រា ១៦.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនេះ។

ក្នុងករណីកិច្ចការណាមួយដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទនិងនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាខេត្តមិនអាចអនុវត្តបាន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយករណីនេះ។

**មាត្រា ១៧.-**

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាខេត្តបានសម្រេចរួចហើយ គណៈអភិបាលខេត្តត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សាខេត្ត ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលខេត្ត ដើម្បីធានាថាគណៈអភិបាលខេត្តអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាខេត្តក្នុងការរៀបចំនូវប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត។

## ផ្នែកទី២

## អំពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត

**មាត្រា ១៨.-**

ក្រុមប្រឹក្សាខេត្ត ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានគតិយុត្តស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ។

**មាត្រា ១៩.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាខេត្តអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឡើយ។

ក្រុមប្រឹក្សាខេត្តអាចបង្កើតអនុគណៈកម្មាធិការឬក្រុមការងារផ្សេងៗទៀត តាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលខេត្ត។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលខេត្ត។

**មាត្រា ២០.-**

ក្រុមប្រឹក្សាខេត្ត អាចតែងតាំងសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត អភិបាលរងខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តំណាងក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង។

ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬ អនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង។

ក្រុមប្រឹក្សាខេត្ត អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង តាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខេត្ត។

**មាត្រា ២១.-**

គណៈអភិបាលខេត្ត អាចស្នើសុំក្រុមប្រឹក្សាខេត្តដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវឱ្យបង្កើតឡើងដោយ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត។

**មាត្រា ២២.-**

ក្រុមប្រឹក្សាខេត្ត ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

**មាត្រា ២៣.-**

ក្រុមប្រឹក្សាខេត្ត ត្រូវណែនាំឱ្យគណៈអភិបាលខេត្តផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង។

**មាត្រា ២៤.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលខេត្ត ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត។

ក្រុមប្រឹក្សាខេត្ត អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

## ផ្នែកទី៣

## គណៈអភិបាលខេត្ត

**មាត្រា ២៥.-**

ខេត្តនីមួយៗ ត្រូវមានគណៈអភិបាលខេត្តមួយដែលរួមមាន អភិបាលខេត្ត អភិបាលរងខេត្ត ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២៦.-**

អភិបាលខេត្ត អភិបាលរងខេត្ត មិនមែនជាសមាជិកក្រុមប្រឹក្សាខេត្តឡើយ។

**មាត្រា ២៧.-**

គណៈអភិបាលខេត្ត ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ២៨.-**

គណៈអភិបាលខេត្ត មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាខេត្ត និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។

**មាត្រា ២៩.-**

គណៈអភិបាលខេត្ត ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខេត្ត ដើម្បីក្រុមប្រឹក្សាខេត្តធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាខេត្ត និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរសក្តិ និងការបញ្ឈប់បុគ្គលិក
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យ និងអនុម័តមិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :
  + ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខេត្ត និងសកម្មភាព លទ្ធផលនៃការអនុវត្ត
  + របាយការណ៍ហិរញ្ញវត្ថុ
  + ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខេត្តនិងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
  + វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត

+ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ

+ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាខេត្តយល់ឃើញថា ចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្ដារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៣០.-**

នៅពេលបានទទួលរបាយការណ៍ឬព័ត៌មានអំពីការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលខេត្តត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលខេត្តត្រូវធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាខេត្តនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៣១.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា២៩ និងមាត្រា៣០ នៃអនុក្រឹត្យនេះ និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលខេត្តត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួនដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាខេត្តអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលខេត្ត លើភារកិច្ចនានាដែលបានប្រគល់ ហើយត្រូវរួមជាមួយអភិបាលខេត្តទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលខេត្តត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាសនិងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលខេត្តអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ៣២.-**

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្ត ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។

**មាត្រា ៣៣.-**

គណៈអភិបាលខេត្ត ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលខេត្ត និងអភិបាលរងខេត្ត ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលខេត្ត អភិបាលរងខេត្ត និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ៣៤.-**

អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។

អភិបាលខេត្ត អាចប្រគល់សិទ្ធិដល់អភិបាលរងខេត្តក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងខេត្តនីមួយៗ។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខេត្ត។

អភិបាលខេត្ត មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខេត្តណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលខេត្តត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ៣៥.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខេត្ត អភិបាលខេត្តមានភារកិច្ច ៖

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ

- សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាខេត្ត។
- ពិនិត្យ វាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា តាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុន ក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខេត្ត។ ក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីពិនិត្យពិចារណា។ ក្នុងករណីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប។ ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថា ហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្តពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្ត ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាពរវាងអភិបាលខេត្ត ជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទៅលើបេក្ខភាពដែលស្នើតែងតាំងនោះ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ សម្រេច។ អភិបាលខេត្តត្រូវរាយការណ៍ករណីនេះជូនក្រុមប្រឹក្សារបស់ខ្លួននិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយ ឬការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយ អភិបាលខេត្តត្រូវធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះ ឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់។ ក្នុងករណីប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតីឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ អភិបាលខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារទាំងនោះ។ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីដោះស្រាយទៅតាមច្បាប់។

– អភិបាលខេត្ត មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងនូវប្រធានមន្ទីរ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយដែលប្រព្រឹត្តខុសឆ្គង ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

ដើម្បីធានាឱ្យអភិបាលខេត្តអនុវត្តនូវតួនាទី ភារកិច្ចខាងលើនេះ សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ត្រូវដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យ ផ្តល់យោបល់ជាមុន។ ប្រសិនបើឯកភាព អភិបាលខេត្តត្រូវចុះហត្ថលេខាលើរបាយការណ៍នេះជាមួយប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ត្រូវចម្លងជូនសាលាខេត្ត។

**មាត្រា ៣៦.-**

អភិបាលខេត្ត ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត។

អភិបាលខេត្ត គឺជាប្រធានគណៈបញ្ជាការឯកភាពខេត្ត ក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត។

**មាត្រា ៣៧.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃអនុក្រឹត្យនេះ អភិបាលខេត្តត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងខេត្តក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយក្នុងការងារខាងលើនេះ។

អភិបាលរងខេត្តដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលខេត្ត។

អភិបាលខេត្ត ត្រូវកោះប្រជុំគណៈអភិបាលខេត្តតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលខេត្ត សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ។

**មាត្រា ៣៨.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា៣៥និងមាត្រា៣៦នៃអនុក្រឹត្យនេះ អភិបាលខេត្តត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្រុមប្រឹក្សាស្រុក អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចាំបាច់ឬតាមសំណើរបស់គណៈកម្មាធិការឬគណៈអភិបាលស្រុក។

**មាត្រា ១៣៩.-**

គណៈអភិបាលស្រុក អាចស្នើសុំក្រុមប្រឹក្សាស្រុកដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលស្រុក។

**មាត្រា ១៤០.-**

ក្រុមប្រឹក្សាស្រុក ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានានិងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

**មាត្រា ១៤១.-**

ក្រុមប្រឹក្សាស្រុក ត្រូវណែនាំឱ្យគណៈអភិបាលស្រុកផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាស្រុកបានបង្កើតឡើង។

**មាត្រា ១៤២.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្តីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលស្រុក ដើម្បីធ្វើការបូកសរុបនិងរាយការណ៍ជូនក្រុមប្រឹក្សា។

ក្រុមប្រឹក្សាស្រុក អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយ ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាស្រុកតាមការចាំបាច់របស់ខ្លួន។

## ផ្នែកទី៣

## គណៈអភិបាលស្រុក

**មាត្រា ១៤៣.-**

ស្រុកនីមួយៗ ត្រូវមានគណៈអភិបាលមួយដែលរួមមាន អភិបាល អភិបាលរង ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៤៤.-**

អភិបាល អភិបាលរងស្រុក មិនមែនជាសមាជិកក្រុមប្រឹក្សាស្រុកឡើយ។

**មាត្រា ១៤៥.-**

គណៈអភិបាលស្រុក ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុកនិងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៤៦.-**

គណៈអភិបាលស្រុក មានភារកិច្ចផ្ដល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាស្រុក និងជាអ្នកអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាស្រុក ទាំងសេចក្ដីសម្រេចខាងបញ្ញត្តិនិងសេចក្ដីសម្រេចខាងប្រតិបត្តិ។

**មាត្រា ១៤៧.-**

គណៈអភិបាលស្រុក ត្រូវធ្វើការសិក្សាស្រាវជ្រាវដើម្បីផ្ដល់យោបល់ជូនក្រុមប្រឹក្សាស្រុកអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាស្រុកនិងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រនិងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឬបានផ្ទេរស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការងារហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ស្រុក
- ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការកំណត់នីតិវិធីរដ្ឋបាលនិងហិរញ្ញវត្ថុសម្រាប់ការិយាល័យនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាស្រុកពិនិត្យនិងអនុម័ត មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :

+ ដីកានិងសេចក្ដីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាស្រុកនិងសកម្មភាព លទ្ធផលនៃការអនុវត្ត
+ របាយការណ៍ហិរញ្ញវត្ថុ
+ ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលនិងបុគ្គលិក
+ វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
+ វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
+ កិច្ចការផ្សេងៗទៀតដែលក្រុមប្រឹក្សាស្រុកយល់ឃើញថាចាំបាច់ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការវាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក និងតម្រូវការគាំទ្រចំពោះឃុំ សង្កាត់ក្នុងស្រុក
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាស្រុក
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជាការរៀបចំក្ដារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មាននិងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- កិច្ចសហការនិងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុករបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១៤៨.-**

នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច ដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨និងមាត្រា៤៩នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលស្រុកត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថា មានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលត្រូវធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ជូនក្រុមប្រឹក្សាស្រុកនិងធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១៤៩.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៤៧និងមាត្រា១៤៨នៃអនុក្រឹត្យនេះ និងការងារដទៃទៀត ដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលស្រុកត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលស្រុករបស់ខ្លួន ដោយឈរលើគោលការណ៍ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេចនិងគោលការណ៍

ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

អភិបាលស្រុក ត្រូវទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាស្រុកអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលរបស់ខ្លួន។

អភិបាលរងស្រុក ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលស្រុកលើភារកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលទទួលខុសត្រូវអំពីការសម្រេចនិងសកម្មភាពក្នុងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលស្រុកត្រូវជួបប្រជុំគ្នាប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។

ក្រៅពីការប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែខាងលើ គណៈអភិបាលស្រុកអាចកោះប្រជុំតាមការចាំបាច់។

រៀងរាល់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ។

**មាត្រា ១៥០.-**

គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាស្រុក ការសម្រេចឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលស្រុក ឬអភិបាលស្រុក ឬអភិបាលរងស្រុក ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេចឬសកម្មភាពខាងលើនេះ។

**មាត្រា ១៥១.-**

គណៈអភិបាលស្រុក ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលស្រុកនិងអភិបាលរងស្រុក ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលស្រុក អភិបាលរងស្រុក និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ១៥២.-**

អភិបាលស្រុក ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាស្រុកចុះហត្ថលេខា ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣១នៃអនុក្រឹត្យនេះ។

អភិបាលស្រុក អាចប្រគល់សិទ្ធិដល់អភិបាលរងស្រុកក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងស្រុកនីមួយៗ។

អភិបាលស្រុកត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងស្រុក។

អភិបាលស្រុក មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងស្រុកណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលស្រុកត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្ដីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ១៥៣.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងស្រុក អភិបាលស្រុក មានភារកិច្ច :

- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ឱ្យអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលស្រុកត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក អភិបាលស្រុកត្រូវសម្របសម្រួលតម្រង់ទិសការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាស្រុក។
- ពិនិត្យវាយតម្លៃ ផ្ដល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានការិយាល័យអង្គភាពនៃក្រសួង ស្ថាប័ននានាតាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាស្រុកជាមុន ក្នុងការផ្ដល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យនិងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំក្នុងស្រុករបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខភាពដែលស្នើតែងតាំងខាងលើនេះ អភិបាលស្រុកត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការសម្របសម្រួលជាមួយប្រធានមន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្ដីរាយការណ៍ជូនរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី។
- ក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតីដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងស្រុករបស់ខ្លួនឬករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យ អង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលស្រុកត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរនិងជាបន្ទាន់ទៅអភិបាលខេត្ត។ អភិបាលខេត្ត ត្រូវណែនាំដល់មន្ទីរ

អង្គភាពខ្សែបណ្ដោយសាមីនៅថ្នាក់ខេត្តឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារ ដែលមានការចូលរួមពីតំណាងស្រុកពាក់ព័ន្ធ ឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី ។

– អភិបាលស្រុកមានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្ដូរឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តិកម្មបាន ។

ដើម្បីធានាឱ្យអភិបាលស្រុកអនុវត្តនូវភារកិច្ចខាងលើនេះ សេចក្ដីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅស្រុក ត្រូវដាក់ជូនអភិបាលស្រុកដើម្បីពិនិត្យនិងផ្ដល់យោបល់ ។ ប្រសិនបើអភិបាលស្រុកឯកភាព អភិបាលត្រូវចុះហត្ថលេខាលើរបាយការណ៍នោះរួមជាមួយប្រធានការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ ។ ចំពោះសេចក្ដីរាយការណ៍ក្រៅពីនោះរបស់ការិយាល័យ អង្គភាពនិងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ត្រូវចម្លងជូនសាលាស្រុក ។

**មាត្រា ១៥៤.-**

អភិបាលស្រុកត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលក្នុងការថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងស្រុក អំពីច្បាប់និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារនិងគោរពសិទ្ធិមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងស្រុក ។

អភិបាលស្រុក គឺជាប្រធានគណៈបញ្ជាការឯកភាពស្រុក ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្ដាប់ធ្នាប់និងរបៀបរៀបរយសាធារណៈនៅក្នុងស្រុក ។

**មាត្រា ១៥៥.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៥៣និងមាត្រា១៥៤នៃអនុក្រឹត្យនេះ អភិបាលស្រុកត្រូវធ្វើការបែងចែកភារកិច្ចដល់អភិបាលរងក្នុងគណៈអភិបាលរបស់ខ្លួន ឱ្យជួយខ្លួនក្នុងការងារខាងលើនេះ ។

អភិបាលរងស្រុកដែលបានទទួលការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលស្រុក ។

អភិបាលស្រុក ត្រូវកោះប្រជុំគណៈអភិបាលតាមការចាំបាច់ ដើម្បីពិគ្រោះពិភាក្សាលើបញ្ហាណាមួយដែលខ្លួនយល់ឃើញថាចាំបាច់ត្រូវធ្វើការពិភាក្សាក្នុងគណៈអភិបាលស្រុក សំដៅលើកកម្ពស់ការចូលរួមអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងក្រសួង ស្ថាប័ននានា ។

គ្រប់កិច្ចប្រជុំខាងលើនេះ ត្រូវមានកំណត់ហេតុប្រជុំ ។

**មាត្រា ១៥៦.-**

ក្នុងការអនុវត្តតួនាទី ភារកិច្ចដូចមានចែងក្នុងមាត្រា១៥៣និងមាត្រា១៥៤នៃអនុក្រឹត្យនេះ អភិបាលស្រុកត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានានិងការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃនិងក្រសួង ស្ថាប័ននានា ស្របទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៥៧.-**

អភិបាលស្រុកដោយមាននាយករដ្ឋបាលជាជំនួយការ ត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពនិងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួន។

ក្នុងករណីមានបញ្ហាណាមួយ ដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលស្រុកក្នុងនាមជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុកអាចតម្រូវឱ្យអភិបាលស្រុកធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក។

ក្រុមប្រឹក្សាស្រុក អាចផ្តល់អនុសាសន៍និងការណែនាំដល់អភិបាលស្រុកអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនិងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។

អភិបាលស្រុក ត្រូវទទួលយកអនុសាសន៍និងការណែនាំពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើការណែនាំសម្របសម្រួលនិងតម្រង់ទិសដល់ការិយាល័យ អង្គភាពនិងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅស្រុក ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនវិញ។

**មាត្រា ១៥៨.-**

ក្នុងករណីអភិបាលស្រុកអវត្តមាន អភិបាលស្រុកត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងស្រុកមួយរូប ឱ្យទទួលជាអភិបាលស្រុកស្តីទី។

ប្រសិនបើអភិបាលស្រុកអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងស្រុកដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលស្រុក ត្រូវធ្វើជាអភិបាលស្រុកស្តីទី។

ក្នុងករណីអភិបាលស្រុកស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងស្រុកមួយរូបឱ្យទទួលជាអភិបាលស្រុកស្តីទីនិងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលស្រុកស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្ត ជូនអភិបាលស្រុក នៅពេលដែលអភិបាលស្រុកមានវត្តមានវិញ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំស្តីពីបែបបទនិងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ។

**មាត្រា ១៥៩.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើសេចក្តីណែនាំស្តីពីការសុំច្បាប់ឈប់សម្រាករបស់អភិបាលស្រុក អភិបាលរងស្រុកនិងបុគ្គលិករបស់ក្រុមប្រឹក្សាស្រុក។

## ផ្នែកទី៤

## នាយករដ្ឋបាលសាលាស្រុក

**មាត្រា ១៦០.-**

ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក ត្រូវមាននាយករដ្ឋបាលមួយ(០១)រូប ហៅថានាយករដ្ឋបាលសាលាស្រុក ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុក ដោយយោងតាមការសម្រេចពីក្រុមប្រឹក្សាស្រុក។

នាយករដ្ឋបាលសាលាស្រុក ត្រូវមាននាយករងរដ្ឋបាលសាលាស្រុកយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់អភិបាលស្រុក ដោយយោងតាមការសម្រេចពីក្រុមប្រឹក្សាស្រុក។

នាយករដ្ឋបាលសាលាស្រុក ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការដើមខ្សែនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

នាយករងរដ្ឋបាលសាលាស្រុក ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរសក្តិចាប់ពីក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

**មាត្រា ១៦១.-**

លក្ខណសម្បត្តិនិងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលសាលាស្រុក និងនាយករងរដ្ឋបាលសាលាស្រុក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញប្រកាសឬសេចក្តីណែនាំអំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់នាយករដ្ឋបាលសាលាស្រុកនិងនាយករងរដ្ឋបាលសាលាស្រុក។

**មាត្រា ១៦២.-**

នាយករដ្ឋបាលសាលាស្រុក មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងអភិបាលស្រុក ក្នុងការចាត់ចែងកិច្ចការរដ្ឋបាលនិងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក។

ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលាស្រុកត្រូវធ្វើរបាយការណ៍និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលស្រុក អភិបាលស្រុកនិងក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ១៦៣.-**

ក្នុងការអនុវត្តតួនាទីដូចមានចែងក្នុងមាត្រា១៦២នៃអនុក្រឹត្យនេះ នាយករដ្ឋបាលសាលាស្រុក មានភារកិច្ច :

- រៀបចំនិងដាក់ជូនគណៈអភិបាលស្រុក ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក ក្នុង

ក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលស្រុក ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល

- រៀបចំនិងដាក់ជូនគណៈអភិបាលនូវវិធាននិងគោលការណ៍ក្នុងការអនុវត្តដីកានិងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក
- ធ្វើជាសេនាធិការជូនអភិបាលស្រុកនិងប្រធានក្រុមប្រឹក្សា ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារនិងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារនិងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាស្រុកបានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា ត្រូវតែដាក់ជូនគណៈអភិបាល ដើម្បីពិនិត្យនិងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។
- ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាក្នុងការរៀបចំនិងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំនិងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក
- ត្រៀមរៀបចំកិច្ចការនានាសម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលស្រុក តាមការណែនាំរបស់អភិបាល
- ធានាក្នុងការទទួលនិងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវ ដល់សមាជិកក្រុមប្រឹក្សាស្រុក អភិបាលស្រុកនិងអភិបាលរងស្រុក ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញនិងអ្នកពាក់ព័ន្ធនានា
- គ្រប់គ្រងនិងប្រើប្រាស់ត្រារដ្ឋបាលស្រុកឱ្យបានត្រឹមត្រូវតាមការកំណត់ ដូចមានចែងក្នុងមាត្រា១៧១នៃអនុក្រឹត្យនេះ
- ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវនិងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក និងរដ្ឋបាលរបស់ខ្លួន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក អភិបាលស្រុក ឬដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៦៤.-**

នាយករដ្ឋបាលសាលាស្រុក មានសិទ្ធិចូលរួមនិងបញ្ចេញយោបល់គ្រប់កិច្ចប្រជុំក្រុមប្រឹក្សាស្រុក កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការនិងក្រុមការងារនានារបស់ក្រុមប្រឹក្សាស្រុកនិងកិច្ចប្រជុំគណៈអភិបាលស្រុក ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលសាលាស្រុកជាសមាជិកគណៈកម្មាធិការឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយរបស់ក្រុមប្រឹក្សាស្រុក។

**មាត្រា ១៦៥.-**

ក្នុងការចូលរួមក្នុងកិច្ចប្រជុំ ដូចមានចែងក្នុងមាត្រា១៦៤នៃអនុក្រឹត្យនេះនិងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលសាលាស្រុកអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សា គណៈកម្មាធិការ អនុគណៈកម្មាធិការនិងក្រុមការងារនានា របស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលរបស់ខ្លួន អំពីបញ្ហាច្បាប់និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេចនិង សកម្មភាពនានារបស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុកនិងអភិបាលស្រុក មានលក្ខណៈសមស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិសម្រាប់សុវត្ថិភាពនិងគុណភាពដែលបានកំណត់ ព្រមទាំង ការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាស្រុក។

**មាត្រា ១៦៦.-**

ដោយមានការដឹកនាំ ណែនាំពីគណៈអភិបាលស្រុកនិងអភិបាលស្រុក នាយករដ្ឋបាលសាលាស្រុកត្រូវធានាឱ្យ ការិយាល័យ មន្ត្រី បុគ្គលិកទាំងអស់ អនុវត្តការងារឱ្យបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សានិងគណៈអភិបាលរបស់ខ្លួន។

**មាត្រា ១៦៧.-**

គណៈអភិបាលស្រុកនិងអភិបាលស្រុក អាចធ្វើប្រតិភូកម្មដល់នាយករដ្ឋបាលសាលាស្រុក ឱ្យលើកយោបល់លើ កិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាល ឬអភិបាល ពិនិត្យសម្រេច តាមការចាំបាច់។

## ផ្នែកទី៥

## សាលាស្រុក និងការិយាល័យចំណុះនានា

**មាត្រា ១៦៨.-**

សាលាស្រុក គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក។

សាលាស្រុក ត្រូវបើកធ្វើការឱ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ។

ក្នុងអំឡុងពេលម៉ោងធ្វើការងារ ប្រជាពលរដ្ឋមានសិទ្ធិ :

- ធ្វើទំនាក់ទំនងនិងធ្វើការងារជាមួយក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក
- ទទួលព័ត៌មានអំពីសំណើនិងការងារនានាពីរដ្ឋបាលស្រុក
- ចូលរួមយោបល់ឬសំណូមពរលើបញ្ហាណាមួយ។

នៅចន្លោះម៉ោងធ្វើការឬថ្ងៃឈប់សម្រាកជាផ្លូវការ ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក ត្រូវធានាឱ្យមាន មន្ត្រី បុគ្គលិកនៃរដ្ឋបាលរបស់ខ្លួន ក្នុងចំនួនសមស្របប្រចាំការ ដើម្បីទទួលឬដោះស្រាយសំណូមពរបន្ទាន់ពិសេសនានា។

**មាត្រា ១៦៩.-**

រដ្ឋបាលស្រុកនីមួយៗ ត្រូវធ្វើជាម្ចាស់និងទទួលខុសត្រូវចាត់ចែងលើរាល់លិខិតស្នាម ឯកសារទាំងអស់ដែល បានទទួលត្រឹមត្រូវ ឱ្យបានស្របតាមច្បាប់ជាធរមាន។

**មាត្រា ១៧០.-**

រដ្ឋបាលស្រុកនីមួយៗ ជាម្ចាស់និងទទួលខុសត្រូវលើរាល់លិខិតស្នាម ឯកសារនានាដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាស្រុក ឬក្នុងនាមក្រុមប្រឹក្សាស្រុក និងដោយគណៈអភិបាលស្រុកក្នុងនាមរដ្ឋ ព្រមទាំងជាម្ចាស់លើឧបករណ៍ មធ្យោបាយនិងសម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន ។

រដ្ឋបាលស្រុកនីមួយៗ ត្រូវធានាទុកដាក់ឯកសារ លិខិតស្នាម ឧបករណ៍ មធ្យោបាយ សម្ភារៈនានានៃរដ្ឋបាលរបស់ខ្លួន ឱ្យបានត្រឹមត្រូវតាមការកំណត់ មានសណ្តាប់ធ្នាប់ល្អនិងគង់វង្ស ។

**មាត្រា ១៧១.-**

ត្រារដ្ឋបាលស្រុកនីមួយៗ ត្រូវបានប្រគល់ឱ្យនាយករដ្ឋបាលសាលាស្រុករបស់ខ្លួន ដើម្បីទទួលខុសត្រូវនិងគ្រប់គ្រងសម្រាប់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុកប្រើប្រាស់ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំអំពីការគ្រប់គ្រងនិងប្រើប្រាស់ត្រាខាងលើនេះ ។

**មាត្រា ១៧២.-**

រដ្ឋបាលស្រុកនីមួយៗ ត្រូវរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈនៅមុខសាលាស្រុករបស់ខ្លួន ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល ។

ក្តារព័ត៌មានសាធារណៈខាងលើនេះ ត្រូវបានសរសេរឬបានបិទផ្សាយសេចក្តីជូនដំណឹងជាផ្លូវការដល់សាធារណជន ។

ការសរសេរនិងការបិទផ្សាយខាងលើនេះ ត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់(១០)ថ្ងៃ ។

ក្រៅពីក្តារព័ត៌មានសាធារណៈនៅមុខសាលាស្រុក ក្រុមប្រឹក្សាស្រុកនីមួយៗត្រូវរៀបចំក្តារព័ត៌មានសាធារណៈនៅទីសាធារណៈដទៃទៀតក្នុងស្រុករបស់ខ្លួនតាមការចាំបាច់ ។

ក្រៅពីការរៀបចំឱ្យមានក្តារព័ត៌មានសាធារណៈ ក្រុមប្រឹក្សាស្រុកនីមួយៗត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ ។

**មាត្រា ១៧៣.-**

សាលាស្រុកនីមួយៗ ត្រូវមានការិយាល័យចំណុះមួយចំនួន ។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយ(០១)រូប អមដោយអនុប្រធានការិយាល័យមួយ(០១)រូបជាជំនួយការ ដែលត្រូវតែងតាំងឡើងតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាស្រុក ។

ការិយាល័យខាងលើនេះ ជាសេនាធិការរបស់ក្រុមប្រឹក្សាស្រុកនិងគណៈអភិបាលស្រុក ក្នុងកិច្ចសហការជាមួយស្ថាប័ន អង្គភាពជំនាញតាមវិស័យ លើកិច្ចការសំខាន់ៗដូចខាងក្រោម :

ក្នុងការសិក្សាខាងលើនេះ គ.ជ.អ.ប. ត្រូវធ្វើការពិគ្រោះយោបល់និងធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំយុទ្ធសាស្ត្រ និងដំណាក់កាលសមស្របក្នុងដំណើរការធ្វើសមាហរណកម្មនេះ ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ២១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុងកោះរ៉ុង នៃខេត្តព្រះសីហនុ

- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌកំបូល នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកតាំងគោក នៃខេត្តកំពង់ធំ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកបុរីអូរស្វាយសែនជ័យ នៃខេត្តស្ទឹងត្រែង
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតស្រុកតាលោសែនជ័យ នៃខេត្តពោធិ៍សាត់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី និងសមាជិកក្រុមប្រឹក្សាខេត្តនីមួយៗសម្រាប់អាណត្តិទី៣ ដោយអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១- រាជធានីភ្នំពេញ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ២- ខេត្ត កណ្តាល | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៣- ខេត្ត កំពង់ចាម | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៤- ខេត្ត បាត់ដំបង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៥- ខេត្ត ព្រៃវែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៦- ខេត្ត សៀមរាប | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៧- ខេត្ត តាកែវ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៧ នាក់ |
| ៨- ខេត្ត ត្បូងឃ្មុំ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ៩- ខេត្ត បន្ទាយមានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១០-ខេត្ត កំពង់ស្ពឺ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១១-ខេត្ត កំពង់ធំ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១២-ខេត្ត កំពត | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៥ នាក់ |
| ១៣-ខេត្ត កំពង់ឆ្នាំង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៣ នាក់ |
| ១៤-ខេត្ត ស្វាយរៀង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២៣ នាក់ |
| ១៥-ខេត្ត ពោធិ៍សាត់ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៦-ខេត្ត ក្រចេះ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |

| | | |
|---|---|---|
| ១៧-ខេត្ត ព្រះសីហនុ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៨-ខេត្ត កោះកុង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៩-ខេត្ត ព្រះវិហារ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ២០-ខេត្ត រតនគិរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ២១-ខេត្ត ឧត្តរមានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ២២-ខេត្ត ស្ទឹងត្រែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ២៣-ខេត្ត មណ្ឌលគិរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ២៤-ខេត្ត ប៉ៃលិន | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ២៥-ខេត្ត កែប | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់។ |

**មាត្រា ២.-**

ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នីមួយៗសម្រាប់អាណត្តិទី៣ ដោយអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម៖

**១.រាជធានីភ្នំពេញ**

| | | |
|---|---|---|
| ១- ខណ្ឌ មានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ២- ខណ្ឌ ច្បារអំពៅ | -ដ- | ២១ នាក់ |
| ៣- ខណ្ឌ ទួលគោក | -ដ- | ២១ នាក់ |
| ៤- ខណ្ឌ ឫស្សីកែវ | -ដ- | ២១ នាក់ |
| ៥- ខណ្ឌ សែនសុខ | -ដ- | ២១ នាក់ |
| ៦- ខណ្ឌ ពោធិ៍សែនជ័យ | -ដ- | ២១ នាក់ |
| ៧- ខណ្ឌ ចំការមន | -ដ- | ១៩ នាក់ |
| ៨- ខណ្ឌ ដង្កោ | -ដ- | ១៩ នាក់ |
| ៩- ខណ្ឌ ដូនពេញ | -ដ- | ១៩ នាក់ |
| ១០-ខណ្ឌ ៧មករា | -ដ- | ១៩ នាក់ |
| ១១-ខណ្ឌ បឹងកេងកង | -ដ- | ១៧ នាក់ |
| ១២-ខណ្ឌ កំបូល | -ដ- | ១៧ នាក់ |
| ១៣-ខណ្ឌ ជ្រោយចង្វារ | -ដ- | ១៧ នាក់ |
| ១៤-ខណ្ឌ ព្រែកព្នៅ | -ដ- | ១៧ នាក់ |

**២.ខេត្ត កណ្ដាល**

| | | |
|---|---|---|
| ១៥-ក្រុង តាខ្មៅ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៦-ស្រុក កៀនស្វាយ | -ដ- | ២១ នាក់ |
| ១៧-ស្រុក ស្អាង | -ដ- | ២១ នាក់ |

| | | |
|---|---|---|
| ១៨-ស្រុក កោះធំ | -ដ- | ២១ នាក់ |
| ១៩-ស្រុក ខ្សាច់កណ្ដាល | -ដ- | ២១ នាក់ |
| ២០-ស្រុក ពញាឮ | -ដ- | ២១ នាក់ |
| ២១-ស្រុក កណ្ដាលស្ទឹង | -ដ- | ២១ នាក់ |
| ២២-ស្រុក អង្គស្នួល | -ដ- | ១៩ នាក់ |
| ២៣-ស្រុក មុខកំពូល | -ដ- | ១៩ នាក់ |
| ២៤-ស្រុក ល្វាឯម | -ដ- | ១៩ នាក់ |
| ២៥-ស្រុក លើកដែក | -ដ- | ១៧ នាក់ |

**៣.ខេត្ត កំពង់ចាម**

| | | |
|---|---|---|
| ២៦-ស្រុក ស្ទឹងត្រង់ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ២៧-ស្រុក ចំការលើ | -ដ- | ២១ នាក់ |
| ២៨-ស្រុក កំពង់សៀម | -ដ- | ២១ នាក់ |
| ២៩-ស្រុក ព្រៃឈរ | -ដ- | ២១ នាក់ |
| ៣០-ស្រុក បាធាយ | -ដ- | ២១ នាក់ |
| ៣១-ស្រុក ស្រីសន្ធរ | -ដ- | ២១ នាក់ |
| ៣២-ស្រុក កងមាស | -ដ- | ២១ នាក់ |
| ៣៣-ស្រុក ជើងព្រៃ | -ដ- | ២១ នាក់ |
| ៣៤-ស្រុក កោះសូទិន | -ដ- | ១៩ នាក់ |
| ៣៥-ក្រុង កំពង់ចាម | -ដ- | ១៧ នាក់ |

**៤.ខេត្ត បាត់ដំបង**

| | | |
|---|---|---|
| ៣៦-ក្រុង បាត់ដំបង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៣៧-ស្រុក ថ្មគោល | -ដ- | ២១ នាក់ |
| ៣៨-ស្រុក មោងឫស្សី | -ដ- | ២១ នាក់ |
| ៣៩-ស្រុក សង្កែ | -ដ- | ២១ នាក់ |
| ៤០-ស្រុក បាណន់ | -ដ- | ២១ នាក់ |
| ៤១-ស្រុក បវេល | -ដ- | ២១ នាក់ |
| ៤២-ស្រុក ឯកភ្នំ | -ដ- | ១៩ នាក់ |
| ៤៣-ស្រុក ភ្នំព្រឹក | -ដ- | ១៧ នាក់ |
| ៤៤-ស្រុក កំរៀង | -ដ- | ១៧ នាក់ |
| ៤៥-ស្រុក សំឡូត | -ដ- | ១៧ នាក់ |
| ៤៦-ស្រុក រុក្ខគិរី | -ដ- | ១៧ នាក់ |
| ៤៧-ស្រុក សំពៅលូន | -ដ- | ១៧ នាក់ |

| | | |
|---|---|---|
| ៤៨-ស្រុក រតនមណ្ឌល | -ដ- | ១៥ នាក់ |
| ៤៩-ស្រុក គាស់ក្រឡ | -ដ- | ១៥ នាក់ |

**៥.ខេត្ត ព្រៃវែង**

| | | |
|---|---|---|
| ៥០-ស្រុក ពារាំង | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៥១-ស្រុក ព្រះស្ដេច | -ដ- | ២១ នាក់ |
| ៥២-ស្រុក កំពង់ត្របែក | -ដ- | ២១ នាក់ |
| ៥៣-ស្រុក ស្វាយអន្ទរ | -ដ- | ២១ នាក់ |
| ៥៤-ស្រុក មេសាង | -ដ- | ២១ នាក់ |
| ៥៥-ស្រុក បាភ្នំ | -ដ- | ១៩ នាក់ |
| ៥៦-ស្រុក ស៊ីធរកណ្ដាល | -ដ- | ១៩ នាក់ |
| ៥៧-ស្រុក កញ្ច្រៀច | -ដ- | ១៩ នាក់ |
| ៥៨-ស្រុក ពាមជរ | -ដ- | ១៩ នាក់ |
| ៥៩-ស្រុក កំចាយមារ | -ដ- | ១៩ នាក់ |
| ៦០-ស្រុក ពាមរក៍ | -ដ- | ១៧ នាក់ |
| ៦១-ស្រុក ពោធិ៍រៀង | -ដ- | ១៧ នាក់ |
| ៦២-ក្រុង ព្រៃវែង | -ដ- | ១៥ នាក់ |

**៦.ខេត្ត សៀមរាប**

| | | |
|---|---|---|
| ៦៣-ក្រុង សៀមរាប | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៦៤-ស្រុក ជីក្រែង | -ដ- | ២១ នាក់ |
| ៦៥-ស្រុក ពួក | -ដ- | ២១ នាក់ |
| ៦៦-ស្រុក សូទ្រនិគម | -ដ- | ២១ នាក់ |
| ៦៧-ស្រុក ប្រាសាទបាគង | -ដ- | ១៩ នាក់ |
| ៦៨-ស្រុក ក្រឡាញ់ | -ដ- | ១៩ នាក់ |
| ៦៩-ស្រុក អង្គរជុំ | -ដ- | ១៩ នាក់ |
| ៧០-ស្រុក វ៉ារិន | -ដ- | ១៧ នាក់ |
| ៧១-ស្រុក បន្ទាយស្រី | -ដ- | ១៥ នាក់ |
| ៧២-ស្រុក ស្រីស្នំ | -ដ- | ១៥ នាក់ |
| ៧៣-ស្រុក ស្វាយលើ | -ដ- | ១៥ នាក់ |
| ៧៤-ស្រុក អង្គរធំ | -ដ- | ១៣ នាក់ |

**៧.ខេត្ត តាកែវ**

| | | |
|---|---|---|
| ៧៥-ស្រុក បាទី | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៧៦-ស្រុក ត្រាំកក់ | -ដ- | ២១ នាក់ |

| | | |
|---|---|---|
| ៧៧-ស្រុក សំពោង | -ដ- | ២១ នាក់ |
| ៧៨-ស្រុក ទ្រាំង | -ដ- | ២១ នាក់ |
| ៧៩-ស្រុក គិរីវង់ | -ដ- | ២១ នាក់ |
| ៨០-ស្រុក ព្រៃកប្បាស | -ដ- | ២១ នាក់ |
| ៨១-ស្រុក អង្គរបូរី | -ដ- | ១៧ នាក់ |
| ៨២-ស្រុក កោះអណ្តែត | -ដ- | ១៧ នាក់ |
| ៨៣-ក្រុង ដូនកែវ | -ដ- | ១៧ នាក់ |
| ៨៤-ស្រុក បុរីជលសារ | -ដ- | ១៥ នាក់ |
| **៨.ខេត្ត ត្បូងឃ្មុំ** | | |
| ៨៥-ស្រុក ត្បូងឃ្មុំ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៨៦-ស្រុក មេមត់ | -ដ- | ២១ នាក់ |
| ៨៧-ស្រុក ពញាក្រែក | -ដ- | ២១ នាក់ |
| ៨៨-ស្រុក ក្រូចឆ្មារ | -ដ- | ២១ នាក់ |
| ៨៩-ស្រុក អូររាំងឪ | -ដ- | ១៩ នាក់ |
| ៩០-ស្រុក តំបែរ | -ដ- | ១៩ នាក់ |
| ៩១-ក្រុង សួង | -ដ- | ១៥ នាក់ |
| **៩.ខេត្ត បន្ទាយមានជ័យ** | | |
| ៩២-ស្រុក មង្គលបូរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ៩៣-ស្រុក ព្រះនេត្រព្រះ | -ដ- | ២១ នាក់ |
| ៩៤-ក្រុង សិរីសោភ័ណ | -ដ- | ១៩ នាក់ |
| ៩៥-ក្រុង ប៉ោយប៉ែត | -ដ- | ១៩ នាក់ |
| ៩៦-ស្រុក ស្វាយចេក | -ដ- | ១៩ នាក់ |
| ៩៧-ស្រុក ថ្មពួក | -ដ- | ១៩ នាក់ |
| ៩៨-ស្រុក អូរជ្រៅ | -ដ- | ១៧ នាក់ |
| ៩៩-ស្រុក ភ្នំស្រុក | -ដ- | ១៧ នាក់ |
| ១០០-ស្រុក ម៉ាឡៃ | -ដ- | ១៧ នាក់ |
| **១០.ខេត្ត កំពង់ស្ពឺ** | | |
| ១០១-ស្រុក បសេដ្ឋ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១០២-ស្រុក គងពិសី | -ដ- | ២១ នាក់ |
| ១០៣-ស្រុក ឧដុង្គ | -ដ- | ២១ នាក់ |
| ១០៤-ស្រុក សំរោងទង | -ដ- | ២១ នាក់ |
| ១០៥-ស្រុក ភ្នំស្រួច | -ដ- | ២១ នាក់ |

| | | |
|---|---|---|
| ១០៦-ស្រុក ថ្លុង | -ដ- | ១៧ នាក់ |
| ១០៧-ក្រុង ច្បារមន | -ដ- | ១៧ នាក់ |
| ១០៨-ស្រុក ឱរ៉ាល់ | -ដ- | ១៥ នាក់ |

**១១.ខេត្ត កំពង់ធំ**

| | | |
|---|---|---|
| ១០៩-ស្រុក បារាយណ៍ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១១០-ស្រុក ស្ទោង | -ដ- | ២១ នាក់ |
| ១១១-ស្រុក កំពង់ស្វាយ | -ដ- | ២១ នាក់ |
| ១១២-ស្រុក សន្ទុក | -ដ- | ២១ នាក់ |
| ១១៣-ស្រុក តាំងគោក | -ដ- | ១៩ នាក់ |
| ១១៤-ស្រុក ប្រាសាទបល្ល័ង្គ | -ដ- | ១៧ នាក់ |
| ១១៥-ស្រុក សណ្ដាន់ | -ដ- | ១៧ នាក់ |
| ១១៦-ក្រុង ស្ទឹងសែន | -ដ- | ១៧ នាក់ |
| ១១៧-ស្រុក ប្រាសាទសំបូរ | -ដ- | ១៥ នាក់ |

**១២.ខេត្ត កំពត**

| | | |
|---|---|---|
| ១១៨-ស្រុក ទឹកឈូ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១១៩-ស្រុក ឈូក | -ដ- | ២១ នាក់ |
| ១២០-ស្រុក កំពង់ត្រាច | -ដ- | ១៩ នាក់ |
| ១២១-ស្រុក បន្ទាយមាស | -ដ- | ១៩ នាក់ |
| ១២២-ស្រុក អង្គរជ័យ | -ដ- | ១៩ នាក់ |
| ១២៣-ស្រុក ដងទង់ | -ដ- | ១៧ នាក់ |
| ១២៤-ស្រុក ជុំគីរី | -ដ- | ១៧ នាក់ |
| ១២៥-ក្រុង កំពត | -ដ- | ១៥ នាក់ |

**១៣.ខេត្ត កំពង់ឆ្នាំង**

| | | |
|---|---|---|
| ១២៦-ស្រុក រលាប្អៀរ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១២៧-ស្រុក កំពង់ត្រឡាច | -ដ- | ១៩ នាក់ |
| ១២៨-ស្រុក សាមគ្គីមានជ័យ | -ដ- | ១៩ នាក់ |
| ១២៩-ស្រុក កំពង់លែង | -ដ- | ១៧ នាក់ |
| ១៣០-ស្រុក បរិបូណ៌ | -ដ- | ១៧ នាក់ |
| ១៣១-ស្រុក ទឹកផុស | -ដ- | ១៧ នាក់ |
| ១៣២-ក្រុង កំពង់ឆ្នាំង | -ដ- | ១៥ នាក់ |
| ១៣៣-ស្រុក ជលគិរី | -ដ- | ១៥ នាក់ |

**១៤.ខេត្ត ស្វាយរៀង**

| | | |
|---|---|---|
| ១៣៤-ស្រុក រមាសហែក | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៣៥-ស្រុក ស្វាយជ្រំ | -ដ- | ២១ នាក់ |
| ១៣៦-ស្រុក កំពង់រោទិ៍ | -ដ- | ១៩ នាក់ |
| ១៣៧-ស្រុក រំដួល | -ដ- | ១៧ នាក់ |
| ១៣៨-ស្រុក ស្វាយទាប | -ដ- | ១៧ នាក់ |
| ១៣៩-ក្រុង ស្វាយរៀង | -ដ- | ១៥ នាក់ |
| ១៤០-ក្រុង បាវិត | -ដ- | ១៥ នាក់ |
| ១៤១-ស្រុក ចន្ទ្រា | -ដ- | ១៥ នាក់ |

**១៥.ខេត្ត ពោធិ៍សាត់**

| | | |
|---|---|---|
| ១៤២-ស្រុក បាកាន | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ១៤៣-ស្រុក ក្រគរ | -ដ- | ២១ នាក់ |
| ១៤៤-ក្រុង ពោធិ៍សាត់ | -ដ- | ១៧ នាក់ |
| ១៤៥-ស្រុក ភ្នំក្រវាញ | -ដ- | ១៧ នាក់ |
| ១៤៦-ស្រុក កណ្ដៀង | -ដ- | ១៧ នាក់ |
| ១៤៧-ស្រុក តាលោសែនជ័យ | -ដ- | ១៥ នាក់ |
| ១៤៨-ស្រុក វាលវែង | -ដ- | ១៣ នាក់ |

**១៦.ខេត្ត ក្រចេះ**

| | | |
|---|---|---|
| ១៤៩-ស្រុក ស្នួល | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៥០-ស្រុក ព្រែកប្រសព្វ | -ដ- | ១៩ នាក់ |
| ១៥១-ស្រុក សំបូរ | -ដ- | ១៩ នាក់ |
| ១៥២-ស្រុក ចិត្របូរី | -ដ- | ១៩ នាក់ |
| ១៥៣-ស្រុក ឆ្លូង | -ដ- | ១៧ នាក់ |
| ១៥៤-ក្រុង ក្រចេះ | -ដ- | ១៥ នាក់ |

**១៧.ខេត្ត ព្រះសីហនុ**

| | | |
|---|---|---|
| ១៥៥-ក្រុង ព្រះសីហនុ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៥៦-ស្រុក ព្រៃនប់ | -ដ- | ១៩ នាក់ |
| ១៥៧-ក្រុង កោះរ៉ុង | -ដ- | ១១ នាក់ |
| ១៥៨-ស្រុក កំពង់សីលា | -ដ- | ១១ នាក់ |
| ១៥៩-ស្រុក ស្ទឹងហាវ | -ដ- | ១១ នាក់ |

**១៨.ខេត្ត កោះកុង**

| | | |
|---|---|---|
| ១៦០-ក្រុង ខេមរភូមិន្ទ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |

| | | |
|---|---|---|
| ១៦១-ស្រុក ស្រែអំបិល | -ដ- | ១៥ នាក់ |
| ១៦២-ស្រុក បទុមសាគរ | -ដ- | ១៣ នាក់ |
| ១៦៣-ស្រុក មណ្ឌលសីមា | -ដ- | ១១ នាក់ |
| ១៦៤-ស្រុក គិរីសាគរ | -ដ- | ១១ នាក់ |
| ១៦៥-ស្រុក កោះកុង | -ដ- | ១១ នាក់ |
| ១៦៦-ស្រុក ថ្មបាំង | -ដ- | ១១ នាក់ |

**១៩.ខេត្ត ព្រះវិហារ**

| | | |
|---|---|---|
| ១៦៧-ស្រុក រវៀង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១៦៨-ស្រុក ជាំក្សាន្ត | -ដ- | ១៧ នាក់ |
| ១៦៩-ស្រុក គូលែន | -ដ- | ១៥ នាក់ |
| ១៧០-ស្រុក ជ័យសែន | -ដ- | ១៣ នាក់ |
| ១៧១-ស្រុក សង្គមថ្មី | -ដ- | ១៣ នាក់ |
| ១៧២-ស្រុក ឆែប | -ដ- | ១៣ នាក់ |
| ១៧៣-ក្រុង ព្រះវិហារ | -ដ- | ១៣ នាក់ |
| ១៧៤-ស្រុក ត្បែងមានជ័យ | -ដ- | ១១ នាក់ |

**២០.ខេត្ត រតនគិរី**

| | | |
|---|---|---|
| ១៧៥-ក្រុង បានលុង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៧៦-ស្រុក អូរជុំ | -ដ- | ១៣ នាក់ |
| ១៧៧-ស្រុក វើនសៃ | -ដ- | ១៣ នាក់ |
| ១៧៨-ស្រុក បរកែវ | -ដ- | ១៣ នាក់ |
| ១៧៩-ស្រុក លំផាត់ | -ដ- | ១៣ នាក់ |
| ១៨០-ស្រុក កូនមុំ | -ដ- | ១៣ នាក់ |
| ១៨១-ស្រុក អូរយ៉ាដាវ | -ដ- | ១៣ នាក់ |
| ១៨២-ស្រុក អណ្ដូងមាស | -ដ- | ១១ នាក់ |
| ១៨៣-ស្រុក តាវែង | -ដ- | ១១ នាក់ |

**២១.ខេត្ត ស្ទឹងត្រែង**

| | | |
|---|---|---|
| ១៨៤-ក្រុង ស្ទឹងត្រែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៨៥-ស្រុក ថាឡាបរិវ៉ាត់ | -ដ- | ១៥ នាក់ |
| ១៨៦-ស្រុក សេសាន | -ដ- | ១៣ នាក់ |
| ១៨៧-ស្រុក សៀមប៉ាង | -ដ- | ១៣ នាក់ |
| ១៨៨-ស្រុក សៀមបូក | -ដ- | ១៣ នាក់ |
| ១៨៩-ស្រុក បុរីអូរស្វាយសែនជ័យ | -ដ- | ១១ នាក់ |

**២២.ខេត្ត ឧត្តរមានជ័យ**

| | | |
|---|---|---|
| ១៩០-ក្រុង សំរោង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១៩១-ស្រុក ត្រពាំងប្រាសាទ | -ដ- | ១៧ នាក់ |
| ១៩២-ស្រុក បន្ទាយអំពិល | -ដ- | ១៥ នាក់ |
| ១៩៣-ស្រុក អន្លង់វែង | -ដ- | ១៥ នាក់ |
| ១៩៤-ស្រុក ចុងកាល់ | -ដ- | ១៣ នាក់ |

**២៣.ខេត្ត មណ្ឌលគិរី**

| | | |
|---|---|---|
| ១៩៥-ស្រុក កែវសីមា | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៩៦-ស្រុក កោះញែក | -ដ- | ១៣ នាក់ |
| ១៩៧-ស្រុក អូររាំង | -ដ- | ១១ នាក់ |
| ១៩៨-ស្រុក ពេជ្រាដា | -ដ- | ១១ នាក់ |
| ១៩៩-ក្រុង សែនមនោរម្យ | -ដ- | ១១ នាក់ |

**២៤.ខេត្ត ប៉ៃលិន**

| | | |
|---|---|---|
| ២០០-ក្រុង ប៉ៃលិន | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ២០១-ស្រុក សាលាក្រៅ | -ដ- | ១៥ នាក់ |

**២៥.ខេត្ត កែប**

| | | |
|---|---|---|
| ២០២-ក្រុង កែប | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ២០៣-ស្រុក ដំណាក់ចង្កើរ | -ដ- | ១៣ នាក់។ |

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៥ រោចខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ខ-<u>តែងតាំងផ្លាស់ប្តូរមុខងារ</u> :

១-ឧត្តមសេនីយ៍ទោ ពុត សំអេត អត្តលេខ ០០០១៦៣ នាយក នាយកដ្ឋានបុគ្គលិក បច្ចុប្បន្ន ជាទីប្រឹក្សា ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ត្រី ទ្រាំ ស៊ូ អត្តលេខ ០០៣៨០៨ បច្ចុប្បន្ន ជាទីប្រឹក្សាក្រសួងការពារជាតិ

៣-ឧត្តមសេនីយ៍ត្រី ចំរើន ជាតិ អត្តលេខ ០០០១១០ បច្ចុប្បន្ន ជាទីប្រឹក្សាក្រសួងការពារជាតិ

គ-<u>តម្លើងឋាននន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ</u> :

-ឧត្តមសេនីយ៍ត្រី មាស សំអុល អត្តលេខ ០០០២១១ នាយករង នាយកដ្ឋានបុគ្គលិក បច្ចុប្បន្ន ជានាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ

ឃ-<u>តម្លើងឋាននន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី</u> :

១-វរសេនីយ៍ឯក យៀង គឹមសួរ អត្តលេខ ០០០៤៩៥ នាយករង ឧទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ឯក មាស សក្តិ អត្តលេខ ០០០៧៤៧ នាយករង អធិការកិច្ច អគ្គបញ្ជាការដ្ឋាន

៣-វរសេនីយ៍ឯក ពេជ្រ សុផា អត្តលេខ ០០០៣២០ នាយករង សាលានាយទាហានថ្មរុះ អគ្គបញ្ជាការដ្ឋាន

៤-វរសេនីយ៍ឯក ផាន់ សាមន្តា អត្តលេខ ០០១១៨៩ នាយករង នាយកដ្ឋាន សោធននិវត្តន៍

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

**អនុក្រឹត្យ លេខ ៤២ អនក្រ.បក**

**ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់**

**និងការរំខានដោយសំលេង**

***

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៤ / ២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រង ធនធានធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០០ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំឡេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយ ដែលបង្កអោយមានការបំពុលខ្យល់ និងការរំខានដោយសំឡេងនៅក្នុងបរិយាកាស ។

**មាត្រា ៣ .-**

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ :

ក-"ប្រភពបំពុល" ចែកចេញជាពីរគឺ :

-ប្រភពចល័ត : គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ ជាអាទិ៍មាន : យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ

-ប្រភពអចល័ត : គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែង ជាអាទិ៍មាន : រោងចក្រ សហគ្រាស ឃ្លាំងស្តុកសំភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ ។

ខ-"សារធាតុបំពុល" គឺសំដៅទៅលើផ្សែង ល្អងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម ។

គ-"សារធាតុពុល" គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុសធ្យូង ឬសារធាតុគីមីផ្សេងៗទៀតដែលមានប្រតិកម្មចំហេះ ។

ឃ-"កំរិតកំណត់ស្តង់ដារ" គឺជាកំរិតកំណត់កំហាប់អតិបរមានៃសារធាតុបំពុល ដែលអាចអនុញ្ញាតអោយមាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតអោយបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន ។

## ជំពូកទី ២

## បញ្ញត្តិលើការបញ្ចេញសារធាតុបំពុលខ្យល់ និងសំលេង

**មាត្រា ៤ .-**

កំរិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ១ និងកំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ២ ។

**មាត្រា ៥ .-**

កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស មានចែងនៅក្នុងតារាង ឧបសម្ព័ន្ធ ៣ និងកំរិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ ។

**មាត្រា ៦ .-**

ក្នុងករណីចាំបាច់ កំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងមាត្រា៤ និងមាត្រា៥ នៃអនុក្រឹត្យនេះ នឹងត្រូវ ពិនិត្យកែសំរួលរៀងរាល់ប្រាំឆ្នាំម្តង តាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៧ .-**

កំរិតកំណត់ស្តង់ដារបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំឡេងអតិបរមាសំរាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និង ឧបសម្ព័ន្ធ ៧ ។

**មាត្រា ៨ .-**

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៣ និង ឧបសម្ព័ន្ធ ៤ ។

**មាត្រា ៩ .-**

ហាមឃាត់ដាច់ខាតនូវការបង្កអោយមានសំឡេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមាន ចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៥ ឧបសម្ព័ន្ធ ៦ និងឧបសម្ព័ន្ធ ៧ ។

មាត្រា ១០ .-

ការនាំចូល និងផលិតនូវសារធាតុធេះ ដែលមានជាតិស្ពាន់ធ័រ សំណ បង់សែន និងសារធាតុអ៊ីដ្រូកាប៊ូប្រហើរ ត្រូវឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៨ ។

មាត្រា ១១ .-

ហាមឃាត់ដាច់ខាតការនាំចូល ប្រើប្រាស់ ផលិតយានយន្ត និងគ្រឿងយន្តគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលយានយន្តនិងគ្រឿងយន្តទាំងនោះបានបញ្ចេញសារធាតុបំពុល និងសំឡេងមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ ៤ និង ឧបសម្ព័ន្ធ ៥ ។

មាត្រា ១២ .-

ហាមឃាត់ដាច់ខាតការបង្ហូរ ឬការធ្វើអោយលេចធ្លាយសារធាតុធេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬ សារធាតុ គីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី ។

## ជំពូកទី ៣

## ការសុំអនុញ្ញាត

មាត្រា ១៣ .-

ការបញ្ចេញសារធាតុបំពុល និងសំឡេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវធ្វើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ។

មាត្រា ១៤ .-

ការសុំអនុញ្ញាតនាំចូលនូវសារធាតុធេះ ត្រូវមានភ្ជាប់នូវលទ្ធផលវិភាគ ដែលបញ្ជាក់ពីបរិមាណជាតិពុល ស្ពាន់ធ័រ សំណ បង់សែន ឬ អ៊ីដ្រូកាប៊ូប្រហើរពីប្រភពដើមនៃការនាំចូល ឬការផលិត ។

មាត្រា ១៥ .-

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំឡេងដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងពំរោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ លើកលែងតែ គំរោងដែលមានរបាយការណ៍វាយតំលៃហេតុប៉ះពាល់ បរិស្ថានរួចហើយ ។

មាត្រា ១៦ .-

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យ សុំការអនុញ្ញាតមកក្រសួងបរិស្ថាន ៈ

-អោយបានមុន៩០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គំរោងនៅភ្នំពេញ

-អោយបានមុន៦០ថ្ងៃ នៃការចាប់ផ្តើមដំណើរការ សំរាប់គំរោងនៅតាមខេត្ត-ក្រុង ។

## ជំពូកទី ៤
## ការត្រួតពិនិត្យប្រភពបំពុល

**មាត្រា ១៧ .-**

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុនេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសំឡេងពីប្រភពអចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៨ .-**

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសំឡេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ដោយមានកិច្ចសហការពីក្រសួង និងស្ថាប័នពាក់ព័ន្ធ ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង ។

**មាត្រា ១៩ .-**

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្ដីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសំឡេង ។

**មាត្រា ២០ .-**

ក្រសួងបរិស្ថានត្រូវចុះយកគំរូតាងនៅគ្រប់ចំណុចបញ្ចេញរបស់ប្រភពបំពុល ។ ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថានដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

**មាត្រា ២១ .-**

នៅពេលចុះត្រួតពិនិត្យ ឬធ្វើអធិការកិច្ចនៅតាមប្រភពបំពុល មន្ត្រីបរិស្ថានអាចធ្វើការវិភាគគំរូតាងនៅនឹងកន្លែង ឬយកមកធ្វើនៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ។

**មាត្រា ២២ .-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល ត្រូវបង់ថ្លៃសេវាវិភាគ តាមបញ្ជីចំនួនទឹកប្រាក់ដែលបានកំណត់ជាមុនដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្ដល់ជូនទៅគណនីមូលនិធិទាយទ្ទានបរិស្ថាន ។

**មាត្រា ២៣ .-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល អាចសុំធ្វើការវិភាគគំរូតាងសារធាតុបំពុលរបស់ខ្លួននៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀតដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តវិធីសាស្ត្រវិភាគដូចដែលបានអនុវត្តនៅក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

**មាត្រា ២៤ .-**

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលទាំងអស់ត្រូវ :

-ទទួលខុសត្រូវក្នុងការតម្លើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧបករណ៍សំរាប់កាត់បន្ថយសំឡេង ដើម្បីអោយឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ

-ទទួលខុសត្រូវក្នុងការតម្លើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុល ដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវកត់ត្រាលទ្ធផលទុកជាឯកសារ ហើយត្រូវធ្វើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់៣ខែម្តង

-ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួនមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសំរបសំរួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាល តាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ ។

មាត្រា ២៥ .-

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំឡេងពីប្រភពណាមួយពុំបានឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារ ដូចមានចែងក្នុងមាត្រា ៥ មាត្រា ៧ នៃអនុក្រឹត្យនេះក្រសួងបរិស្ថានត្រូវ :

ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ ។

ខ-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កអោយមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន ។

## ជំពូកទី ៥

## ការត្រួតពិនិត្យគុណភាពខ្យល់

មាត្រា ២៦ .-

ក្រសួងបរិស្ថានត្រូវធ្វើការត្រួតពិនិត្យ តាមដានជាប្រចាំពីស្ថានភាព និងគុណភាពខ្យល់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីមានវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់បានទាន់ពេលវេលា ។

មាត្រា ២៧ .-

ក្រសួងបរិស្ថានត្រូវគ្រប់គ្រងទិន្នន័យលទ្ធផលវិភាគគុណភាពខ្យល់ និងវាយតំលៃពីស្ថានភាពគុណភាពខ្យល់ ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណៈពីស្ថានភាព គុណភាពនិងការបំពុលខ្យល់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៨ .-

ក្នុងករណីរកឃើញថាតំបន់ណាមួយត្រូវទទួលរងការបំពុលខ្យល់ ដែលបង្កអោយមានការគំរាមកំហែងដល់អាយុជីវិតសាធារណៈ ឬគុណភាពបរិស្ថាន ក្រសួងបរិស្ថានត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ

ជាបន្ទាន់ពីបញ្ហាគ្រោះថ្នាក់ និងត្រូវស៊ើបអង្កេតរកប្រភពដែលបង្កអោយមានការបំពុល ព្រមទាំងចាត់វិធានការទប់ស្កាត់ប្រភពបំពុលទាំងនោះ ដើម្បីស្តារនូវគុណភាពខ្យល់អោយបានប្រសើរឡើងវិញ ។

## ជំពូកទី ៦
## នីតិវិធីនៃការធ្វើអធិការកិច្ច

**មាត្រា ២៩ .-**

នៅពេលចុះធ្វើអធិការកិច្ចតាមប្រភពបំពុល មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងខាងក្រោម :

ក-បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួននៅពេលចូលក្នុងបរិវេណ ឬកន្លែងប្រភពបំពុលដើម្បីធ្វើអធិការកិច្ច យកគំរូតាង ឬ ពិនិត្យកំណត់ត្រា ។

ខ-កំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬយកគំរូតាង ត្រូវធ្វើនៅនឹងកន្លែងដែលធ្វើអធិការកិច្ច ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ-មន្ត្រីអធិការកិច្ចអាចសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលផ្តល់ព័ត៌មាន ឬឯកសារនានាដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ និងកំណត់ហេតុសំរាប់ប្រើជាវត្ថុតាង ។

ឃ-របាយការណ៍ ឬកំណត់ហេតុត្រូវផ្តល់មួយច្បាប់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុល មួយច្បាប់ជូនតំណាងក្រសួងពាក់ព័ន្ធ និងមួយច្បាប់ទៀតត្រូវរក្សាទុកនៅក្រសួងបរិស្ថាន ។

**មាត្រា ៣០ .-**

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា ប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំឡេង ឬរំញ័រ បង្កអោយមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

**មាត្រា ៣១ .-**

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ណាមួយនៃការបំពុលខ្យល់ ឬការរំខានដោយ សំឡេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣២ .-**

ក្នុងករណីរកឃើញសកម្មភាពដែលបង្កអោយមានការបំពុលខ្យល់ ឬការរំខានដោយសំឡេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ :

ក-ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ ប្រសិនបើបទល្មើសនោះមិនបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

ខ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូនសំណុំរឿងទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះបានបង្កអោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៣ .-**

ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះនឹងត្រូវទទួលពិន័យ និងផ្តន្ទាទោស ដោយយោងទៅតាមមាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ និងមាត្រា២៥ ជំពូកទី៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣៤ .-**

កំណត់ហេតុចោទប្រកាន់បទល្មើសចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។ ក្រសួងបរិស្ថាន ត្រូវអនុវត្តវិធានការច្បាប់ចំពោះបទល្មើសទាំងឡាយនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៥ .-**

មន្ត្រី ឬភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែសខ្វះការប្រុងប្រយ័ត្ន ឬ ធ្វេសពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលដល់អ្នកប្រព្រឹត្តបទល្មើស ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់ពីបទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣៨.-

អនុក្រឹត្យនេះចូលជាធរមានគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០០

បានជំរាបជូន — នាយករដ្ឋមន្ត្រី

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំចុះហត្ថលេខា — ហត្ថលេខា និងត្រា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន — ហ៊ុន សែន

ម៉ុក ម៉ារ៉េត

★★★

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ-បក

ចុះថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ១

## កំរិតកំណត់ស្តង់ដាគុណភាពខ្យល់

| លរ | ប៉ារ៉ាម៉ែត្រ | រយៈពេល ១ ម៉ោង ជាមធ្យម mg/m³ | រយៈពេល ៨ ម៉ោង ជាមធ្យម mg/m³ | រយៈពេល២៤ម៉ោង ជាមធ្យម mg/m³ | រយៈពេល ១ ឆ្នាំ ជាមធ្យម mg/m³ |
|---|---|---|---|---|---|
| ១ | កាបូនម៉ូណូអុកស៊ីត CO | 40 | 20 | | |
| ២ | អាសូតឌីអុកស៊ីត $NO_2$ | 0,3 | | 0,10 | |
| ៣ | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 0,5 | | 0,30 | 0,10 |
| ៤ | អូសូន $O_3$ | 0,2 | | | |
| ៥ | សំណ Pb | | | 0,005 | |
| ៦ | សារធាតុរឹងអណ្តែតក្នុងខ្យល់ TSP | | | 0,33 | 0,10 |

កំណត់សំគាល់ :

-កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ធ្វើការវាយតំលៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់ ។

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ។

- TSP = Total Suspended Particulate

★★★

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ-បក
ចុះថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ២
## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់
## ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់

| ល.រ | ឈ្មោះសារធាតុគីមី | រូបមន្តគីមី | កំរិតអតិបរមា ($mg/m^3$) |
|---|---|---|---|
| ១ | អានីលីន | $C_6H_5NH_2$ | 0,03 |
| ២ | អាម៉ូញាក់ | $NH_3$ | 0,2 |
| ៣ | អាស៊ីត អាសេទិច | $CH_3$ COOH | 0,2 |
| ៤ | អាស៊ីត ស៊ុលផួរិច | $H_2SO_4$ | 0,3 |
| ៥ | អាស៊ីត នីទ្រិច | $HNO_3$ | 0,4 |
| ៦ | បង់សែន | $C_6H_6$ | 1 |
| ៧ | បង់ស៊ីឌីន | $NH_2C_6H_4C_6H_4NH_2$ | គ្មាន |
| ៨ | កាបូនឌីស៊ុលហ្វីត | $CS_2$ | 0,02 |
| ៩ | ក្លរ៉ូហ្វម | $CHCl_3$ | 0,01 |
| ១០ | កាបូនតេត្រាក្លរីត | $CCl_4$ | 3 |
| ១១ | ភាគល្អិតដែលមាន asbestos | | គ្មាន |
| ១២ | ដេ ដេ តេ | $C_8H_{11}Cl_4$ | 0,5 |
| ១៣ | ហ្វម៉ាល់ដេអ៊ីត | HCOH | 0,012 |
| ១៤ | អ៊ីដ្រូសែន អាសេនិច | AsH3 | 0,002 |
| ១៥ | អ៊ីដ្រូសែន ស៊ីអានិត | HCN | 0,01 |
| ១៦ | អ៊ីដ្រូសែន ភ្លុយអរ៊ិច | HF | 0,002 |

| | | | |
|---|---|---|---|
| ១៧ | អ៊ីដ្រូសែន ស៊ុលហ្វីត | $H_2S$ | 0,001 |
| ១៨ | ផេណុល | $C_6H_5OH$ | 0,01 |
| ១៩ | ស្ទីរេន | $C_6H_5CHCH_2$ | 0,003 |
| ២០ | តេត្រាក្លរអេទីឡែន | $C_2Cl_4$ | 0,1 |
| ២១ | សំណ តេត្រាអេទីល | $Pb(C_2H5)_4$ | 0,005 |
| ២២ | ទ្រីក្លរអេទីឡែន | $ClCHCCl_2$ | 0,2 |
| ២៣ | តូលុយអេន | $C_6H_5CH_3$ | 0,4 |
| ២៤ | វីនីលក្លរ | $ClCHCH_2$ | 0,05 |
| ២៥ | អាសេនិច(សមាសធាតុអសរីរាង្គ) | As | 0,00001 |
| ២៦ | កាដ់មូម (សមាសធាតុលោហៈ និងអុកស៊ីត) | Cd | 0,003 |
| ២៧ | ក្រូម (លោហៈ និងសមាសធាតុ) | Cr | 0,0015 |
| ២៨ | នីកែល (លោហៈ និងសមាសធាតុ) | Ni | 0,0001 |
| ២៩ | បារត (លោហៈ និងសមាសធាតុ) | Hg | 0,0001 |
| ៣០ | ប្រេងកាត | | 5 |

កំណត់សំគាល់ :

ការពិពណ៌នាស្តង់ដារនេះអនុវត្តដើម្បីត្រួតពិនិត្យសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតអោយមាននៅក្នុងខ្យល់ ។

★★★

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ-បក
ចុះថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០០០

## តារាងឧបសម្ព័ន្ធ ៣
## កំរិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញ ពីប្រភពអចល័ត ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត្រ | អតិបរមា កំរិតនៃការបញ្ចេញ |
|---|---|---|
| | ភាគល្អិតនៅក្នុងផ្សែង : បញ្ចេញពីប្រភព | |
| | - ឡដុត | $400 mg / m^3$ |
| | - រោងចក្រផលិតលោហធាតុ | $400 mg / m^3$ |
| | - រោងចក្រស៊ីម៉ង់ត៍ កំបោរ និងថ្មស្អុយ | $400 mg / m^3$ |
| | - រោងចក្របេតុងអាស្វាល់ | $500 mg / m^3$ |
| ២ | - ធូលី ដែលមានភ្ជាប់ : | |
| | - សារធាតុ ស៊ីលីកាត $SiO_2$ | $100 mg / m^3$ |
| | - សារធាតុ Asbetos | $27 ug / m^3$ |
| | <u>សារធាតុគីមីអសរីរាង្គ</u> : | |
| ៣ | - អាលុយមីញ៉ូម Al | (ធូលី) $300 mg / m^3$ ; (Al) $50 mg/m^3$ |
| ៤ | - អាម៉ូញ៉ាក់ $NH_3$ | $100 mg / m^3$ |
| ៥ | - អង់ទីម៉ូន Sb | $25 mg / m^3$ |
| ៦ | - អាសេនិច As | $20 mg / m^3$ |
| ៧ | - បេរីល្យ៉ូម Be | $10 ug / m^3$ |
| ៨ | - ក្លរ Cl | $20 mg / m^3$ |

| | | |
|---|---|---|
| ៩ | - អ៊ីដ្រូសែនក្លរីត HCl | 200 mg / $m^3$ |
| ១០ | - អ៊ីដ្រូសែនភ្លុយអរីត HF | 10 mg / $m^3$ |
| ១១ | - អ៊ីដ្រូសែនស៊ុលហ្វីត $H_2S$ | 2 mg / $m^3$ |
| ១២ | - កាត់ម្ញ៉ូម Cd | 1 mg / $m^3$ |
| ១៣ | - ទង់ដែង Cu | (ធូលី) 300 mg / $m^3$ ; (Cu) 20mg/$m^3$ |
| ១៤ | - សំណ Pb | (ធូលី) 100 mg / $m^3$ ; (Pb) 30mg/$m^3$ |
| ១៥ | - ស័ង្កសី Zn | 30 mg / $m^3$ |
| ១៦ | - បារត Hg | 0,1 mg / $m^3$ |
| ១៧ | - កាបូនម៉ូណូអុកស៊ីត CO | 1000 mg / $m^3$ |
| ១៨ | - ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | 500 mg / $m^3$ |
| ១៩ | - អាសូតអុកស៊ីត (គ្រប់ប្រភេទ) NOx | 1000 mg / $m^3$ |
| ២០ | - អាសូតអុកស៊ីត (ចេញពីការផលិតអាស៊ីត) NOx | 2000 mg / $m^3$ |
| ២១ | - អាស៊ីតស៊ុលហ្វួរិច $H_2SO_4$ | 35 mg / $m^3$ |
| ២២ | -អាស៊ីតនីទ្រិច $HNO_4$ | 70mg / $m^3$ |
| ២៣ | -ស្ពាន់ធ័រទ្រីអុកស៊ីត $SO_3$ | 35 mg / $m^3$ |
| ២៤ | -អាស៊ីតផូស្វរិច $H_3Po_4$ | 3 mg / $m^3$ |
| | -<u>សារធាតុពីមីសរីរាង្គៈ</u> | |
| ២៥ | -អាសេទីឡែនតេត្រាប្រូមីត $CHBr_2$ $CHBr_2$ | 14 mg / $m^3$ |
| ២៦ | -អាក្រូឡេអ៊ីន $CH_2$ CHCHO | 1,2 mg / $m^3$ |
| ២៧ | -អានីលីន $C_6H_5$ $NH_2$ | 19 mg / $m^3$ |
| ២៨ | -បង់ស៊ីឌីន $NH_2$ $C_6$ $H_4$ $C_6$ $H_4$ $NH_2$ | NOne |
| ២៩ | -បង់សែន $C_6H_6$ | 80 mg / $m^3$ |
| ៣០ | -ក្លរបង់ស៊ីល $C_6$ $H_5$ $CH_2$ Cl | 5 mg / $m^3$ |
| ៣១ | -ប៊ុយទីលឡាមីន $CH_3$ ( $CH_2$ )$_2$ $CH_2NH_2$ | 15 mg / $m^3$ |
| ៣២ | -ក្រេស្សូល(O-,m-,P- ) $CH_3$ $C_6H_4$ OH | 22 mg / $m^3$ |
| ៣៣ | -ក្លរបង់សែន $C_6H_5$ Cl | 350 mg / $m^3$ |
| ៣៤ | -ក្លរហ្វម CH $Cl_3$ | 240 mg / $m^3$ |

| | | |
|---|---|---|
| ៣៥ | -ក្លរពីគ្រីន $CCl_3$ $NO_2$ | 0,7 mg / $m^3$ |
| ៣៦ | O-ឌីក្លរបង់សែន $C_6H_4Cl_2$ | 300 mg / $m^3$ |
| ៣៧ | 1,1- ឌីក្លរអេតាន $CHCl_2CH_2$ | 400 mg / $m^3$ |
| ៣៨ | -ឌីមេទីលស៊ុលហ្វាត $(CH_3)_2SO_4$ | 0,5 mg / $m^3$ |
| ៣៩ | -ឌីមេទីលអ៊ីដ្រាហ្សីន $(NH_3)_2NNH_2$ | 1 mg / $m^3$ |
| ៤០ | -ឌីនីត្រូបង់សែន ( O-,m-, P- ) $C_6H_4(NO_2)_2$ | 1 mg / $m^3$ |
| ៤១ | -អេទីឡែនឌីអាមីន $NH_2CH_2CH_2NH_2$ | 30mg / $m^3$ |
| ៤២ | -អេទីឡែន ក្លរអ៊ីឌ្រីន $CH_2ClCH_2OH$ | 16mg / $m^3$ |
| ៤៣ | -អេទីឡែន អុកស៊ីត $CH_2OCH_2$ | 20 mg / $m^3$ |
| ៤៤ | -ហ្វ័រម៉ាល់ដេអ៊ីដ $HCHO$ | 6mg / $m^3$ |
| ៤៥ | -មេទីលអាគ្រីឡាត $CH_2CHCOOCH_3$ | 35 mg / $m^3$ |
| ៤៦ | -មេតាណុល $CH_3OH$ | 260 mg / $m^3$ |
| ៤៧ | -មេទីលប្រូមិត $CH_3Br$ | 80 mg / $m^3$ |
| ៤៨ | -ម៉ូណូមេទីលអានីលីន $C_6H_5NHCH_3$ | 9 mg / $m^3$ |
| ៤៩ | -នីត្រូបង់សែន $C_6H_5NO_2$ | 5 mg / $m^3$ |
| ៥០ | -នីត្រូគ្លីសេរីន $C_3H_5(NO_2)_3$ | 5 mg / $m^3$ |
| ៥១ | -នីត្រូតូលូអែន $NO_2C_6H_4CH_3$ | 30 mg / $m^3$ |
| ៥២ | -ផេណុល $C_6H_5OH$ | 19 mg / $m^3$ |
| ៥៣ | -ផេនីលអ៊ីដ្រាហ្សីន $C_6H_5NHNH_2$ | 22 mg / $m^3$ |
| ៥៤ | -ពីរីនឌីន $C_5H_5N$ | 30 mg / $m^3$ |
| ៥៥ | -ពីរែន $C_{16}H_{10}$ | 15 mg / $m^3$ |
| ៥៦ | -គីណូន $C_6H_4O_2$ | [illegible] |
| ៥៧ | -ស្ទីរែន $C_6H_5CHCH_2$ | [illegible] |
| ៥៨ | 1,12,2-តេត្រាក្លរអេតាន $Cl_2HCCHCl_2$ | [illegible] |
| ៥៩ | -តេត្រាក្លរមេតាន $CCl_4$ | 65 mg / $m^3$ |
| ៦០ | -តូលូអែន $C_6H_2CH_3$ | 750 mg / $m^3$ |
| ៦១ | -តេត្រានីត្រូមេតាន $C(NO_2)_4$ | 8 mg / $m^3$ |
| ៦២ | -តូលូអ៊ីឌីន $CH_3C_6H_4NH_2$ | 22 mg / $m^3$ |
| ៦៣ | -តូលូអែន-2,4-ឌីអ៊ីសូស៊ីអាណាត $CH_3C_6H_3(NCO)_2$ | 0,7mg / $m^3$ |

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០០០

## តារាងឧបសម្ព័ន្ធ ៦
## កំរិតកំណត់ស្តង់ដារសំឡេងអតិបរមា ដែលអនុញ្ញាតនៅតំបន់
## សាធារណៈ និងតំបន់លំនៅដ្ឋាន ( dB (A) )

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង៦ព្រឹក ដល់ម៉ោង ១៨ ល្ងាច | ពីម៉ោង១៨ ល្ងាច ដល់ម៉ោង២២យប់ | ពីម៉ោង ២២ យប់ ដល់ម៉ោង៦ព្រឹក |
| ១ | តំបន់ស្ងប់ស្ងៀម<br>- មន្ទីរពេទ្យ<br>- បណ្ណាល័យ<br>- សាលារៀន<br>- មត្តេយ្យសាលា | ៤៥ | ៤០ | ៣៥ |
| ២ | តំបន់លំនៅដ្ឋាន<br>- សណ្ឋាគារ,ទីកន្លែងរដ្ឋបាល<br>- ភូមិគ្រឹះ, ផ្ទះល្វែង | ៦០ | ៥០ | ៤៥ |
| ៣ | តំបន់ពាណិជ្ជកម្ម , សេវាកម្ម និងចំរុះ | ៧០ | ៦៥ | ៥០ |
| ៤ | ឧស្សាហកម្មតូចស្រាល លាយចំរុះនៅក្នុងតំបន់លំនៅដ្ឋាន | ៧៥ | ៧០ | ៥០ |

**កំណត់សំគាល់ :**

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំឡេងពីប្រភព ឬ សកម្មភាពណាមួយ ដែលបានបញ្ចេញសំឡេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន ។

***

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៥២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០០០

## តារាងឧបសម្ព័ន្ធ ៧
## កំរិតកំណត់ស្តង់ដារសំរាប់ត្រួតពិនិត្យសំលេង
## ក្នុងទីតាំង រោងជាង រោងចក្រឧស្សាហកម្ម

| កំរិតសំលេង (dB (A)) | រយៈពេលអតិបរមា (ម៉ោង) | កំណត់បង្ហាញ |
|---|---|---|
| 75 | 32 | ត្រូវផ្តល់ឧបករណ៍ការពារត្រចៀក ដល់អ្នកបំរើការដែលធ្វើការនៅកន្លែងមានសំលេងលើសពី 80 dB (A) |
| 80 | 16 | |
| 85 | 8 | |
| 90 | 4 | |
| 95 | 2 | |
| 100 | 1 | |
| 105 | 0,5 | |
| 110 | 0,25 | |
| 115 | 0,125 | |

<u>កំណត់សំគាល់</u> :

កំរិតកំណត់ស្តង់ដារនេះអនុវត្តសំរាប់ការត្រួតពិនិត្យកំរិតសំឡេង នៅក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម ។

★★★

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៥២ អនក្រ.បក
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០០០

## តារាងឧបសម្ព័ន្ធ ៨
## កំរិតកំណត់ស្តង់ដារ ជាតិស្ពាន់ធ័រ សំណ បង់សែន
## និង អ៊ីដ្រូកាបួប្រហើរ ដែលអនុញ្ញាតអោយមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម

| ល.រ | សារធាតុចំហេះ | ស្ពាន់ធ័រ ( S ) | សំណ ( Pb ) | បង់សែន | អ៊ីដ្រូកាបួប្រហើរ |
|---|---|---|---|---|---|
| ១ | ប្រេងខ្មៅ | ១,០ % | | | |

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធរូបភាពទី១៖ ផែនទីរូបពីលើអាកាសក្រុងដូនកែវ




**សញ្ញាសម្គាល់**

- ទីតាំងសាលាខេត្តតាកែវ
- ទីតាំងសាលាក្រុងដូនកែវ
- ទីតាំងសាលា ឃុំ សង្កាត់
- ព្រំប្រទល់រដ្ឋបាលក្រុងដូនកែវ
- ព្រំប្រទល់រដ្ឋបាលក្រុង ស្រុក
- ព្រំប្រទល់រដ្ឋបាលឃុំ សង្កាត់
- ព្រំប្រទល់ភូមិ

ក្រុងដូនកែវមានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា មានចម្ងាយ៧៨គីឡូម៉ែត្រពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ២ មានផ្លូវដែកឆ្លងកាត់ដែលតភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ខេត្តកំពតនិងខេត្តព្រះសីហនុ។ ក្រុងនេះមានផ្ទៃដី៩ ៦២៨,៨១ហិកតា ចែកជា៣សង្កាត់គឺសង្កាត់រកាក្នុង សង្កាត់រកាក្រៅ និងសង្កាត់បារាយណ៍ ព្រមទាំងមានភូមិចំនួន៤០។

# ឧបសម្ព័ន្ធរូបភាពទី២៖ ទីតាំងសំខាន់ៗក្នុងក្រុងដូនកែវ



វិមានឯករាជ្យ

សាលាខេត្តតាកែវ



សាលាក្រុងដូនកែវ



សាលាដំបូងខេត្តតាកែវ




មន្ទីរអប់រំយុវជន និងកីឡា ខេត្តតាកែវ




មន្ទីរទេសចរណ៍ខេត្តតាកែវ



មន្ទីរសង្គមកិច្ច



# ឧបសម្ព័ន្ធរូបភាពទី៣៖ សកម្មភាព និងសមិទ្ធផលផ្សេងៗក្នុងក្រុងដូនកែវ















